ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៥ លេខ៦១ ត្រីមាសទី០៣ ឆ្នាំ២០២៥

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ៥-៩-២០២៥ | -ព្រះរាជក្រម នស/រកម/០៩២៥/០៣១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ | ៧៥១៣ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៧-៨-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៥/១១៦៣ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់លោក **ឌី សុខលីន** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអប់រំ យុវជន និងកីឡា | ៧៦៣៦ |
| ៣០-៨-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៥/១១៦៨ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **អ៊ុក វណ្ណារិទ្ធ** ពីសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី | ៧៦៣៧ |
| ៣០-៨-២០២៥ | -ព្រះរាជក្រឹត្យ នស/រកត/០៨២៥/១១៦៩ ស្តីពី ការបញ្ចប់មុខតំណែងលោកជំទាវ **តាន់ ឥន្ទ្រាទេវី** ពីទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក | ៧៦៣៨ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ១១-៨-២០២៥ | -អនុក្រឹត្យលេខ ១៤២ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៧៦៣៩ |
| ១១-៨-២០២៥ | -អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៧៦៤១ |
| ១១-៨-២០២៥ | -អនុក្រឹត្យលេខ ៦៨៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៧៦៤៣ |

# ព្រះរាជក្រម

នស/រកម/០៩២៥/០៣១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការអភិរក្ស
# និងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាព
# នៅក្រៅដែនយុត្តាធិការជាតិក្រោមអនុសញ្ញា
# សហប្រជាជាតិស្ដីពីច្បាប់សមុទ្រ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅទីក្រុងនីសនៃសាធារណរដ្ឋបារាំង នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ១៣ កើត ខែ ភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០២៥

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បញ្ជាប់**
**ប្រមុខរដ្ឋស្តីទី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ពសរ. ៧៥០៩. ១៤១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**

# កិច្ចព្រមព្រៀងស្តីពីការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះសមុទ្រ ប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិ (BBNJ) ក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ



## បុព្វកថា

*រដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ*

*ដោយរំលឹកឡើងវិញ* ពីបទប្បញ្ញត្តិពាក់ព័ន្ធអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ រួមទាំងកាតព្វកិច្ចការពារនិងអភិរក្សបរិស្ថានសមុទ្រ។

*ដោយបញ្ជាក់* ពីតម្រូវការក្នុងការគោរពនូវតុល្យភាពនៃសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ដូចមានចែងក្នុងអនុសញ្ញា។

*ដោយទទួលស្គាល់* ពីតម្រូវការក្នុងការដោះស្រាយដែលមានលក្ខណៈស៊ីចង្វាក់និងកិច្ចសហការដើម្បីការពារការបាត់បង់ជីវៈចម្រុះនិងការរេចរឹលប្រព័ន្ធអេកូឡូស៊ីមហាសមុទ្រ ជាពិសេសដែលបណ្តាលមកពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើប្រព័ន្ធអេកូឡូស៊ីសមុទ្រ រួមមានការឡើងកម្តៅនិងការថយចុះអុកស៊ីសែនក្នុងមហាសមុទ្រ ក៏ដូចជាអាស៊ីដកម្មមហាសមុទ្រ ការបំពុលសមុទ្ររួមទាំងការបំពុលដោយប្លាស្ទិក និងការប្រើប្រាស់មិនប្រកបដោយចីរភាព។

*ដោយយល់ដឹង* ពីតម្រូវការឱ្យមានការគ្រប់គ្រងជាសាកលដ៏ទូលំទូលាយ នៅក្រោមអនុសញ្ញានេះ ដើម្បីធានាឱ្យបានកាន់តែប្រសើរ ក្នុងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រយ៉ាងសម្បូរបែបក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

*ដោយទទួលស្គាល់* ពីសារៈសំខាន់ក្នុងការរួមចំណែកដល់ការធ្វើឱ្យសម្រេចបាននូវសណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិប្រកបដោយយុត្តិធម៌និងសមធម៌ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍និងតម្រូវការរបស់មនុស្សជាតិជារួមនិងជាពិសេស ដល់ផលប្រយោជន៍និងតម្រូវការចាំបាច់របស់រដ្ឋកំពុងអភិវឌ្ឍ ដោយមិនគិតពីរដ្ឋនោះជាប់ឬមិនជាប់នឹងឆ្នេរសមុទ្រឡើយ។

*ដោយទទួលស្គាល់ផងដែរលើ* ការគាំទ្រដល់រដ្ឋភាគីកំពុងអភិវឌ្ឍ តាមរយៈការកសាង ការអភិវឌ្ឍសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យាសមុទ្រ គឺជាធាតុដ៏សំខាន់សម្រាប់ឈានទៅសម្រេចគោលដៅនៃការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រ ក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

*ដោយរំលឹកឡើងវិញ* ពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។

*ដោយបញ្ជាក់ថា* មិនមានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវបានបកស្រាយក្នុងទម្រង់ជាការកាត់បន្ថយឬលុបបំបាត់សិទ្ធិជាធរមានរបស់ជនជាតិដើមភាគតិច រួមទាំងខ្លឹមសារដូចមានចែងក្នុងសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចឬសហគមន៍មូលដ្ឋាននោះឡើយ។

*ដោយទទួលស្គាល់* ពីកាតព្វកិច្ចដូចមានចែងក្នុងអនុសញ្ញាដើម្បីវាយតម្លៃផលប៉ះពាល់ តាមលទ្ធភាពដែលអាចអនុវត្តបាន ពីសកម្មភាពនានាលើបរិស្ថានសមុទ្រ ដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់រដ្ឋមួយ នៅពេលដែលរដ្ឋនោះមានមូលដ្ឋានសមហេតុផលនាំដល់ការជឿជាក់ថា សកម្មភាពទាំងនោះអាចបណ្តាលឱ្យមានការបំពុលយ៉ាងធ្ងន់ធ្ងរឬមានការផ្លាស់ប្តូរយ៉ាងខ្លាំងនិងប្រកបដោយគ្រោះថ្នាក់ដល់បរិស្ថានសមុទ្រ។

*ដោយយកចិត្តទុកដាក់* លើកាតព្វកិច្ចដូចដែលបានកំណត់ក្នុងអនុសញ្ញានេះ ក្នុងការចាត់វិធានការចាំបាច់ [illegible] គឺស្របតាមអនុសញ្ញានេះដើម្បីធានាថា ការបំពុលដែលបណ្តាលមកពីឧប្បត្តិហេតុឬសកម្មភាពនានា [illegible]ហួសពីតំបន់ដែលស្ថិតក្រោមសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន។

*ដោយមានបំណងចង់* បំពេញតួនាទីជាអ្នកទទួលសិទ្ធិគ្រប់គ្រងសមស្របលើមហាសមុទ្រនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ក្នុងនាមមនុស្សជំនាន់បច្ចុប្បន្ននិងអនាគត តាមរយៈការការពារ ការថែទាំ និងការធានាដល់ការប្រើប្រាស់បរិស្ថានសមុទ្រប្រកបដោយការទទួលខុសត្រូវ ការរក្សាបាននូវសុខភាពល្អនៃប្រព័ន្ធអេកូឡូស៊ីមហាសមុទ្រ និងការអភិរក្សតម្លៃពីធម្មជាតិនៃជីវៈចម្រុះ នៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

*ដោយទទួលស្គាល់ថា* ការបង្កើត លទ្ធភាពទទួលបាន និងការប្រើប្រាស់ព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌និងសមធម៌ពីការប្រើប្រាស់ធនធានពន្ធុទាំងនេះ ដើម្បីរួមចំណែកដល់ការស្រាវជ្រាវនិងនវានុវត្តន៍ និងគោលដៅទូទៅនៃកិច្ចព្រមព្រៀងនេះ។

*ដោយគោរពដល់* អធិបតេយ្យភាព បូរណភាពដែនដី និងឯករាជ្យផ្នែកនយោបាយរបស់រដ្ឋទាំងអស់។

*ដោយរំលឹកឡើងវិញថា* ស្ថានភាពនីត្យានុកូលរបស់រដ្ឋភាគីដែលមិនមែនជាសមាជិកនៃអនុសញ្ញានេះឬកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗទៀត ត្រូវបានគ្រប់គ្រងដោយនីតិរដ្ឋនៃសន្ធិសញ្ញានានា។

*ដោយរំលឹកឡើងវិញផងដែរថា* រដ្ឋទាំងអស់ត្រូវទទួលខុសត្រូវក្នុងការបំពេញកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនដែលទាក់ទងទៅនឹងការការពារនិងការអភិរក្សបរិស្ថានសមុទ្រ ហើយអាចទទួលខុសត្រូវស្របតាមច្បាប់អន្តរជាតិដូចដែលមានចែងក្នុងអនុសញ្ញា។

*ដោយប្តេជ្ញា* ធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

*ដោយមានបំណង* ធ្វើឱ្យសម្រេចបាននូវការចូលរួមជាសាកល។

*អាស្រ័យហេតុនេះ បានឯកភាព* ដូចខាងក្រោម៖

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

### មាត្រា១

### ការប្រើប្រាស់វាក្យសព្ទ

វាក្យសព្ទដែលប្រើក្នុងកិច្ចព្រមព្រៀងនេះមាន ដូចតទៅ៖

១- ឧបករណ៍គ្រប់គ្រងតាមតំបន់ (Area-based management tool) សំដៅដល់ឧបករណ៍ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលជាតំបន់កំណត់តាមភូមិសាស្ត្រ តាមរយៈការគ្រប់គ្រងតាមវិស័យមួយឬច្រើន ឬសកម្មភាពមួយឬច្រើនជាពិសេសក្នុងគោលដៅធ្វើឱ្យសម្រេចនូវការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាព ស្របតាមកិច្ចព្រមព្រៀងនេះ។

២- តំបន់ក្រៅដែនយុត្តាធិការជាតិ (Areas beyond national jurisdiction) សំដៅដល់សមុទ្រអន្តរជាតិ និងផ្ទៃបាតសមុទ្រអន្តរជាតិ។

៣- ជីវបច្ចេកវិទ្យា (Biotechnology) សំដៅដល់ការអនុវត្តបច្ចេកវិទ្យាដែលប្រើប្រាស់ប្រព័ន្ធជីវៈចម្រុះ សារពាង្គកាយ ឬនិស្សន្ទវត្ថុមានជីវិតដើម្បីផលិតឬកែប្រែផលិតផលឬដំណើរការសម្រាប់ការប្រើប្រាស់ជាក់លាក់ណាមួយ។

៤- ការយកសំណាកនៅនឹងកន្លែង (Collection in situ) ទាក់ទងនឹងធនធានពន្ធុសមុទ្រ សំដៅដល់ការប្រមូល ឬការយកសំណាកនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៥- អនុសញ្ញា (Convention) សំដៅដល់អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២។

៦- ហេតុប៉ះពាល់កើនសរុប (Cumulative impact) សំដៅដល់ផលប៉ះពាល់រួមនិងមានកម្រិតកើនឡើងដែលបណ្តាលមកពីសកម្មភាពផ្សេងៗគ្នា រួមទាំងសកម្មភាពដែលបានស្គាល់ពីមុន សកម្មភាពបច្ចុប្បន្ននិងសកម្មភាពដែលអាចដឹងជាមុនប្រកបដោយហេតុផលឬពីភាពច្រំដែលនៃសកម្មភាពស្រដៀងគ្នាក្នុងអំឡុងពេលណាមួយ និងផលវិបាកនៃការប្រែប្រួលអាកាសធាតុ អាស៊ីដកម្មមហាសមុទ្រ និងផលប៉ះពាល់ពាក់ព័ន្ធផ្សេងទៀត។

៧- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (Environmental impact assessment) សំដៅដល់ដំណើរការក្នុងការកំណត់អត្តសញ្ញាណនិងវាយតម្លៃហេតុប៉ះពាល់ជាសក្តានុពល ផលប៉ះពាល់នៃសកម្មភាពដើម្បីប្រើជាព័ត៌មានសម្រាប់ធ្វើសេចក្តីសម្រេច។

៨- ធនធានពន្ធុសមុទ្រ (Marine genetic resources) សំដៅដល់ផ្នែកណាមួយនៃរុក្ខជាតិសមុទ្រ សត្វសមុទ្រ មីក្រូជីវៈសមុទ្រ ឬប្រភពដើមផ្សេងៗទៀតពីសមុទ្រ ដែលមានឯកតាមុខងារតំណពូជនៃតម្លៃជាក់ស្តែងឬតម្លៃជាសក្តានុពល។

៩- តំបន់ការពារធម្មជាតិសមុទ្រ (Marine protected area) សំដៅដល់តំបន់សមុទ្រណាមួយដែលត្រូវបានបង្កើតឡើងដោយកំណត់តាមភូមិសាស្ត្រនិងក្នុងគោលដៅគ្រប់គ្រង អភិរក្សជីវៈចម្រុះជាក់លាក់ក្នុងរយៈពេលវែង ហើយក្នុងករណីសមស្រប អាចអនុញ្ញាតឱ្យប្រើប្រាស់ប្រកបដោយចីរភាព ប្រសិនបើការប្រើប្រាស់នោះសមស្របនឹងគោលដៅនៃការអភិរក្ស។

១០- បច្ចេកវិទ្យាសមុទ្រ (Marine technology) សំដៅដល់ព័ត៌មាននិងទិន្នន័យដែលត្រូវបានបង្កើតឡើងជាទម្រង់ងាយស្រួលប្រើប្រាស់អំពីវិទ្យាសាស្ត្រសមុទ្រ ព្រមទាំងប្រតិបត្តិការនិងសេវាកម្មសមុទ្រពាក់ព័ន្ធ សៀវភៅណែនាំ គោលការណ៍ណែនាំ លក្ខណវិនិច្ឆ័យ ស្តង់ដានិងឯកសារយោង ឧបករណ៍យកសំណាកនិងអភិក្រម គ្រឿងបរិក្ខារសង្កេតនិងឧបករណ៍សម្រាប់អង្កេត ការវិភាគនិងការធ្វើពិសោធន៍ក្នុងទីតាំងនិងបន្ទប់ពិសោធន៍ កុំព្យូទ័រនិងកម្មវិធីកុំព្យូទ័រ រួមទាំងគំរូនិងបច្ចេកទេសធ្វើគំរូ ជីវបច្ចេកវិទ្យាពាក់ព័ន្ធនិងឯកទេស ចំណេះដឹង ជំនាញ ចំណេះដឹងបច្ចេកទេសវិទ្យាសាស្ត្រនិងច្បាប់និងអភិក្រមវិភាគទាក់ទងនឹងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រ។

១១- រដ្ឋភាគី (Party) សំដៅដល់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលបានយល់ព្រមទទួលអនុវត្តកិច្ចព្រមព្រៀង នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

១២- អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ (Regional economic integration organization) សំដៅដល់អង្គការដែលបង្កើតឡើងដោយរដ្ឋអធិបតេយ្យនៃតំបន់ដែលបានកំណត់ ដែលរដ្ឋជាសមាជិករបស់ខ្លួនបានផ្ទេរសមត្ថភាពទាក់ទងនឹងបញ្ហា ក្រោមការគ្រប់គ្រងនៃកិច្ចព្រមព្រៀងនេះនិងដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវ ស្របតាមនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្វីការ ឬចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។

១៣- ការប្រើប្រាស់ប្រកបដោយចីរភាព (Sustainable use) សំដៅដល់ការប្រើប្រាស់សមាសភាគជីវៈចម្រុះតាមរបៀបនិងក្នុងអត្រាមួយដែលមិននាំឱ្យមានការថយចុះនូវជីវៈចម្រុះក្នុងរយៈពេលយូរអង្វែង ដោយត្រូវរក្សាបាននូវសក្តានុពលរបស់ជីវៈចម្រុះ ដើម្បីបំពេញតម្រូវការនិងសេចក្តីប្រាថ្នារបស់មនុស្សជំនាន់បច្ចុប្បន្ននិងអនាគត។

១៤- ការប្រើប្រាស់ធនធានពន្ធុសមុទ្រ (Utilization of marine genetic resources) សំដៅដល់ការស្រាវជ្រាវ និងអភិវឌ្ឍលើសមាសភាពពន្ធុនិង/ឬគីមីជីវសាស្ត្រនៃធនធានពន្ធុសមុទ្រ រួមទាំងតាមរយៈការអនុវត្តជីវបច្ចេកវិទ្យា ដូចដែលបានកំណត់ក្នុងកថាខណ្ឌ៣ខាងលើ។

## មាត្រា២

## គោលដៅទូទៅ

កិច្ចព្រមព្រៀងនេះ មានគោលដៅធានាឱ្យបាននូវការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ សម្រាប់បច្ចុប្បន្ននិងរយៈពេលវែង តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញា កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរជាតិបន្ថែមទៀត។

## មាត្រា៣

## វិសាលភាពនៃការអនុវត្ត

កិច្ចព្រមព្រៀងនេះ មានវិសាលភាពអនុវត្តចំពោះតំបន់ក្រៅដែនយុត្តាធិការជាតិ។

## មាត្រា៤

## អញ្ញត្រកម្ម

កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះនាវាចម្បាំង យន្តហោះយោធាឬជំនួយកងទ័ពជើងទឹកទេ។ លើកលែងតែផ្នែកទី៣ ប៉ុណ្ណោះ កិច្ចព្រមព្រៀងនេះនឹងមិនអនុវត្តចំពោះនាវាឬយន្តហោះផ្សេងទៀតដែលជាកម្មសិទ្ធិឬដំណើរការដោយរដ្ឋភាគីណាមួយក្នុងពេលបច្ចុប្បន្ន ហើយត្រូវបានប្រើប្រាស់តែលើសេវាកម្មដែលមិនមែនពាណិជ្ជកម្មរបស់រដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការអនុម័តនូវវិធានការសមស្រប រដ្ឋភាគីនីមួយៗត្រូវធានាថានឹងមិនធ្វើឱ្យខូចខាតនូវប្រតិបត្តិការឬសមត្ថភាពប្រតិបត្តិការរបស់នាវាឬយន្តហោះដែលខ្លួនគ្រប់គ្រងឬដំណើរការ ដោយនាវាឬយន្តហោះនោះដែលធ្វើសកម្មភាពក្នុងលំនាំស្របគ្នានឹងកិច្ចព្រមព្រៀងនេះ ក្នុងពេលមានភាពសមហេតុផលនិងជាក់ស្តែង។

## មាត្រា៥

## ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញានិងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ

១- កិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយនិងអនុវត្តក្នុងបរិបទនិងក្នុងលំនាំដែលមានលក្ខណៈស្របនឹងអនុសញ្ញា។ គ្មានចំណុចណាមួយក្នុងកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងឱ្យប៉ះពាល់ដល់សិទ្ធិ យុត្តាធិការ និងកាតព្វកិច្ចរបស់រដ្ឋនានានៅក្រោមអនុសញ្ញានេះ រួមទាំងទាក់ទងនឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងខ្ពង់រាបបាតសមុទ្រក្នុងនិងលើសពី២០០(ពីររយ) ម៉ាយល៍ចូលក្នុងសមុទ្រ។

២- កិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយនិងអនុវត្តក្នុងលំនាំដែលមិនប៉ះពាល់ដល់អង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ហើយលើកកម្ពស់ឱ្យមានសង្គតិភាពជាមួយនឹងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៣- ស្ថានភាពនីត្យានុកូលនៃរដ្ឋដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញាឬកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលិខិតូបករណ៍ទាំងនោះ គឺមិនត្រូវបានប៉ះពាល់ដោយកិច្ចព្រមព្រៀងនេះទេ។

## មាត្រា៦

## ភាពគ្មានព្យសនកម្ម

កិច្ចព្រមព្រៀងនេះ រួមទាំងសេចក្តីសម្រេចឬអនុសាសន៍ណាមួយនៃសន្និសីទបណ្តារដ្ឋភាគីឬអង្គភាពក្រោមឱវាទណាមួយរបស់ខ្លួន ព្រមទាំងវិធានច្បាប់ វិធានការឬសកម្មភាពណាមួយដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋាន ដែលបាន

កំណត់ក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវមានព្យសនកម្មនិងមិនត្រូវយកកិច្ចព្រមព្រៀងនេះធ្វើជាមូលដ្ឋាន សម្រាប់ការអះអាងឬការបដិសេធការទាមទារណាមួយចំពោះអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាពឬយុត្តាធិការ រួមទាំងវិវាទណាមួយដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះឡើយ។

**មាត្រា៧**

**គោលការណ៍ទូទៅនិងអភិក្រម**

ដើម្បីសម្រេចគោលដៅនៃកិច្ចព្រមព្រៀងនេះបាន រដ្ឋភាគីទាំងអស់ត្រូវទទួលបានការណែនាំអំពីគោលការណ៍និងអភិក្រម ដូចតទៅ៖

ក- គោលការណ៍អ្នកបំពុលត្រូវបង់ប្រាក់។

ខ- គោលការណ៍ស្តីពីបេតិកភណ្ឌរួមរបស់មនុស្សជាតិ ដូចមានចែងក្នុងអនុសញ្ញា។

គ- សេរីភាពក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ រួមទាំងសេរីភាពផ្សេងទៀតនៃតំបន់សមុទ្រនៅក្រៅដែនយុត្តាធិការជាតិ។

ឃ- គោលការណ៍ស្តីពីសមធម៌និងការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌និងសមធម៌។

ង- គោលការណ៍ត្រៀមទប់ស្កាត់បញ្ហាឬអភិក្រមត្រៀមទប់ស្កាត់បញ្ហា ក្នុងករណីសមស្រប។

ច- អភិក្រមស្តីពីប្រព័ន្ធអេកូឡូស៊ី។

ឆ- អភិក្រមសមាហរណកម្មសម្រាប់គ្រប់គ្រងមហាសមុទ្រ។

ជ- អភិក្រមបង្កើតភាពធន់នៃប្រព័ន្ធអេកូឡូស៊ី រួមទាំងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុនិងអាស៊ីដកម្មមហាសមុទ្រ ហើយថែមទាំងរក្សានិងស្តារឡើងវិញនូវគុណតម្លៃមុខងារនៃប្រព័ន្ធអេកូឡូស៊ី រួមទាំងសេវាវដ្តកាបូនដែលកំណត់ពីតួនាទីរបស់មហាសមុទ្រក្នុងអាកាសធាតុ។

ឈ- ការប្រើប្រាស់វិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រចុងក្រោយបំផុត។

ញ- ការប្រើប្រាស់ចំណេះដឹងពាក់ព័ន្ធជាប្រពៃណីរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ក្នុងករណីធ្វើបាន។

ដ- ការគោរព ការលើកកម្ពស់និងការពិចារណាអនុវត្តកាតព្វកិច្ចរៀងៗខ្លួន ក្នុងករណីអនុវត្តបានដែលទាក់ទងនឹងសិទ្ធិរបស់ជនជាតិដើមភាគតិចឬបើអាចធ្វើបាន សហគមន៍មូលដ្ឋាន នៅពេលមានចំណាត់ការ ដើម្បីជំរុញការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ឋ- ការមិនបញ្ជូនដោយផ្ទាល់ឬដោយប្រយោល នូវព្យសនកម្មឬការគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀត និងការមិនបម្លែងប្រភេទនៃការបំពុលមួយទៅប្រភេទនៃការបំពុលមួយទៀត ក្រោមហេតុផលទប់ស្កាត់ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។

ឌ- ការទទួលស្គាល់ពេញលេញនៃកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសមានការអភិវឌ្ឍតិចតួច។

ឍ- ការទទួលស្គាល់ផលប្រយោជន៍និងតម្រូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍដែលមិនជាប់សមុទ្រ។

**មាត្រា៨**

**កិច្ចសហប្រតិបត្តិការអន្តរជាតិ**

១- តាមរយៈកិច្ចព្រមព្រៀងនេះ រដ្ឋភាគីទាំងអស់ត្រូវសហការគ្នាដើម្បីអភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងតាមរយៈការពង្រឹង បង្កើនកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅថ្នាក់សាកល តំបន់ អនុតំបន់ និងតាមវិស័យ ដើម្បីធ្វើឱ្យសម្រេចគោលដៅនៃកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ក្នុងករណីសមស្រប រដ្ឋភាគីត្រូវខិតខំលើកកម្ពស់គោលដៅនៃកិច្ចព្រមព្រៀងនេះ នៅពេលចូលរួមក្នុងការសម្រេចចិត្ត ស្ថិតនៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៣- រដ្ឋភាគីទាំងអស់ត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រនិងក្នុងការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ស្របតាមអនុសញ្ញាដើម្បីគាំទ្រដល់ការធ្វើឱ្យសម្រេចគោលដៅនៃកិច្ចព្រមព្រៀងនេះ។

## ផ្នែកទី២

## ធនធានពន្ធុសមុទ្រ រួមទាំងការបែងចែកផលប្រយោជន៍ ដោយយុត្តិធម៌និងសមធម៌

### មាត្រា៩

### គោលដៅ

ផ្នែកនេះមានគោលដៅ ដូចតទៅ៖

ក- ការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌និងសមធម៌នៃផលប្រយោជន៍ពីសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុ(DSI) នៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិសម្រាប់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ខ- ការកសាងនិងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋភាគី ជាពិសេសរដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ ជាងនេះទៀតប្រទេសមានការអភិវឌ្ឍតិចតួច រដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ រដ្ឋតាមតំបន់ឆ្នេរនៅទ្វីបអាហ្វ្រិក រដ្ឋប្រជុំកោះនិងប្រទេសកំពុងអភិវឌ្ឍមានប្រាក់ចំណូលមធ្យម ដើម្បីធ្វើសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់នៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

គ- ការកសាងចំណេះដឹង ការយល់ដឹងផ្នែកវិទ្យាសាស្ត្រនិងនវានុវត្តន៍ផ្នែកបច្ចេកវិទ្យា រួមទាំងតាមរយៈការអភិវឌ្ឍនិងការធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ដែលជាសារវន្តនៃការចែករំលែកការអនុវត្តកិច្ចព្រមព្រៀងនេះ។

ឃ- ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រស្របតាមកិច្ចព្រមព្រៀងនេះ។

### មាត្រា១០

### វិសាលភាពអនុវត្ត

១- បទប្បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះសកម្មភាព ដែលទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដែលបានប្រមូលនិងបង្កើតឱ្យមាន បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់រដ្ឋភាគីរៀងៗខ្លួន។ ការអនុវត្តបទប្បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ ត្រូវពង្រីកដល់ការប្រើប្រាស់ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដែលបានប្រមូលឬបង្កើតឱ្យមានមុនពេលចូលជាធរមាន លើកលែងតែរដ្ឋភាគីណាមួយស្នើសុំលើកលែងជាលាយលក្ខណ៍អក្សរ ដូចមានកំណត់ក្នុងមាត្រា៧០ នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្វីការ ឬចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។

២- បទប្បញ្ញត្តិនៃផ្នែកនេះមិនត្រូវអនុវត្តចំពោះ៖

ក- ការនេសាទដែលត្រូវបានគ្រប់គ្រងដោយច្បាប់អន្តរជាតិនិងសកម្មភាពទាក់ទងនឹងការនេសាទពាក់ព័ន្ធឬធនធានជលផលឬធនធានសមុទ្រមានជីវិតផ្សេងទៀត ដែលត្រូវបានដឹងថាបានចាប់ក្នុងពេលនេសាទនិងសកម្មភាពទាក់ទងនឹងការនេសាទក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ លើកលែងតែត្រីឬធនធានសមុទ្រដែលមានជីវិតផ្សេងទៀតដែលត្រូវបានកំណត់ឱ្យប្រើប្រាស់ ដូចមានកំណត់នៅក្នុងផ្នែកនេះ។



៣- កាតព្វកិច្ចនៅក្នុងផ្នែកនេះនឹងមិនត្រូវអនុវត្តទេចំពោះសកម្មភាពយោធារបស់រដ្ឋភាគីមួយ រួមទាំងសកម្មភាពយោធាដោយនាវានិងយន្តហោះរបស់រដ្ឋាភិបាលនៃរដ្ឋនោះ ដែលបានចូលរួមក្នុងសេវាមិនមែនពាណិជ្ជកម្ម។ កាតព្វកិច្ចនៅក្នុងផ្នែកនេះដែលទាក់ទងនឹងការប្រើប្រាស់ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវអនុវត្តចំពោះសកម្មភាពមិនមែនយោធារបស់រដ្ឋភាគីមួយ។

## មាត្រា១១

## សកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ

១- សកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ អាចត្រូវបានធ្វើឡើងដោយរដ្ឋភាគីទាំងអស់ មិនថាស្ថិតក្នុងទីតាំងភូមិសាស្ត្ររបស់ខ្លួននិងដោយរូបវន្តបុគ្គលឬនីតិបុគ្គល ដែលស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគី។ សកម្មភាពបែបនេះត្រូវធ្វើឡើងស្របតាមកិច្ចព្រមព្រៀងនេះ។

២- រដ្ឋភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់សកម្មភាពទាំងអស់ ដែលទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៣- ការយកសំណាកនៅនឹងកន្លែងនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវធ្វើឡើងនៅក្នុងតំបន់ក្រៅដែនយុត្តាធិការ ជាតិរបស់ខ្លួន ដោយយកចិត្តទុកដាក់ខ្ពស់លើសិទ្ធិនិងផលប្រយោជន៍ធម្មានុរូបនៃរដ្ឋជាប់ឆ្នេរសមុទ្រ និងដោយយកចិត្តទុកដាក់ខ្ពស់លើផលប្រយោជន៍របស់រដ្ឋភាគីផ្សេងទៀតនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ស្របតាមអនុសញ្ញានេះ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋភាគីត្រូវខិតខំសហការគ្នា ក្នុងពេលសមស្រប រួមទាំងតាមរយៈទម្រង់ជាក់លាក់នៃកិច្ចប្រតិបត្តិការសម្រាប់យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ដូចមានចែកក្នុងមាត្រា៥១ រួមទាំងទិដ្ឋភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

៤- គ្មានរដ្ឋណាមួយត្រូវទាមទារឬអនុវត្តអធិបតេយ្យភាពឬសិទ្ធិអធិបតេយ្យភាពលើធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិឡើយ។ គ្មានការទាមទារឬការអនុវត្តអធិបតេយ្យភាពឬសិទ្ធិអធិបតេយ្យភាពត្រូវបានទទួលស្គាល់ទេ។

៥- ការយកសំណាកនៅនឹងកន្លែងនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ មិនត្រូវបង្កើតឱ្យមានជាមូលដ្ឋានច្បាប់សម្រាប់ការទាមទារយកផ្នែកណាមួយនៃបរិស្ថានសមុទ្រឬធនធានសមុទ្រនោះឡើយ។

៦- សកម្មភាពនានាទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថល អំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ គឺធ្វើឡើងសម្រាប់ជាផលប្រយោជន៍របស់រដ្ឋភាគីទាំងអស់និងជាប្រយោជន៍របស់មនុស្សជាតិទាំងមូល ជាពិសេសសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្ររបស់មនុស្សជាតិនិងការលើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍និងតម្រូវការរបស់រដ្ឋភាគីកំពុងអភិវឌ្ឍ។

៧- សកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវធ្វើឡើងផ្តាច់មុខ ហើយសម្រាប់តែក្នុងគោលដៅសន្តិភាពប៉ុណ្ណោះ។

## មាត្រា១២

## សេចក្តីជូនដំណឹងអំពីសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ

១- រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់លើផ្នែកច្បាប់ រដ្ឋបាលឬគោលនយោបាយ ដើម្បីធានាថា ព័ត៌មាននេះត្រូវបានផ្តល់ជូនទៅយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ដូចមានកំណត់នៅផ្នែកនេះ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ស ៨៤

២- ព័ត៌មានខាងក្រោមត្រូវបញ្ជូនទៅយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ក្នុងរយៈពេល៦(ប្រាំមួយ)ខែ ឬឆាប់ជាងនេះ តាមដែលអាចធ្វើទៅបាន មុនពេលយកសំណាកនៅនឹងកន្លែងនៃធនធានពន្ធុសមុទ្រនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ៖

ក- លក្ខណៈនិងគោលដៅនៃការប្រមូលធនធានពន្ធុសមុទ្រ រួមទាំងកម្មវិធីណាមួយដែលជាផ្នែកមួយនៃការប្រមូលធនធានពន្ធុសមុទ្រ ក្នុងករណីសមស្រប។

ខ- ប្រធានបទនៃការស្រាវជ្រាវឬបើដឹងនូវធនធានពន្ធុសមុទ្រដែលត្រូវបានកំណត់ជាគោលដៅឬត្រូវប្រមូល និងគោលដៅក្នុងការប្រមូលធនធានទាំងនោះ។

គ- តំបន់ភូមិសាស្ត្រដែលនឹងត្រូវការប្រមូលនូវធនធានពន្ធុនោះ។

ឃ- សេចក្តីសង្ខេបនៃអភិក្រមនិងមធ្យោបាយដែលត្រូវប្រមូល រួមទាំងឈ្មោះ ទម្ងន់ ប្រភេទនិងចំណាត់ថ្នាក់នាវា បរិក្ខារវិទ្យាសាស្ត្រនិង/ឬអភិក្រមសិក្សាដែលត្រូវបានអនុវត្ត។

ង- ព័ត៌មានទាក់ទងនឹងការរួមចំណែកផ្សេងទៀតដល់កម្មវិធីសំខាន់ៗដែលបានស្នើឡើង។

ច- កាលបរិច្ឆេទរំពឹងទុកនៃការចូលទីតាំងលើកដំបូងនិងការចាកចេញចុងក្រោយនៃនាវាស្រាវជ្រាវឬការដាក់ពង្រាយឧបករណ៍និងការដកចេញឧបករណ៍ទាំងនោះវិញ ក្នុងពេលសមស្រប។

ឆ- ឈ្មោះស្ថាប័នឧបត្ថម្ភនិងអ្នកទទួលខុសត្រូវគម្រោង។

ជ- ឱកាសសម្រាប់អ្នកវិទ្យាសាស្ត្រពីរដ្ឋទាំងអស់ ជាពិសេសអ្នកវិទ្យាសាស្ត្រមកពីរដ្ឋកំពុងអភិវឌ្ឍ ដើម្បីចូលរួមឬមានទំនាក់ទំនងជាមួយគម្រោង។

ឈ- វិសាលភាពដែលត្រូវបានចាត់ទុកថា រដ្ឋដែលអាចមានតម្រូវការនិងស្នើសុំជំនួយបច្ចេកទេស ជាពិសេសរដ្ឋកំពុងអភិវឌ្ឍ គួរចូលរួមឬមានតំណាងនៅក្នុងគម្រោង។

ញ- ផែនការគ្រប់គ្រងទិន្នន័យដែលបានរៀបចំឡើង ដោយយោងតាមការគ្រប់គ្រងទិន្នន័យ ដោយបើកទូលាយ និងមានការទទួលខុសត្រូវដោយផ្អែកលើការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ន។

៣- បន្ទាប់ពីមានការជូនដំណឹងដូចដែលបានកំណត់ក្នុងកថាខណ្ឌ២ខាងលើ យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាននឹងបង្កើតឱ្យមានឧបករណ៍កំណត់អត្តសញ្ញាណបណ្តុំស្តង់ដា «BBNJ» ដោយស្វ័យប្រវត្ត។

៤- នៅពេលដែលមានការផ្លាស់ប្តូរជាសារវន្តចំពោះព័ត៌មានដែលបានផ្តល់ទៅឱ្យយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន មុនពេលមានការប្រមូលដូចបានគ្រោងទុក ព័ត៌មានបច្ចុប្បន្នកម្មត្រូវផ្តល់ទៅឱ្យយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានក្នុងរយៈពេលដ៏សមស្របមួយ ហើយមិនត្រូវនៅក្រោយការចាប់ផ្តើមការយកសំណាកនៅនឹងកន្លែងនៃធនធានពន្ធុសមុទ្រខណៈអនុវត្តបាន។

៥- រដ្ឋភាគីទាំងអស់ត្រូវធានាថា ព័ត៌មានខាងក្រោម ដោយរួមនឹងឧបករណ៍កំណត់អត្តសញ្ញាណបណ្តុំស្តង់ដា «BBNJ» ត្រូវបានបញ្ជូនទៅយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានភ្លាមៗ នៅពេលមានព័ត៌មានទាំងនោះ ប៉ុន្តែមិនលើសពីមួយឆ្នាំ បន្ទាប់ពីមានការការយកសំណាកនៅនឹងកន្លែងនៃធនធានពន្ធុសមុទ្រនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ៖

ក- កន្លែងផ្ទុកទិន្នន័យឬមូលដ្ឋានទិន្នន័យដែលកំពុងផ្ទុកឬនឹងផ្ទុកព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រ។

ខ- កន្លែងដែលកំពុងឬនឹងផ្ទុកឬរក្សាទុកធនធានពន្ធុសមុទ្រទាំងអស់ដែលប្រមូលបាន។

គ- របាយការណ៍ដែលរៀបរាប់លម្អិតអំពីតំបន់ភូមិសាស្ត្រដែលមានធនធានពន្ធុសមុទ្រ រួមទាំងព័ត៌មានអំពី [illegible]ទីតាំង រយៈបណ្តោយនិងជម្រៅនៃទីតាំងប្រមូលនិងវិសាលភាពនៃទីតាំងដែលមានបេកគំហើញដែលទទួលបានពី [illegible]។

ឃ- ការធ្វើបច្ចុប្បន្នកម្មចាំបាច់សម្រាប់ផែនការគ្រប់គ្រងទិន្នន័យដូចបានកំណត់ក្នុងកថាខណ្ឌ២(ញ-)



ឲ ㎘

៦- រដ្ឋភាគីទាំងអស់ត្រូវធានាថា សំណាកគំរូនៃធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដែលស្ថិតក្នុងកន្លែងផ្ទុកទិន្នន័យឬមូលដ្ឋានទិន្នន័យក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អាចត្រូវបានកំណត់អត្តសញ្ញាណថាមានប្រភពមកពីតំបន់ក្រៅដែនយុត្តាធិការជាតិស្របតាមការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ននិងក្នុងកម្រិតដែលអាចអនុវត្តបាន។

៧- រដ្ឋភាគីត្រូវធានាថា កន្លែងផ្ទុកទិន្នន័យ ក្នុងកម្រិតដែលអាចអនុវត្តបាននិងមូលដ្ឋានទិន្នន័យដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន រៀបចំបង្កើតរបាយការណ៍សរុបស្តីពីការទទួលធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុដែលភ្ជាប់ទៅឧបករណ៍កំណត់អត្តសញ្ញាណបណ្ដុំស្តង់ដា«BBNJ» របស់ខ្លួននៅរៀងរាល់ពីរឆ្នាំម្តង និងមានរបាយការណ៍ជាស្រេចសម្រាប់គណៈកម្មាធិការទទួលបន្ទុកការទទួលនិងការបែងចែកផលប្រយោជន៍ ដូចក្នុងមាត្រា១៥។

៨- នៅពេលណាដែលមានធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ហើយក្នុងករណីអាចអនុវត្តបានព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៅលើធនធានទាំងនោះគឺជាកម្មវត្ថុនៃការប្រើប្រាស់ រួមទាំងការធ្វើពាណិជ្ជកម្មដោយរូបវន្តបុគ្គលឬនីតិបុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួននោះ រដ្ឋភាគីត្រូវធានាថា ព័ត៌មានខាងក្រោមរួមទាំងឧបករណ៍កំណត់ពីអត្តសញ្ញាណបណ្ដុំស្តង់ដា«BBNJ» ប្រសិនបើមាននោះនឹងត្រូវបញ្ជូនទៅយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានភ្លាមបន្ទាប់ពីមានព័ត៌មានដូច្នេះ៖

ក- នៅពេលរកឃើញលទ្ធផលសម្រាប់ប្រើប្រាស់ ដូចជាការបោះពុម្ពផ្សាយ ប៉ាតង់ដែលបានប្រគល់ជូនប្រសិនបើអាចរកបាននិងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាននិងផលិតផលដែលត្រូវបានបង្កើតឡើង។

ខ- ក្នុងករណីរកបាននូវព័ត៌មានលម្អិតនៃការជូនដំណឹង ក្រោយការប្រមូលធនធានពន្ធុទៅឱ្យយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានដែលទាក់ទងនឹងធនធានពន្ធុសមុទ្រដែលជាកម្មវត្ថុនៃការប្រើប្រាស់។

គ- ក្នុងករណីដែលសំណាកគំរូដើមដែលជាកម្មវត្ថុនៃការប្រើប្រាស់ត្រូវបានរក្សាទុក។

ឃ- ទម្រង់គំរូ/ម៉ូដែលដែលត្រូវបានសន្មតសម្រាប់ការទទួលធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រដែលកំពុងត្រូវបានប្រើប្រាស់និងផែនការគ្រប់គ្រងទិន្នន័យសម្រាប់ការទទួលធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រនោះ។

ង- ប្រសិនបើមានបន្ទាប់ពីបានចូលទីផ្សារ ព័ត៌មានស្តីពីការលក់ផលិតផលពាក់ព័ន្ធនិងត្រូវការអភិវឌ្ឍបន្ថែមទៀត។

## មាត្រា១៣

## ចំណេះដឹងជាប្រពៃណីរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងធនធានពន្ធុសមុទ្រនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ

រដ្ឋភាគីទាំងអស់ត្រូវចាត់វិធានការតាមច្បាប់ រដ្ឋបាលឬគោលនយោបាយក្នុងករណីពាក់ព័ន្ធនិងសមស្រប ក្នុងគោលដៅដោយធានាថា ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធជាមួយធនធានពន្ធុសមុទ្រនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដែលកាន់កាប់ដោយជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ត្រូវបានប្រមូល/ប្រើប្រាស់តាមរយៈកិច្ចព្រមព្រៀងឬការយល់ព្រមដោយសេរីជាមុននិងមានព័ត៌មានគ្រប់គ្រាន់និងមានការចូលរួមពីជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន។ ការទទួលចំណេះដឹងបែបប្រពៃណីបែបនេះ អាចត្រូវបានសម្របសម្រួលដោយយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។ ការទទួលនិងការប្រើប្រាស់ចំណេះដឹងបែបប្រពៃណីនេះ ត្រូវធ្វើឡើងដោយផ្អែកលើលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា។

## មាត្រា១៤

## ការបែងចែកផលប្រយោជន៍ដោយយុត្តិធម៌និងសមធម៌

១- ផលប្រយោជន៍ដែលទទួលបានពីសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវបែងចែកដោយយុត្តិធម៌និងសមធម៌ ដូចមានចែងក្នុងផ្នែកនេះនិងជាការរួមចំណែកដល់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

២- ផលប្រយោជន៍មិនមែនជាប្រាក់ ត្រូវបែងចែកដោយអនុលោមតាមកិច្ចព្រមព្រៀងនេះក្នុងទម្រង់មួយចំនួននៃទម្រង់ផ្សេងៗទៀត ដូចតទៅ៖

ក- ការទទួលបានសំណាកគំរូនិងការប្រមូលសំណាកគំរូ ដោយអនុលោមតាមការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ន។

ខ- ការទទួលបានព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រស្របតាមការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ន។

គ- ការទទួលបានដោយចំហនៃទិន្នន័យវិទ្យាសាស្ត្រដែលអាចស្វែងរកបាន អាចចូលប្រើប្រាស់បាន អាចផ្លាស់ប្តូរគ្នាបាននិងអាចប្រើឡើងវិញបាន(FAIR) ដោយអនុលោមតាមការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ននិងការគ្រប់គ្រងទិន្នន័យដោយបើកចំហនិងប្រកបដោយការទទួលខុសត្រូវ។

ឃ- ព័ត៌មាននៅក្នុងសេចក្តីជូនដំណឹង រួមទាំងឧបករណ៍កំណត់អត្តសញ្ញាណបណ្តុំស្តង់ដា«BBNJ» ដែលបានចែងស្របតាមមាត្រា១២ នៅក្នុងទម្រង់ដែលអាចស្វែងរកបាននិងអាចចូលប្រើបានជាសាធារណៈ។

ង- ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ស្របតាមគំរូពាក់ព័ន្ធដែលមានចែងក្នុងផ្នែកទី៥ នៃកិច្ចព្រមព្រៀងនេះ។

ច- ការកសាងសមត្ថភាព រួមទាំងកម្មវិធីស្រាវជ្រាវហិរញ្ញប្បទាននិងឱកាសភាពជាដៃគូ ជាពិសេសឱកាសពាក់ព័ន្ធដោយផ្ទាល់និងសំខាន់ៗសម្រាប់អ្នកវិទ្យាសាស្ត្រនិងអ្នកស្រាវជ្រាវក្នុងគម្រោងស្រាវជ្រាវ ក៏ដូចជាគំនិតផ្តួចផ្តើមដែលមានការតាំងចិត្តខ្ពស់ ជាពិសេសសម្រាប់រដ្ឋកំពុងអភិវឌ្ឍ ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច។

ឆ- កិច្ចសហប្រតិបត្តិការបច្ចេកទេសនិងវិទ្យាសាស្ត្រដែលបានលើកកម្ពស់ ជាពិសេសជាមួយអ្នកវិទ្យាសាស្ត្រមកពីរដ្ឋកំពុងអភិវឌ្ឍនិងស្ថាប័នវិទ្យាសាស្ត្រក្នុងរដ្ឋកំពុងអភិវឌ្ឍទាំងនេះ។

ឈ- ទម្រង់ផ្សេងៗទៀតនៃផលប្រយោជន៍ដែលកំណត់ដោយសន្និសីទកំពូលបណ្តាភាគី ដោយផ្តោតការយកចិត្តទុកដាក់លើអនុសាសន៍នៃគណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ដែលបានបង្កើតឡើងក្នុងមាត្រា១៥។

៣- រដ្ឋភាគីត្រូវចាត់វិធានការតាមច្បាប់ រដ្ឋបាលឬគោលនយោបាយចាំបាច់ ដើម្បីធានាថា ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងឧបករណ៍កំណត់អត្តសញ្ញាណបណ្តុំស្តង់ដា«BBNJ» របស់ធនធានពន្ធុសមុទ្រទាំងនោះផង ដែលត្រូវប្រើប្រាស់ដោយរូបវន្តបុគ្គលឬនីតិបុគ្គល នៅក្រោមយុត្តាធិការរបស់ខ្លួន ត្រូវដាក់ក្នុងកន្លែងផ្ទុកទិន្នន័យនិងមូលដ្ឋានទិន្នន័យដែលអាចចូលប្រើបានជាសាធារណៈ រក្សាទុកទាំងនៅថ្នាក់ជាតិនិងអន្តរជាតិ ដោយមិនលើសពី៣(បី)ឆ្នាំ ពីការចាប់ផ្តើមប្រើប្រាស់ឬនៅពេលមានធនធានពន្ធុទាំងនោះភ្លាម ដោយផ្អែកតាមការអនុវត្តជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ន។

៤- ការទទួលបានធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ នៅក្នុងកន្លែងផ្ទុកនិងមូលដ្ឋានទិន្នន័យដែលស្ថិតក្រោមយុត្តាធិការរបស់រដ្ឋភាគី អាចស្ថិតក្រោម [illegible]សម្បយោគផលដូចខាងក្រោម៖

ក- តម្រូវការដើម្បីរក្សាគុណតម្លៃមុខងាររូបវន្តនៃធនធានពន្ធុសមុទ្រ។

ខ- ការចំណាយសមហេតុផលទាក់ទងនឹងការថែរក្សាធនាគារពន្ធុពាក់ព័ន្ធ កន្លែងផ្ទុកទិន្នន័យឬមូលដ្ឋានទិន្នន័យដែលផ្ទុកសំណាកគំរូ ទិន្នន័យ ឬព័ត៌មាន។

គ- ការចំណាយសមស្របទាក់ទងនឹងការឱ្យប្រមូលធនធានពន្ធុសមុទ្រ ទិន្នន័យ ឬព័ត៌មាន។

ឃ- លក្ខខណ្ឌសមស្របផ្សេងៗទៀត ស្របតាមគោលដៅនៃកិច្ចព្រមព្រៀងនេះនិងឱកាសសម្រាប់ការប្រមូលនោះ ដោយផ្អែកលើលក្ខខណ្ឌយុត្តិធម៌និងអំណោយផលបំផុត រួមទាំងលក្ខខណ្ឌសម្បទាននិងអនុគ្រោះ អាចត្រូវបានផ្តល់ជូនអ្នកស្រាវជ្រាវនិងស្ថាប័នស្រាវជ្រាវមកពីរដ្ឋកំពុងអភិវឌ្ឍ។

៥- ផលប្រយោជន៍ជាសាច់ប្រាក់បានពីការប្រើប្រាស់ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងការធ្វើពាណិជ្ជកម្មផង ត្រូវបែងចែកដោយស្មើភាពនិងសមធម៌ តាមរយៈយន្តការហិរញ្ញវត្ថុដូចដែលមានចែងក្នុងមាត្រា៥២ សម្រាប់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៦- បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន រដ្ឋភាគីអភិវឌ្ឍត្រូវបរិច្ចាគថវិកាប្រចាំឆ្នាំចូលក្នុងមូលនិធិពិសេសដូចដែលមានចែងក្នុងមាត្រា៥២។ អត្រានៃការបរិច្ចាគរបស់រដ្ឋភាគីមួយ គឺ៥០(ហាសិប)ភាគរយនៃវិភាគទានដែលបានវាយតម្លៃរបស់រដ្ឋភាគីនោះ ចំពោះថវិកាដែលបានអនុម័តដោយសន្និសីទកំពូលបណ្តាភាគី ដូចមានចែងក្នុងមាត្រា៤៧ កថាខណ្ឌ៦(ង-)។ ការបង់ប្រាក់នេះនឹងបន្តរហូតដល់មានការសម្រេចជាថ្មីដោយសន្និសីទកំពូលបណ្តាភាគីដូចមានកំណត់ក្នុងកថាខណ្ឌ៧ខាងក្រោម។

៧- សន្និសីទកំពូលបណ្តាភាគីត្រូវសម្រេចលើទម្រង់បែបបទ សម្រាប់ការបែងចែកផលប្រយោជន៍ជាសាច់ប្រាក់ពីការប្រើប្រាស់ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដោយយកចិត្តទុកដាក់លើអនុសាសន៍របស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ដូចមានចែងក្នុងមាត្រា១៥។ ប្រសិនបើកិច្ចខិតខំប្រឹងប្រែងទាំងអស់នឹងឈានដល់ការឯកភាព ត្រូវបានប្រើប្រាស់អស់ហើយ ការសម្រេចចិត្តមួយនឹងត្រូវបានអនុម័តដោយរដ្ឋភាគីភាគច្រើនចំនួនបីភាគបួនដែលមានវត្តមាននិងមានសិទ្ធិបោះឆ្នោត។ ការទូទាត់ត្រូវធ្វើឡើងតាមរយៈមូលនិធិពិសេសដូចមានចែងក្នុងមាត្រា៥២។

ទម្រង់បែបបទមាន ដូចតទៅ៖

ក- ការទូទាត់តាមដំណាក់កាលសំខាន់ៗ។

ខ- ការទូទាត់ឬការរួមចំណែកដែលទាក់ទងនឹងការធ្វើពាណិជ្ជកម្មនៃផលិតផល រួមទាំងការទូទាត់គិតជាភាគរយនៃប្រាក់ចំណូលបានពីការលក់ផលិតផល។

គ- ថ្លៃសេវាតាមលំដាប់ ដែលត្រូវបង់តាមកាលកំណត់ដោយផ្អែកលើសំណុំសូចនាករចម្រុះដែលវាស់វែងកម្រិតសរុបនៃសកម្មភាពដោយរដ្ឋភាគីមួយ។

ឃ- ទម្រង់ផ្សេងៗទៀត ដូចដែលបានសម្រេចដោយសន្និសីទកំពូលបណ្តាភាគីដោយផ្អែកលើអនុសាសន៍នានារបស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍។

៨- រដ្ឋភាគីមួយអាចធ្វើសេចក្តីប្រកាសក្នុងពេលដែលសន្និសីទកំពូលបណ្តាភាគីអនុម័តទម្រង់បែបបទដោយមតិភាគច្រើន ទម្រង់បែបបទទាំងនោះមិនត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីក្នុងរយៈពេលរហូតដល់៤(បួន)ឆ្នាំ ដើម្បីទុកពេលវេលាសម្រាប់អនុវត្ត។ រដ្ឋភាគីដែលធ្វើសេចក្តីប្រកាសបែបនេះត្រូវបន្តធ្វើការទូទាត់ដូចមានចែងក្នុងកថាខណ្ឌ៦ ខាងលើ រហូតដល់ទម្រង់បែបបទថ្មីចូលជាធរមាន។

៩- ក្នុងការធ្វើសេចក្ដីសម្រេចលើទម្រង់បែបបទនៃការបែងចែកផលប្រយោជន៍ជាសាច់ប្រាក់ ពីការប្រើប្រាស់ព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ តាមកថាខណ្ឌ៧ខាងលើ សន្និសីទកំពូលបណ្ដាភាគី ត្រូវយកចិត្តទុកដាក់លើអនុសាសន៍របស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ ដោយទទួលស្គាល់ថា ទម្រង់បែបបទទាំងនេះគួរមានការគាំទ្រនិងអាចសម្របខ្លួនទៅវិញទៅមក ទៅនឹងលិខិតូបករណ៍ទទួលនិងបែងចែកផលប្រយោជន៍ផ្សេងទៀត។

១០- ដោយពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ដែលបានបង្កើតឡើងក្នុងមាត្រា១៥ សន្និសីទកំពូលបណ្ដាភាគីនឹងពិនិត្យនិងវាយតម្លៃមួយឆ្នាំពីរដង ផលប្រយោជន៍ជាសាច់ប្រាក់ដែលបានពីការប្រើប្រាស់ធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថល អំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។ ការត្រួតពិនិត្យវាយតម្លៃលើកដំបូងត្រូវធ្វើឡើងមិនលើសពី៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ ការពិនិត្យវាយតម្លៃនេះត្រូវរួមបញ្ចូលនូវការពិចារណាលើការរួមចំណែកប្រចាំឆ្នាំដូចដែលមានចែងក្នុងកថាខណ្ឌ៦ខាងលើ។

១១- រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ រដ្ឋបាលឬគោលនយោបាយ ក្នុងពេលសមស្របណាមួយក្នុងគោលដៅ ដើម្បីធានាផលប្រយោជន៍ដែលកើតចេញពីសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថល អំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដោយរូបវន្តបុគ្គលឬនីតិបុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ត្រូវបានបែងចែកដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

## មាត្រា១៥

## គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍

១- គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ ត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។ ក្នុងចំណោមកិច្ចការផ្សេងៗគណៈកម្មាធិការនេះនឹងបំពេញការងារក្នុងការបង្កើតគោលការណ៍ណែនាំសម្រាប់ការបែងចែកផលប្រយោជន៍ ស្របតាមមាត្រា១៤ ដោយមានតម្លាភាពនិងធានាដល់ការបែងចែកផលប្រយោជន៍ជាសាច់ប្រាក់និងមិនមែនជាសាច់ប្រាក់ ប្រកបដោយសមធម៌និងយុត្តិធម៌។

២- គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ត្រូវមានសមាជិកចំនួន១៥(ដប់ប្រាំ)រូប ដែលមានគុណវុឌ្ឍិសមស្របតាមវិស័យពាក់ព័ន្ធ ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវមុខងាររបស់គណៈកម្មាធិការ។ សមាជិកត្រូវទទួលបានការតែងតាំងដោយរដ្ឋភាគីនិងត្រូវបានជ្រើសរើសដោយសន្និសីទកំពូលបណ្ដាភាគី ដោយយកចិត្តទុកដាក់លើសមតុល្យយេនឌ័រនិងរបាយភូមិសាស្ត្រ ប្រកបដោយសមធម៌និងមានភាពជាតំណាងក្នុងគណៈកម្មាធិការមកពីរដ្ឋកំពុងអភិវឌ្ឍ រួមទាំងមកពីប្រទេសអភិវឌ្ឍតិចតួច រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ និងពីប្រទេសកំពុងអភិវឌ្ឍដែលមិនស្ថិតនៅជាប់នឹងសមុទ្រ។ ការពិពណ៌នាពីលក្ខខណ្ឌការងារនិងទម្រង់បែបបទសម្រាប់ប្រតិបត្តិការរបស់គណៈកម្មាធិការត្រូវកំណត់ដោយសន្និសីទកំពូលបណ្ដាភាគី។

៣- គណៈកម្មាធិការអាចផ្ដល់អនុសាសន៍ដល់សន្និសីទកំពូលបណ្ដាភាគីអំពីការងារនិងបញ្ហាទាក់ទងនឹងផ្នែកនេះរួមទាំងការងារនិងការប្រឈមខាងក្រោម៖

ក- គោលការណ៍ណែនាំឬក្រមសីលធម៌សម្រាប់សកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដែលមានកំណត់ក្នុងផ្នែកនេះ។

ខ- តាមដានការអនុវត្តសេចក្ដីសម្រេចដែលបានធ្វើឡើងស្របតាមផ្នែកនេះ។

គ- អត្រាឬយន្តការសម្រាប់បែងចែកផលប្រយោជន៍ជាសាច់ប្រាក់ស្របតាមមាត្រា១៤។

ឃ- ការងារ/ការប្រឈមក្នុងផ្នែកនេះដែលទាក់ទងនឹងយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

ង- ការងារ/ការប្រឈមក្នុងផ្នែកនេះដែលទាក់ទងនឹងយន្តការហិរញ្ញវត្ថុដូចមានចែងក្នុងមាត្រា៥២។

ច- ការងារនិងការប្រឈមផ្សេងៗទៀតក្នុងផ្នែកនេះ គឺសន្និសីទកំពូលបណ្តាភាគីអាចស្នើសុំឱ្យគណៈកម្មការទទួលនិងបែងចែកផលប្រយោជន៍ដើម្បីដោះស្រាយ។

៤- នៅក្នុងកិច្ចព្រមព្រៀងនេះ រដ្ឋភាគីនីមួយៗត្រូវផ្តល់ព័ត៌មានដែលចាំបាច់ដល់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ តាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ដែលរួមមាន៖

ក- វិធានការច្បាប់ រដ្ឋបាល និងគោលនយោបាយស្តីពីការទទួលនិងការបែងចែកផលប្រយោជន៍។

ខ- ព័ត៌មានទំនាក់ទំនងនិងព័ត៌មានពាក់ព័ន្ធផ្សេងទៀតអំពីជនបង្គោលថ្នាក់ជាតិ។

គ- ព័ត៌មានចាំបាច់ផ្សេងៗទៀត ស្របតាមសេចក្តីសម្រេច ដែលបានធ្វើឡើងដោយសន្និសីទកំពូលបណ្តាភាគី។

៥- គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍អាចពិគ្រោះយោបល់និងសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាន ដែលទាក់ទងនឹងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ អំពីសកម្មភាព ក្រោមអាណត្តិរបស់ខ្លួន រួមទាំងការបែងចែកផលប្រយោជន៍ ការប្រើប្រាស់ព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រ ការអនុវត្តល្អបំផុតនូវឧបករណ៍និងអភិក្រមក្នុងការគ្រប់គ្រងទិន្នន័យ និងមេរៀនជាបទពិសោធដទៃទៀត។

៦- គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ អាចផ្តល់អនុសាសន៍ដល់សន្និសីទកំពូលបណ្តាភាគីទាក់ទងនឹងព័ត៌មានដែលទទួលបានក្នុងកថាខណ្ឌ៥ខាងលើ។

### មាត្រា១៦

### ការត្រួតពិនិត្យនិងតម្លាភាព

១- ការត្រួតពិនិត្យនិងតម្លាភាពនៃសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវទទួលបានតាមរយៈការជូនដំណឹងដល់យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ដោយប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណបណ្តុំស្តង់ដា«BBNJ» ស្របតាមផ្នែកនេះនិងនីតិវិធីដែលបានអនុម័តដោយសន្និសីទកំពូលបណ្តាភាគី តាមអនុសាសន៍របស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍។

២- រដ្ឋភាគីត្រូវដាក់របាយការណ៍ក្នុងរយៈពេលទៀងទាត់ទៅគណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ស្តីពីការអនុវត្តរបស់ខ្លួននៃបទប្បញ្ញត្តិនៅក្នុងផ្នែកនេះនូវសកម្មភាពទាក់ទងនឹងធនធានពន្ធុសមុទ្រនិងព័ត៌មានឌីជីថលអំពីតំណលំដាប់ពន្ធុនៃធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិនិងការបែងចែកផលប្រយោជន៍ ស្របតាមផ្នែកនេះ។

៣- គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ត្រូវរៀបចំរបាយការណ៍ ដោយផ្អែកលើព័ត៌មានដែលទទួលបានតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន នឹងផ្ញើទៅរដ្ឋភាគីដើម្បីផ្តល់មតិយោបល់កែលម្អ។ គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ត្រូវបញ្ជូនរបាយការណ៍ រួមទាំងមតិយោបល់ដែលទទួលបានសម្រាប់ការពិចារណាក្នុងសន្និសីទកំពូលបណ្តាភាគី។ សន្និសីទកំពូលបណ្តាភាគី ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មាធិការទទួលនិងបែងចែកផលប្រយោជន៍ អាចកំណត់គោលការណ៍ណែនាំសមស្របសម្រាប់អនុវត្តមាត្រានេះ ដែលត្រូវពិចារណាលើសមត្ថភាពជាតិនិងកាលៈទេសៈរបស់រដ្ឋភាគី។

## ផ្នែកទី៣

## វិធានការដូចជាឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ

### មាត្រា១៧

### គោលដៅ

ផ្នែកនេះមានគោលដៅដើម្បីៈ

ក- អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវតំបន់ដែលទាមទារឱ្យមានការការពារ រួមទាំងតាមរយៈការបង្កើតឱ្យមានប្រព័ន្ធទូលំទូលាយលើការគ្រប់គ្រងឧបករណ៍តាមតំបន់ ដែលមានបណ្ដាញតំណាងប្រព័ន្ធអេកូឡូស៊ីនិងបណ្ដាញតភ្ជាប់យ៉ាងល្អនៃតំបន់ការពារធម្មជាតិសមុទ្រ។

ខ- ពង្រឹងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលក្នុងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ក្នុងចំណោមរដ្ឋភាគី លិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ ព្រមទាំងស្ថាប័ន តាមវិស័យពាក់ព័ន្ធនិងនៅថ្នាក់អនុតំបន់ តំបន់ និងថ្នាក់សាកល។

គ- ការពារ អភិរក្ស ស្ដារ និងរក្សាជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ក្នុងគោលដៅលើកកម្ពស់ផលិតភាព សុខភាពរបស់ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងពង្រឹងភាពធន់នឹងបញ្ហាបរិស្ថាន រួមទាំងបញ្ហាដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ អាស៊ីដកម្មមហាសមុទ្រ និងការបំពុលសមុទ្រ។

ឃ- គាំទ្រដល់សន្តិសុខស្បៀងនិងគោលដៅសេដ្ឋកិច្ចសង្គមផ្សេងទៀត រួមទាំងការការពារតម្លៃវប្បធម៌។

ង- គាំទ្រដល់រដ្ឋភាគីកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសកំពុងអភិវឌ្ឍមិនជាប់ឆ្នេរសមុទ្ររដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ រដ្ឋជាប់ឆ្នេរសមុទ្រនៅទ្វីបអាហ្វ្រិក រដ្ឋប្រជុំកោះនិងប្រទេសកំពុងអភិវឌ្ឍមានចំណូលមធ្យម ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗ តាមរយៈការកសាងសមត្ថភាព ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រក្នុងការអភិវឌ្ឍ ការអនុវត្ត ការត្រួតពិនិត្យ ការគ្រប់គ្រងនិងការពង្រឹងឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ។

### មាត្រា១៨

### តំបន់សម្រាប់ការអនុវត្ត

ការបង្កើតឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ មិនត្រូវរាប់បញ្ចូលតំបន់ណាមួយនៅក្នុងដែនយុត្តាធិការជាតិនិងមិនត្រូវពឹងផ្អែកលើមូលដ្ឋាននៃការអះអាងឬបដិសេធការទាមទារណាមួយចំពោះអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាពឬយុត្តាធិការ រួមទាំងទាក់ទងទៅនឹងជម្លោះពាក់ព័ន្ធនឹងការអះអាងឬការទាមទារនោះឡើយ។ សន្និសីទកំពូលបណ្ដាភាគីមិនត្រូវពិចារណាលើសំណើសុំការសម្រេច ដើម្បីបង្កើតឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ហើយទោះជាយ៉ាងណាក្ដី សំណើទាំងនោះមិនត្រូវបានបកស្រាយថាជាការទទួលស្គាល់ឬការមិនទទួលស្គាល់លើការទាមទារណាមួយចំពោះអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការឡើយ។

### មាត្រា១៩

### សំណើ

[illegible] សំណើ[illegible]ទាក់ទងនឹងការបង្កើតឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រនៅក្នុង[illegible]ជូនដោយរដ្ឋភាគីនីមួយៗឬជាសមូហភាពទៅកាន់លេខាធិការដ្ឋាន។

២- រដ្ឋភាគីត្រូវសហការនិងពិគ្រោះយោបល់ តាមភាពសមស្រប ជាមួយរដ្ឋភាគីពាក់ព័ន្ធ រួមទាំងរដ្ឋនិងស្ថាប័នតាមវិស័យនិងនៅថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់សាកល ព្រមទាំងសង្គមស៊ីវិល សហគមន៍វិទ្យាសាស្ត្រ វិស័យឯកជន ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំសំណើ ដូចមានចែងក្នុងផ្នែកនេះ។

៣- សំណើនឹងត្រូវបង្កើតឡើង ដោយផ្អែកលើវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រដែលមាននិងល្អបំផុត បើរកបានចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ដោយត្រូវយកចិត្តទុកដាក់លើអភិក្រមដោយមានការប្រុងប្រយ័ត្នជាមុននិងអភិក្រមប្រព័ន្ធអេកូឡូស៊ី។

៤- សំណើទាក់ទងនឹងតំបន់ដែលបានកំណត់រួច ត្រូវរួមបញ្ចូលធាតុសំខាន់ៗដូចខាងក្រោម៖

ក- ការពិពណ៌នាពីលក្ខណៈភូមិសាស្ត្រឬរូបន្តនៃតំបន់ដែលជាកម្មវត្ថុនៃសំណើដោយយោងទៅលើលក្ខណវិនិច្ឆ័យដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ I។

ខ- ព័ត៌មានអំពីលក្ខណវិនិច្ឆ័យណាមួយដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ I ក៏ដូចជាលក្ខណវិនិច្ឆ័យណាមួយដែលអាចត្រូវបានបង្កើតឡើងនិងកែសម្រួលបន្ថែម ដោយអនុលោមតាមកថាខណ្ឌ៥ខាងក្រោមដូចដែលបានអនុវត្តក្នុងការកំណត់អត្តសញ្ញាណតំបន់។

គ- សកម្មភាពរបស់មនុស្សនៅក្នុងតំបន់ រួមទាំងការប្រើប្រាស់ដោយជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន និងផលប៉ះពាល់ជាសក្តានុពលពីការប្រើប្រាស់នោះ ប្រសិនបើមាន។

ឃ- ការពិពណ៌នាអំពីស្ថានភាពនៃបរិស្ថានសមុទ្រនិងជីវៈចម្រុះនៅក្នុងតំបន់ដែលបានកំណត់។

ង- ការពិពណ៌នាអំពីការអភិរក្សនិងនៅពេលសមស្រប គោលដៅប្រើប្រាស់ប្រកបដោយចីរភាពដែលនឹងត្រូវអនុវត្តចំពោះតំបន់នោះ។

ច- សេចក្តីព្រាងផែនការគ្រប់គ្រងដែលបានស្នើឡើង ដោយគ្របដណ្តប់លើវិធានការដែលបានស្នើឡើងនិងបង្ហាញពីសកម្មភាពត្រួតពិនិត្យ ស្រាវជ្រាវនិងវាយតម្លៃ ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់។

ឆ- រយៈពេលសម្រាប់តំបន់និងវិធានការដែលបានស្នើឡើង ប្រសិនបើមាន។

ជ- ព័ត៌មានស្តីពីការពិគ្រោះយោបល់ណាមួយដែលធ្វើឡើងជាមួយរដ្ឋ រួមទាំងរដ្ឋមានសមុទ្រនិង/ឬស្ថាប័នពាក់ព័ន្ធតាមវិស័យនិងនៅថ្នាក់អនុតំបន់ តំបន់ និងថ្នាក់សាកល ប្រសិនបើមាន។

ឈ- ព័ត៌មានអំពីឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលត្រូវបានអនុវត្តតាមឧបករណ៍និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនិងស្ថាប័នពាក់ព័ន្ធតាមវិស័យនិងនៅថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់សាកល។

ញ- ធាតុចូលពាក់ព័ន្ធផ្នែកវិទ្យាសាស្ត្រនិងបើអាចរកបាននូវចំណេះដឹងជាប្រពៃណីរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន។

៥- លក្ខណវិនិច្ឆ័យដែលបានស្នើឡើងសម្រាប់ការកំណត់អត្តសញ្ញាណផ្នែកទាំងនេះ ត្រូវរាប់បញ្ចូលផ្នែកដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ I ក្នុងករណីមានការពាក់ព័ន្ធ ហើយអាចត្រូវបានបង្កើតនិងកែសម្រួលបន្ថែមទៀត ក្នុងករណីចាំបាច់ដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសសម្រាប់ការពិចារណានិងអនុម័តដោយសន្និសីទកំពូលបណ្តាភាគី។

៦- លក្ខខណ្ឌតម្រូវផ្សេងៗទៀតទាក់ទងនឹងខ្លឹមសារនៃសំណើ រួមទាំងទម្រង់បែបបទសម្រាប់ការអនុវត្តលក្ខណវិនិច្ឆ័យដែលបានស្នើឡើង ដូចមានចែងក្នុងកថាខណ្ឌ៥ខាងលើនិងការណែនាំអំពីសំណើដែលបានបញ្ជាក់ក្នុងកថាខណ្ឌ៤(ខ)ខាងលើ ត្រូវបញ្ជាក់ដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស តាមការចាំបាច់ សម្រាប់ការពិចារណានិងអនុម័តដោយសន្និសីទកំពូលបណ្តាភាគី។

## មាត្រា២០

## ការផ្សព្វផ្សាយនិងការពិនិត្យបឋមនៃសំណើ

បន្ទាប់ពីទទួលបានសំណើជាលាយលក្ខណ៍អក្សរហើយ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយសំណើនេះជាសាធារណៈ ហើយបញ្ជូនសំណើនោះទៅអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសដើម្បីពិនិត្យវាយតម្លៃបឋម។ គោលដៅនៃការត្រួតពិនិត្យវាយតម្លៃនេះគឺដើម្បីបញ្ជាក់ថាសំណើនោះមានព័ត៌មានតាមលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងមាត្រា១៩ រួមទាំងលក្ខណៈវិនិច្ឆ័យគោល ដែលបានពិពណ៌នានៅក្នុងផ្នែកនេះនិងនៅក្នុងឧបសម្ព័ន្ធ។ លទ្ធផលនៃការពិនិត្យវាយតម្លៃនោះត្រូវផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបញ្ជូនទៅកាន់អ្នកស្នើសុំដោយលេខាធិការដ្ឋាន។ អ្នកស្នើសុំត្រូវបញ្ជូនសំណើត្រឡប់ទៅលេខាធិការដ្ឋានឡើងវិញ ដោយធ្វើការពិចារណាលើការត្រួតពិនិត្យវាយតម្លៃបឋមដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស។ លេខាធិការដ្ឋាន ត្រូវជូនដំណឹងដល់រដ្ឋភាគីនានានិងផ្សព្វផ្សាយសំណើដែលបានបញ្ជូនឡើងវិញនេះជាសាធារណៈ និងសម្របសម្រួលការពិគ្រោះយោបល់ ស្របតាមមាត្រា២១។

## មាត្រា២១

## ការពិគ្រោះយោបល់និងការវាយតម្លៃសំណើ

១- ការពិគ្រោះយោបល់លើសំណើដែលបញ្ជូនមកដោយស្របតាមមាត្រា១៩ ត្រូវតែមានលក្ខណៈបរិយាបន្ន តម្លាភាពនិងបើកចំហ ចំពោះរដ្ឋភាគីពាក់ព័ន្ធទាំងអស់ រួមទាំងជនជាតិដើមភាគតិចនិងស្ថាប័នតាមវិស័យនិងនៅថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងសាកល ព្រមទាំងសង្គមស៊ីវិល សហគមន៍វិទ្យាសាស្ត្រ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។

២- លេខាធិការដ្ឋានត្រូវសម្របសម្រួលឱ្យមានការពិគ្រោះយោបល់និងប្រមូលធាតុចូល ដូចខាងក្រោម៖

ក- រដ្ឋ ជាពិសេសរដ្ឋជាប់ឆ្នេរសមុទ្រ នឹងទទួលបានការជូនដំណឹងនិងស្នើសុំឱ្យបញ្ជូននូវព័ត៌មានដូចខាងក្រោមក្នុងចំណោមព័ត៌មានដទៃទៀត៖

១- ទិដ្ឋភាពទូទៅស្តីពីគុណសម្បត្តិនិងវិសាលភាពភូមិសាស្ត្រនៃសំណើ។

២- ធាតុចូលផ្នែកវិទ្យាសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

៣- ព័ត៌មានទាក់ទងនឹងវិធានការឬសកម្មភាពជាធរមាន នៅក្នុងតំបន់ជាប់ឬពាក់ព័ន្ធក្នុងដែនសមត្ថកិច្ចជាតិ និងក្រៅដែនយុត្តាធិការជាតិ។

៤- ទិដ្ឋភាពជាសក្តានុពលនៃសំណើសម្រាប់តំបន់នានាក្នុងយុត្តាធិការជាតិ។

៥- ព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

ខ- អង្គភាពពាក់ព័ន្ធនៃអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ នឹងត្រូវទទួលបានការជូនដំណឹងនិងស្នើសុំឱ្យបញ្ជូននូវព័ត៌មានដូចខាងក្រោមក្នុងចំណោមព័ត៌មានដទៃទៀត៖

១- ទិដ្ឋភាពទូទៅស្តីពីគុណសម្បត្តិនៃសំណើ។

២- ធាតុចូលផ្នែកវិទ្យាសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

៣- ព័ត៌មានទាក់ទងនឹងវិធានការដែលមានស្រាប់ដែលត្រូវបានអនុម័ត ដោយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យសម្រាប់តំបន់ពាក់ព័ន្ធឬសម្រាប់តំបន់ជិតៗនោះ។

៤- ទិដ្ឋភាពទាក់ទងនឹងវិធានការនិងសមាសធាតុផ្សេងៗទៀតសម្រាប់សេចក្តីព្រាងផែនការគ្រប់គ្រងដែលបានដាក់នៅក្នុងសំណើស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គភាពនោះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៥- ទិដ្ឋភាពទាក់ទងនឹងវិធានការបន្ថែមពាក់ព័ន្ធដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារ។

៦- ព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

គ- ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលមានចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ សហគមន៍វិទ្យាសាស្ត្រ សង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធផ្សេងទៀតត្រូវបានស្នើសុំឱ្យបញ្ជូនព័ត៌មានក្នុងចំណោមព័ត៌មានផ្សេងៗទៀតដូចខាងក្រោម៖

១- ទិដ្ឋភាពអំពីគុណសម្បត្តិនៃសំណើ។

២- ធាតុចូលផ្នែកវិទ្យាសាស្ត្រពាក់ព័ន្ធផ្សេងៗ។

៣- ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន។

៤- ព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

៣- ការរួមចំណែកដែលទទួលបានស្របតាមកថាខណ្ឌ២ខាងលើ ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយលេខាធិការដ្ឋាន។

៤- ក្នុងករណីវិធានការដែលបានស្នើឡើងប៉ះពាល់ដល់តំបន់ដែលមានការហ៊ុមព័ទ្ធទាំងស្រុងដោយតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋ អ្នកស្នើសុំត្រូវ៖

ក- ធ្វើការពិគ្រោះយោបល់តាមចំណុចដៅនិងបុរេសកម្ម ក្នុងនោះរួមទាំងការជូនដំណឹងជាមុនដល់រដ្ឋសាមី។

ខ- ពិចារណាលើទស្សនៈនិងមតិយោបល់របស់រដ្ឋសាមី លើវិធានការដែលបានស្នើឡើង ហើយផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ជាពិសេសចំពោះទស្សនៈនិងយោបល់ទាំងនោះ ហើយក្នុងករណីសមស្រប ត្រូវពិនិត្យឡើងវិញនូវវិធានការដែលបានស្នើឡើង។

៥- អ្នកស្នើសុំត្រូវពិចារណាលើការរួមចំណែកដែលទទួលបានក្នុងអំឡុងពេលពិគ្រោះយោបល់ ក៏ដូចជាទស្សនៈនិងព័ត៌មានពីអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ហើយក្នុងករណីសមស្រប ត្រូវពិនិត្យឡើងវិញនូវសំណើនេះតាមឬឆ្លើយតបទៅនឹងការរួមចំណែកសំខាន់ៗដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងសំណើនេះ។

៦- រយៈពេលពិគ្រោះយោបល់ត្រូវមានកំណត់ពេលវេលា។

៧- សំណើដែលបានកែសម្រួលត្រូវដាក់ជូនអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដែលត្រូវវាយតម្លៃសំណើនិងផ្តល់អនុសាសន៍ដល់សន្និសីទកំពូលបណ្តាភាគី។

៨- ទម្រង់បែបបទសម្រាប់ដំណើរការពិគ្រោះយោបល់និងការវាយតម្លៃ ក្នុងនោះរួមទាំងរយៈពេល នឹងត្រូវបញ្ជាក់បន្ថែមដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ក្នុងករណីមានភាពចាំបាច់ នៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ដើម្បីពិចារណានិងអនុម័តដោយសន្និសីទកំពូលបណ្តាភាគី ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ។

## មាត្រា២២

## ការបង្កើតឧបករណ៍គ្រប់គ្រងតាមតំបន់ ក្នុងនោះរួមទាំងតំបន់ការពារធម្មជាតិសមុទ្រ

១- សន្និសីទកំពូលបណ្តាភាគី ដោយផ្អែកលើមូលដ្ឋាននៃសំណើសុំចុងក្រោយនិងសេចក្តីព្រាងផែនការគ្រប់គ្រង ត្រូវយកចិត្តទុកដាក់លើការចូលរួមចំណែកនិងផ្តល់ធាតុចូលផ្នែកវិទ្យាសាស្ត្រដែលទទួលបានក្នុងដំណើរការពិគ្រោះយោបល់ដែលបានបង្កើតឡើងក្នុងផ្នែកនេះនិងការណែនាំនិងអនុសាសន៍ផ្នែកវិទ្យាសាស្ត្ររបស់អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស៖

ក- ត្រូវធ្វើការសម្រេចលើការបង្កើតឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រនិងវិធានការពាក់ព័ន្ធ។

ខ- អាចធ្វើការសម្រេចលើវិធានការដែលត្រូវគ្នានឹងសេចក្ដីសម្រេចដែលបានអនុម័តដោយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ដោយសហការនិងសម្របសម្រួលជាមួយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធទាំងនោះ។

គ- នៅពេលវិធានការដែលបានស្នើឡើង ស្ថិតនៅក្នុងសមត្ថកិច្ចនៃអង្គភាពពាក់ព័ន្ធតាមវិស័យនិងថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬថ្នាក់សាកល គឺអាចផ្ដល់អនុសាសន៍ដល់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះនិងដល់អង្គភាពពាក់ព័ន្ធតាមវិស័យនិងថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់សាកល ដើម្បីជំរុញការអនុម័តវិធានការពាក់ព័ន្ធ តាមរយៈអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ ស្របតាមអាណត្តិរៀងៗខ្លួន។

២- ក្នុងការធ្វើសេចក្ដីសម្រេចនៅក្រោមមាត្រានេះ សន្និសីទកំពូលបណ្ដាភាគីត្រូវគោរពសមត្ថកិច្ចនិងមិនធ្វើឱ្យប៉ះពាល់ដល់អង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៣- សន្និសីទកំពូលបណ្ដាភាគីត្រូវធ្វើការរៀបចំឱ្យមានការពិគ្រោះយោបល់យ៉ាងទៀងទាត់ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលជាមួយនិងក្នុងចំណោមលិខិតូបករណ៍នីត្យានុកូលពាក់ព័ន្ធនិងក្របខ័ណ្ឌការងារ និងស្ថាប័នពាក់ព័ន្ធតាមវិស័យនិងនៅថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់សាកល ទាក់ទងនឹងឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ក៏ដូចជាការសម្របសម្រួលទាក់ទងនឹងវិធានការពាក់ព័ន្ធដែលបានអនុម័តក្រោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនិងក្រោមការសម្របសម្រួលដោយស្ថាប័នទាំងនោះ។

៤- នៅពេលមានតម្រូវការឱ្យសម្រេចគោលដៅនិងតម្រូវការអនុវត្តផ្នែកនេះ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងការសម្របសម្រួលបន្ថែមទៀតទាក់ទងនឹងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិនោះ សន្និសីទកំពូលបណ្ដាភាគីអាចពិចារណានិងជាកម្មវត្ថុនៃកថាខណ្ឌ១ និង២ខាងលើ ក្នុងពេលសមស្របណាមួយ អាចសម្រេចបង្កើតយន្តការទាក់ទងនឹងឧបករណ៍គ្រប់គ្រងតាមតំបន់ជាធរមាន ក្នុងនោះរួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលអនុម័តដោយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៥- សេចក្ដីសម្រេចនិងអនុសាសន៍នានាដែលបានអនុម័តដោយសន្និសីទកំពូលបណ្ដាភាគី ផ្អែកតាមផ្នែកនេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃវិធានការដែលបានអនុម័តនៅក្នុងផ្នែកនានាក្នុងយុត្តាធិការជាតិ ហើយត្រូវធ្វើឡើងដោយយកចិត្តទុកដាក់លើសិទ្ធិនិងភារកិច្ចរបស់រដ្ឋទាំងអស់ ស្របតាមអនុសញ្ញា។ ក្នុងករណីវិធានការនានាដែលបានស្នើឡើងនៅក្រោមផ្នែកនេះ អាចនឹងប៉ះពាល់ដល់ឬអាចរំពឹងថានឹងប៉ះពាល់ដល់ផ្ទៃទឹកខាងលើបាតសមុទ្រ និងបាតសមុទ្រនៃតំបន់បាតសមុទ្រ ដែលរដ្ឋជាប់ឆ្នេរសមុទ្រអនុវត្តសិទ្ធិអធិបតេយ្យភាពស្របតាមអនុសញ្ញានោះ វិធានការបែបនេះត្រូវអនុវត្ត ដោយយកចិត្តទុកដាក់ពិសេសលើសិទ្ធិអធិបតេយ្យភាពនៃរដ្ឋជាប់ឆ្នេរសមុទ្របែបនេះ។ ការពិគ្រោះយោបល់ត្រូវធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងគោលដៅនេះ ស្របតាមបទប្បញ្ញត្តិទាំងឡាយដែលបានកំណត់ក្នុងផ្នែកនេះ។

៦- ក្នុងករណីឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រដែលត្រូវបានបង្កើតឡើងក្រោមផ្នែកនេះ ដោយថាហេតុ មិនអាចអនុវត្តបានទាំងស្រុងឬដោយផ្នែក នៅក្នុងយុត្តាធិការជាតិនៃរដ្ឋជាប់ឆ្នេរសមុទ្រ ផ្នែកដែលស្ថិតនៅក្នុងយុត្តាធិការជាតិ គឺត្រូវបញ្ឈប់ការអនុវត្តជាបន្ទាន់។ ផ្នែកដែលអាចអនុវត្តបានដទៃទៀតនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ នឹងនៅជាធរមានរហូតដល់សន្និសីទកំពូលបណ្ដាភាគី នៅក្នុងកិច្ចប្រជុំបន្ទាប់របស់ខ្លួនដើម្បីពិនិត្យនិងសម្រេចថាតើត្រូវធ្វើវិសោធនកម្មឬធ្វើមោឃភាពឧបករណ៍គ្រប់គ្រងតាមតំបន់នោះរួមទាំងតំបន់ការពារធម្មជាតិសមុទ្រតាមការចាំបាច់។

៧- នៅពេលបង្កើតឬធ្វើវិសោធនកម្មលើសមត្ថកិច្ចនៃអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រឬវិធានការពាក់ព័ន្ធដែលបានអនុម័តដោយសន្និសីទកំពូលបណ្ដាភាគីដែលស្ថិតក្រោមផ្នែកនេះ ដែលជាលទ្ធផលគឺមិនអាចអនុវត្តបានទាំងស្រុងឬដោយផ្នែក ក្នុងសមត្ថកិច្ចនៃអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលឬក្របខ័ណ្ឌត្រូវនៅជាធរមានរហូតដល់សន្និសីទកំពូលបណ្ដាភាគីពិនិត្យនិងសម្រេចដោយការសហការនិងការសម្របសម្រួលជិតស្និទ្ធ ជាមួយអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ ក្នុងការរក្សាទុក ធ្វើវិសោធនកម្ម ឬធ្វើមោឃភាពឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ និងវិធានការពាក់ព័ន្ធ ក្នុងពេលសមស្រប។

## មាត្រា២៣
## ការធ្វើសេចក្ដីសម្រេច

១- តាមវិធានទូទៅ សេចក្ដីសម្រេចនិងអនុសាសន៍នៅក្រោមផ្នែកនេះ ត្រូវធ្វើឡើងដោយមានការឯកភាពជារួម។

២- ប្រសិនរកការឯកភាពគ្នាជារួមមិនបានទេ សេចក្ដីសម្រេចនិងអនុសាសន៍នៅក្រោមផ្នែកនេះ នឹងត្រូវធ្វើឡើងដោយមតិភាគច្រើនបីភាគបួននៃរដ្ឋភាគីដែលមានវត្តមាននិងបោះឆ្នោត ដោយមុននឹងការអនុវត្តដូច្នេះ សន្និសីទកំពូលបណ្ដាភាគីត្រូវសម្រេចដោយសំឡេងភាគច្រើនពីភាគបីនៃរដ្ឋភាគីដែលមានវត្តមាននិងបោះឆ្នោត បន្ទាប់ពីអស់លទ្ធភាពក្នុងការខិតខំប្រឹងប្រែងស្វែងរកការឯកភាពគ្នាជារួមបាន។

៣- សេចក្ដីសម្រេចដែលធ្វើឡើង នៅក្រោមផ្នែកនេះត្រូវចូលជាធរមានក្នុងរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ បន្ទាប់ពីការប្រជុំនៃសន្និសីទកំពូលបណ្ដាភាគី ដែលខ្លួនបានចូលរួមនិងក្លាយជាសេចក្ដីសម្រេចចងជាកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់រដ្ឋភាគីទាំងអស់។

៤- ក្នុងអំឡុងពេល១២០(មួយរយម្ភៃ)ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ៣ខាងលើ រដ្ឋភាគីណាមួយអាចធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់លេខាធិការដ្ឋាន ដោយធ្វើការជំទាស់ចំពោះសេចក្ដីសម្រេចដែលបានអនុម័តនៅក្រោមផ្នែកនេះ ហើយការសម្រេចនោះនឹងមិនត្រូវចងជាកាតព្វកិច្ចចំពោះរដ្ឋភាគីនោះឡើយ។ ការជំទាស់នឹងសេចក្ដីសម្រេចអាចត្រូវបានដកចេញនៅពេលណាក៏បាន តាមរយៈសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ហើយបន្ទាប់ពីនោះ សេចក្ដីសម្រេចត្រូវមានជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះរដ្ឋភាគីនោះក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងដែលបញ្ជាក់ពីការដកការជំទាស់នោះ។

៥- រដ្ឋភាគីដែលធ្វើការជំទាស់ នៅក្រោមកថាខណ្ឌ៤ខាងលើ ត្រូវផ្ដល់សេចក្ដីជូនដំណឹងទៅលេខាធិការដ្ឋានជាលាយលក្ខណ៍អក្សរ ពីការជំទាស់របស់ខ្លួនដោយពន្យល់អំពីហេតុផលនៃការជំទាស់ ដោយផ្អែកលើហេតុផលមួយឬច្រើនដូចខាងក្រោម៖

ក- សេចក្ដីសម្រេចនោះ មិនស្របនឹងកិច្ចព្រមព្រៀងនេះឬសិទ្ធិនិងភារកិច្ចរបស់រដ្ឋភាគីដែលជំទាស់ដោយអនុលោមតាមអនុសញ្ញា។

ខ- សេចក្ដីសម្រេចនោះមានការរើសអើង ដោយមិនអាចផ្ដល់យុត្តិកម្មបានតាមទម្រង់ឬតាមអង្គហេតុ ប្រឆាំងនឹងរដ្ឋភាគីដែលជំទាស់។

គ- រដ្ឋភាគីជំទាស់នេះជាក់ស្ដែងមិនអាចអនុវត្តបានតាមការសម្រេចនោះ នៅពេលដាក់ការជំទាស់ បន្ទាប់ពីបានខិតខំប្រឹងប្រែងដោយសមហេតុផលដើម្បីអនុវត្តសេចក្ដីសម្រេចនោះ។

៦- រដ្ឋភាគីដែលធ្វើការជំទាស់ នៅក្រោមកថាខណ្ឌ៤ខាងលើ នឹងមានវិសាលភាពអាចអនុវត្តបាន អនុម័តនូវវិធានការឬអភិក្រមជំនួស ដែលសមមូលជាធរមានចំពោះសេចក្ដីសម្រេចដែលខ្លួនបានជំទាស់ ហើយមិនត្រូវអនុម័ត [illegible]ឬមានចំណាត់ការ ដែលនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការសម្រេចដែលខ្លួនបានជំទាស់ លុះត្រាតែ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

វិធានការឬចំណាត់ការនោះមានសារៈសំខាន់សម្រាប់ការអនុវត្តសិទ្ធិនិងភារកិច្ចរបស់រដ្ឋភាគីដែលជំទាស់ដោយអនុលោមតាមអនុសញ្ញា។

៧- រដ្ឋភាគីជំទាស់ត្រូវរាយការណ៍ទៅកិច្ចប្រជុំសាមញ្ញនៅពេលខាងមុខនៃសន្និសីទកំពូលបណ្តាភាគី បន្ទាប់ពីមានសេចក្តីជូនដំណឹងរបស់ខ្លួន នៅក្រោមកថាខណ្ឌ៤ខាងលើ ហើយជាបន្តបន្ទាប់ក្រោយមកតាមកាលកំណត់អំពីការអនុវត្តកថាខណ្ឌ៦ខាងលើ គឺត្រូវផ្តល់ព័ត៌មានសម្រាប់ការត្រួតពិនិត្យនិងការពិនិត្យឡើងវិញក្នុងមាត្រា២៦។

៨- ការជំទាស់លើសេចក្តីសម្រេចដែលបានធ្វើឡើងស្របតាមកថាខណ្ឌ៤ខាងលើអាចបន្តបាន លុះត្រាតែរដ្ឋភាគីជំទាស់ចាត់ទុកថា ការជំទាស់នោះនៅតែមានភាពចាំបាច់ ហើយនៅរៀងរាល់បីឆ្នាំ បន្ទាប់ពីសេចក្តីសម្រេចនោះចូលជាធរមាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់លេខាធិការដ្ឋាន។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរបែបនេះ ត្រូវបញ្ចូលការពន្យល់អំពីមូលដ្ឋាននៃការជំទាស់ដំបូងៗផងដែរ។

៩- ប្រសិនបើពុំបានទទួលការជូនដំណឹងអំពីការបន្តការជំទាស់ ស្របតាមកថាខណ្ឌ៨ខាងលើទេ ការជំទាស់នឹងត្រូវចាត់ទុកថាត្រូវបានដកចេញដោយស្វ័យប្រវត្តិ ហើយបន្ទាប់មក សេចក្តីសម្រេចនេះត្រូវចងជាកាតព្វកិច្ចចំពោះរដ្ឋភាគីនោះរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ បន្ទាប់ពីការជំទាស់នោះត្រូវបានដកចេញដោយស្វ័យប្រវត្តិ។ លេខាធិការដ្ឋាន ត្រូវជូនដំណឹងដល់រដ្ឋភាគីរយៈពេល៦០(ហុកសិប)ថ្ងៃ មុនកាលបរិច្ឆេទដែលការជំទាស់នឹងត្រូវបានដកចេញដោយស្វ័យប្រវត្តិ។

១០- ការសម្រេចនៃសន្និសីទកំពូលបណ្តាភាគីដែលបានអនុម័តនៅក្រោមផ្នែកនេះនិងការជំទាស់ចំពោះសេចក្តីសម្រេចទាំងនោះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈដោយលេខាធិការដ្ឋាន ហើយត្រូវបញ្ជូនទៅរដ្ឋភាគីទាំងអស់និងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

## មាត្រា២៤

## វិធានការសង្គ្រោះបន្ទាន់

១- សន្និសីទកំពូលបណ្តាភាគីត្រូវធ្វើសេចក្តីសម្រេច ដើម្បីអនុម័តវិធានការសង្គ្រោះបន្ទាន់ នៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដើម្បីអនុវត្តជាបន្ទាន់ ប្រសិនបើចាំបាច់ នៅពេលមានបាតុភូតធម្មជាតិឬគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស បានកើតមានឬទំនងជាបង្កឱ្យគ្រោះថ្នាក់ធ្ងន់ធ្ងរឬមិនអាចត្រឡប់វិញបានលើជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដើម្បីធានាថា គ្រោះថ្នាក់ធ្ងន់ធ្ងរនឹងមិនត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរខ្លាំងនោះឡើយ។

២- វិធានការដែលបានអនុម័ត នៅក្រោមមាត្រានេះ ត្រូវបានចាត់ទុកថាចាំបាច់ លុះត្រាតែមានការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយនឹងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលឬក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ស្តីពីការខូចខាតធ្ងន់ធ្ងរឬមិនអាចត្រឡប់វិញបាន មិនអាចគ្រប់គ្រងបានទាន់ពេលវេលា តាមរយៈការអនុវត្តមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះឬដោយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលឬក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៣- វិធានការដែលត្រូវបានអនុម័តសម្រាប់គ្រាអាសន្ន ត្រូវពឹងផ្អែកលើវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រដ៏ល្អបំផុត ហើយបើអាចរកបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ហើយត្រូវគិតគូរពីវិធីបង្ការទុកជាមុន។ វិធានការបែបនេះអាចត្រូវបានស្នើឡើងដោយរដ្ឋភាគីឬជាអនុសាសន៍របស់អង្គភាពជំនាញសាស្ត្រនិងបច្ចេកទេស ហើយអាចត្រូវបានអនុម័តនៅតាមកិច្ចប្រជុំនានា។ វិធានការនេះត្រូវធ្វើជាបណ្តោះអាសន្ន ហើយត្រូវពិចារណាឡើងវិញ សម្រាប់ការសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្នុងពេលបន្ទាប់នៃសន្និសីទកំពូលបណ្តាភាគី បន្ទាប់ពីការអនុម័តដោយសន្និសីទកំពូលបណ្តាភាគី។

៤- វិធានការនេះត្រូវបញ្ចប់រយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីចូលជាធរមានឬត្រូវបញ្ចប់មុនពេលកំណត់ ដោយសន្និសីទកំពូលបណ្តាភាគី នៅពេលត្រូវបានជំនួសដោយឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រនិងវិធានការពាក់ព័ន្ធដែលបានបង្កើតឡើង អនុលោមតាមផ្នែកនេះឬដោយវិធានការដែលបានអនុម័តដោយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យឬដោយសេចក្តីសម្រេចរបស់សន្និសីទកំពូលបណ្តាភាគី នៅពេលដែលកាលៈទេសៈចាំបាច់ត្រូវបញ្ចប់វិធានការនេះ។

៥- នីតិវិធីនិងការណែនាំសម្រាប់បង្កើតវិធានការសង្គ្រោះបន្ទាន់ ក្នុងនោះរួមទាំងនីតិវិធីពិគ្រោះយោបល់ ត្រូវបកស្រាយដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស តាមការចាំបាច់ សម្រាប់ការពិចារណានិងអនុម័តដោយសន្និសីទកំពូលបណ្តាភាគីឱ្យបានលឿនបំផុត តាមដែលអាចធ្វើបាន។ នីតិវិធីបែបនេះត្រូវមានលក្ខណៈបរិយាបន្ននិងតម្លាភាព។

## មាត្រា២៥

## ការអនុវត្ត

១- រដ្ឋភាគីត្រូវធានាថា សកម្មភាពដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ដែលធ្វើឡើងនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវបានធ្វើឡើងស្របនឹងសេចក្តីសម្រេចដែលបានអនុម័ត នៅក្រោមផ្នែកនេះ។

២- នៅក្នុងកិច្ចព្រមព្រៀងនេះមិនមានអ្វីរាំងដល់រដ្ឋភាគីណាមួយពីការអនុម័តវិធានការតឹងរឹងបន្ថែមទៀត ទាក់ទងនឹងជនជាតិនិងនាវារបស់ខ្លួនឬទាក់ទងនឹងសកម្មភាពដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន បន្ថែមលើវិធានការដែលបានអនុម័ត នៅក្រោមផ្នែកនេះ ស្របតាមច្បាប់អន្តរជាតិនិងគាំទ្រដល់គោលដៅនៃកិច្ចព្រមព្រៀង។

៣- ការអនុវត្តវិធានការនានាដែលបានអនុម័តនៅក្រោមផ្នែកនេះមិនដាក់បន្ទុកដោយវិសមាមាត្រលើរដ្ឋភាគីដែលជារដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍឬប្រទេសអភិវឌ្ឍតិចតួច ដោយផ្ទាល់ឬដោយប្រយោល។

៤- ក្នុងពេលសមស្រប រដ្ឋភាគីត្រូវជំរុញការអនុម័តវិធានការពាក់ព័ន្ធនឹងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ក្នុងនាមជាសមាជិករបស់អង្គភាព ដើម្បីគាំទ្រដល់ការអនុវត្តសេចក្តីសម្រេចនិងអនុសាសន៍ដែលធ្វើឡើងដោយសន្និសីទកំពូលបណ្តាភាគីនៅក្រោមផ្នែកនេះ។

៥- រដ្ឋភាគីត្រូវលើកទឹកចិត្តដល់រដ្ឋទាំងឡាយណាដែលមានសិទ្ធិក្លាយជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ជាពិសេសរដ្ឋភាគីដែលសកម្មភាពនាវាឬជនជាតិរបស់ខ្លួន មានប្រតិបត្តិការនៅក្នុងតំបន់ដែលជាកម្មវត្ថុនៃឧបករណ៍គ្រប់គ្រងតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រដែលបានបង្កើតឡើង ដើម្បីអនុម័តវិធានការគាំទ្រដល់សេចក្តីសម្រេចនិងអនុសាសន៍នៃសន្និសីទកំពូលបណ្តាភាគីស្តីពីឧបករណ៍គ្រប់គ្រងតំបន់រួមទាំងតំបន់ការពារធម្មជាតិសមុទ្រដែលត្រូវបានបង្កើតឡើងនៅក្រោមផ្នែកនេះ។

៦- រដ្ឋភាគីដែលមិនមែនជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះឬអ្នកចូលរួមនៅក្នុងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់និងតាមវិស័យនិងផ្ទុយទៅវិញ រដ្ឋភាគីមិនយល់ព្រមក្នុងការអនុវត្តវិធានការដែលបានបង្កើតឡើង នៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនិងដោយស្ថាប័នទាំងនោះ មិនត្រូវដកចេញពីកាតព្វកិច្ចក្នុងការសហការ អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ក្នុងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រ ក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

### មាត្រា២៦

### ការត្រួតពិនិត្យនិងការវាយតម្លៃ

១- ផ្ទៃភាគីត្រូវរាយការណ៍ជាលក្ខណៈបុគ្គលឬជាសមូហភាពទៅកាន់សន្និសីទកំពូលបណ្ដាភាគីស្ដីពីការអនុវត្តឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលបង្កើតឡើងនៅក្រោមផ្នែកនេះនិងផែនការពាក់ព័ន្ធ។ របាយការណ៍បែបនេះ ក៏ដូចជាព័ត៌មាននិងការវាយតម្លៃដែលមានកំណត់ក្នុងកថាខណ្ឌ២និង៣ខាងក្រោម នឹងត្រូវផ្សព្វផ្សាយជាសាធារណៈដោយលេខាធិការដ្ឋាន។

២- អង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់និងតាមវិស័យ នឹងត្រូវបានអញ្ជើញឱ្យផ្ដល់ព័ត៌មានដល់សន្និសីទកំពូលបណ្ដាភាគីស្ដីពីការអនុវត្តផែនការដែលខ្លួនបានអនុម័ត ដើម្បីសម្រេចបាននូវគោលដៅនៃឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលបង្កើតឡើងនៅក្រោមផ្នែកនេះ។

៣- ឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលបង្កើតឡើងនៅក្រោមផ្នែកនេះ រួមទាំងផែនការពាក់ព័ន្ធ នឹងត្រូវបានត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដោយផ្ដោតការយកចិត្តទុកដាក់លើរបាយការណ៍និងព័ត៌មានដែលបានយោងក្នុងកថាខណ្ឌ១និង២។

៤- នៅក្នុងការវាយតម្លៃដោយយោងកថាខណ្ឌ៣ខាងលើ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវវាយតម្លៃពីប្រសិទ្ធភាពនៃឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដែលបានបង្កើតឡើង នៅក្រោមផ្នែកនេះ រួមទាំងផែនការពាក់ព័ន្ធនិងវឌ្ឍនភាពដែលបានធ្វើឡើងនាំដល់ការសម្រេចគោលដៅរបស់ខ្លួននិងផ្ដល់មតិយោបល់និងអនុសាសន៍ដល់សន្និសីទកំពូលបណ្ដាភាគី។

៥- បន្ទាប់ពីមានការវាយតម្លៃរួចមក សន្និសីទកំពូលបណ្ដាភាគី នៅពេលចាំបាច់ ត្រូវធ្វើការសម្រេចឬផ្ដល់អនុសាសន៍លើវិសោធនកម្ម ការបន្ថែមឬមោឃភាពឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ និងផែនការពាក់ព័ន្ធណាមួយដែលត្រូវបានអនុម័តដោយសន្និសីទកំពូលបណ្ដាភាគី ដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រ និងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ហើយបើអាចរកបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនៃជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ដោយយកចិត្តទុកដាក់លើអភិក្រមការពារជាមុននិងអភិក្រមប្រព័ន្ធអេកូឡូស៊ី។

### ផ្នែកទី៤

### ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### មាត្រា២៧

### គោលដៅ

ផ្នែកនេះមានគោលដៅដើម្បី៖

ក- អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដោយបង្ហាញពីដំណើរការ លក្ខខណ្ឌនិងតម្រូវការផ្សេងទៀតសម្រាប់អនុវត្តនិងរាយការណ៍ពីការវាយតម្លៃដោយផ្ទៃភាគីនានា។

ខ- ធានាថា រាល់សកម្មភាពដែលស្ថិតនៅក្រោមផ្នែកនេះ ត្រូវបានវាយតម្លៃនិងធ្វើឡើងដើម្បីការពារ កាត់បន្ថយ និងគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ គឺក្នុងគោលដៅការពារនិងថែរក្សាបរិស្ថានសមុទ្រ។

គ- ផ្ដល់ការពិចារណាលើហេតុប៉ះពាល់កើនសរុបនិងហេតុប៉ះពាល់ទាំងឡាយ នៅក្នុងតំបន់ស្ថិតក្នុង

ឃ- ផ្តល់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ង- សម្រេចបាននូវក្របខ័ណ្ឌវាយតម្លៃហេតុប៉ះពាល់បរិស្ថានដ៏ត្រឹមត្រូវនិងមានសង្គតិភាពចំពោះសកម្មភាពក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ច- កសាងនិងពង្រឹងសមត្ថភាពរបស់រដ្ឋភាគី ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសកំពុងអភិវឌ្ឍមិនជាប់ឆ្នេរសមុទ្រ រដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ រដ្ឋជាប់ឆ្នេរសមុទ្រនៅទ្វីបអាហ្វ្រិក រដ្ឋប្រជុំកោះ និងប្រទេសកំពុងអភិវឌ្ឍមានចំណូលមធ្យម ដើម្បីរៀបចំ អនុវត្តនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់គោលដៅនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា២៨

## កាតព្វកិច្ចរៀបចំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- រដ្ឋភាគីត្រូវធានាថា ហេតុប៉ះពាល់ជាសក្តានុពលលើបរិស្ថានសមុទ្របណ្តាលមកពីសកម្មភាពដែលបានគ្រោងទុក នៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ដែលធ្វើឡើងក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវបានវាយតម្លៃ ដូចមានក្នុងផ្នែកនេះ មុនពេលអនុញ្ញាតឱ្យអនុវត្តសកម្មភាពទាំងនោះ។

២- នៅពេលរដ្ឋភាគីមួយដែលមានយុត្តាធិការឬគ្រប់គ្រងលើសកម្មភាពដែលបានគ្រោងទុក ដែលនឹងត្រូវធ្វើឡើងនៅក្នុងតំបន់សមុទ្រក្នុងដែនសមត្ថកិច្ចជាតិ ដោយកំណត់ថា សកម្មភាពនោះអាចបណ្តាលឱ្យមានការបំពុលឬការផ្លាស់ប្តូរនិងបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់បរិស្ថានសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រដ្ឋភាគីនោះត្រូវធានាថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើសកម្មភាពនោះត្រូវបានធ្វើឡើងស្របតាមផ្នែកនេះឬធានាថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានធ្វើឡើង នៅក្រោមដំណើរការជាតិរបស់រដ្ឋភាគីនោះ។ រដ្ឋភាគីមួយដែលធ្វើការវាយតម្លៃបែបនេះនៅក្រោមដំណើរការជាតិរបស់ខ្លួនត្រូវ៖

ក- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ ដោយប្រើប្រាស់យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលាក្នុងអំឡុងពេលនៃដំណើរវាយតម្លៃថ្នាក់ជាតិរបស់ខ្លួន។

ខ- ធានាថា សកម្មភាពនោះនឹងត្រូវបានត្រួតពិនិត្យក្នុងលក្ខណៈមួយដែលស្របតាមតម្រូវការនៃដំណើរការវាយតម្លៃថ្នាក់ជាតិរបស់ខ្លួន។

គ- ធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងរបាយការណ៍ត្រួតពិនិត្យពាក់ព័ន្ធណាមួយត្រូវបានផ្សព្វផ្សាយ តាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

៣- បន្ទាប់ពីទទួលបានព័ត៌មានដូចដែលបានកំណត់ក្នុងកថាខណ្ឌ២(ក)ខាងលើ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសអាចផ្តល់យោបល់ដល់រដ្ឋភាគីដែលមានយុត្តាធិការឬគ្រប់គ្រងលើសកម្មភាពដែលបានគ្រោងទុកនោះ។

## មាត្រា២៩

## ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ

១- រដ្ឋភាគីត្រូវជំរុញការប្រើប្រាស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងការអនុម័តនិងការអនុវត្តស្តង់ដានិង/ឬគោលការណ៍ណែនាំដែលត្រូវបានបង្កើតឡើង នៅក្រោមមាត្រា៣៨ នៅក្នុងអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យក្នុងនាមជាសមាជិក។

២- សន្និសីទកំពូលបណ្តាភាគីត្រូវបង្កើតយន្តការ នៅក្រោមផ្នែកនេះសម្រាប់អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដើម្បីសហការជាមួយអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យដែលគ្រប់គ្រងសកម្មភាពនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិឬការពារបរិស្ថានសមុទ្រ។

៣- នៅពេលតាក់តែងឬធ្វើបច្ចុប្បន្នកម្មស្តង់ដាឬគោលការណ៍ណែនាំសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ នៅក្រោមមាត្រា៣៨ នេះ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវសហការជាមួយអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៤- ជាការមិនចាំបាច់ក្នុងការត្រួតពិនិត្យឬធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពដែលបានគ្រោងទុកនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិឡើយ ប្រសិនបើរដ្ឋភាគីដែលមានយុត្តាធិការឬការគ្រប់គ្រងលើសកម្មភាពដែលបានគ្រោងទុក៖

ក- កំណត់ថា ហេតុប៉ះពាល់ជាសក្តានុពលនៃសកម្មភាពដែលបានគ្រោងទុកឬប្រភេទនៃសកម្មភាពត្រូវបានវាយតម្លៃ ដោយអនុលោមតាមលក្ខខណ្ឌនៃអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

ខ- កំណត់ថា៖

១- ការវាយតម្លៃដែលបានធ្វើឡើង លើសកម្មភាពដែលបានគ្រោងទុករួចហើយ គឺមានសមមូលទៅនឹងការវាយតម្លៃដែលចាំបាច់ត្រូវធ្វើនៅក្រោមផ្នែកនេះ ហើយលទ្ធផលនៃការវាយតម្លៃត្រូវបានយកមកពិចារណា។ ឬ

២- បទប្បញ្ញត្តិឬស្តង់ដានៃអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យដែលកើតចេញពីការវាយតម្លៃ ត្រូវបានតាក់តែងឡើង ដើម្បីការពារ កាត់បន្ថយ ឬគ្រប់គ្រងផលប៉ះពាល់ជាសក្តានុពល ក្រោមកម្រិតកំណត់សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្រោមផ្នែកនេះនិងអង្គភាពត្រូវបានអនុវត្តតាម។

៥- នៅពេលមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើសកម្មភាព ដែលបានគ្រោងទុកនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវបានធ្វើឡើងនៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍ដែលមានលក្ខណៈជានីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ រដ្ឋភាគីពាក់ព័ន្ធត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវធ្វើឡើង តាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

៦- លើកលែងតែថាសកម្មភាពដែលបានគ្រោងទុកដែលបំពេញលក្ខណវិនិច្ឆ័យដែលមានចែងក្នុងកថាខណ្ឌ៤(ខ)(១)ខាងលើត្រូវត្រួតពិនិត្យនិងវាយតម្លៃ នៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍ច្បាប់និងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យនោះ រដ្ឋភាគីត្រូវត្រួតពិនិត្យនិងវាយតម្លៃសកម្មភាព និងធានាថា របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃត្រូវផ្សព្វផ្សាយ តាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

## មាត្រា៣០

## លក្ខខណ្ឌនិងអត្ថាដើម្បីរៀបចំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- នៅពេលដែលមានសកម្មភាពមួយបានគ្រោងទុក អាចមានផលប៉ះពាល់ច្រើនជាងកម្រិតតិចតួចឬអន្តកោលលើបរិស្ថានសមុទ្រឬផលប៉ះពាល់នៃសកម្មភាពនោះ មិនត្រូវបានដឹងឬយល់ដឹងបានតិចតួច រដ្ឋភាគីដែលមានយុត្តាធិការឬការគ្រប់គ្រងសកម្មភាពនោះ ត្រូវធ្វើការពិនិត្យសកម្មភាព ស្របតាមមាត្រា៣១ ដោយប្រើកត្តានានាដែលមានចែងក្នុងកថាខណ្ឌ២ខាងក្រោម៖

ក- ការត្រួតពិនិត្យត្រូវមានលក្ខណៈលម្អិតគ្រប់គ្រាន់ សម្រាប់ឱ្យរដ្ឋភាគីនោះវាយតម្លៃថាតើខ្លួនមានមូលដ្ឋានសមហេតុផលដើម្បីឱ្យជឿជាក់ថា សកម្មភាពដែលបានគ្រោងទុក អាចបង្កឱ្យមានការបំពុលឬការផ្លាស់ប្តូរបរិស្ថានយ៉ាងធ្ងន់ធ្ងរនិងបង្កគ្រោះថ្នាក់ដល់បរិស្ថានសមុទ្រ ហើយត្រូវមានព័ត៌មាន ដូចតទៅ៖

១- ការពិពណ៌នាអំពីសកម្មភាពដែលបានគ្រោងទុក ក្នុងនោះរួមទាំងគោលដៅ ទីតាំង រយៈពេលនិងប្រពលភាព/អាំងតង់ស៊ីតេនៃសកម្មភាពនោះ។ និង

២- ការវិភាគជំហានដំបូងនៃហេតុប៉ះពាល់ជាសក្តានុពល ក្នុងនោះរួមទាំងការពិចារណាលើហេតុប៉ះពាល់កើនសរុប ហើយក្នុងករណីសមស្រប ជម្រើសជំនួសសម្រាប់សកម្មភាពដែលបានគ្រោងទុក។

ខ- ប្រសិនបើសកម្មភាពនោះត្រូវបានកំណត់ដោយផ្អែកលើការពិនិត្យមើលថារដ្ឋភាគីមានមូលដ្ឋានសមហេតុផលក្នុងការជឿជាក់ថា សកម្មភាពនោះអាចបង្កឱ្យមានការបំពុលឬការផ្លាស់ប្តូរប្រកបដោយគ្រោះថ្នាក់និងធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រនោះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវធ្វើឡើង ស្របតាមបទប្បញ្ញត្តិនៃផ្នែកនេះ។

២- ប្រសិនបើបានកំណត់ថា តើសកម្មភាពដែលបានគ្រោងទុកនោះស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ឆ្លើយតបទៅនឹងលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ១ខាងលើ រដ្ឋភាគីត្រូវពិចារណាលើកត្តាដែលមិនគ្រប់ជ្រុងជ្រោយដូចខាងក្រោម៖

ក- ប្រភេទនិងបច្ចេកវិទ្យាដែលប្រើសម្រាប់សកម្មភាពនិងវិធីដែលត្រូវអនុវត្ត។

ខ- រយៈពេលសម្រាប់ធ្វើសកម្មភាព។

គ- ទីតាំងសម្រាប់ធ្វើសកម្មភាព។

ឃ- លក្ខណៈពិសេសនិងប្រព័ន្ធអេកូឡូស៊ីរបស់ទីតាំង(រាប់បញ្ចូលទាំងតំបន់ដែលមានសារៈសំខាន់ឬភាពងាយរងគ្រោះផ្នែកអេកូឡូស៊ីឬជីវសាស្ត្រជាក់លាក់)។

ង- ហេតុប៉ះពាល់ជាសក្តានុពលសម្រាប់ធ្វើសកម្មភាព ក្នុងនោះរួមទាំងហេតុប៉ះពាល់កើនសរុបជាសក្តានុពលនិងហេតុប៉ះពាល់ជាសក្តានុពលនៅក្នុងតំបន់ស្ថិតក្រោមយុត្តាធិការជាតិ។

ច- វិសាលភាពដែលឥទ្ធិពលនៃសកម្មភាពមិនត្រូវបានស្គាល់ឬមានការយល់ដឹងតិចតួច។

ឆ- លក្ខណវិនិច្ឆ័យអេកូឡូស៊ីឬជីវសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

## មាត្រា៣១

## ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- រដ្ឋភាគីត្រូវធានាថា រាល់ដំណើរការសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានកំណត់ក្នុងផ្នែកនេះមានជាជំហានដូចខាងក្រោម៖

ក- *ការត្រួតពិនិត្យ*: រដ្ឋភាគីត្រូវធ្វើការត្រួតពិនិត្យឱ្យទាន់ពេលវេលា ដើម្បីកំណត់ថា តើមានតម្រូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬទេ ដែលទាក់ទងនឹងសកម្មភាពដែលបានគ្រោងទុកស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ស្របតាមមាត្រា៣០និងធ្វើការផ្សព្វផ្សាយជាសាធារណៈនូវការសម្រេចរបស់ខ្លួន៖

១- ប្រសិនបើរដ្ឋភាគីណាមួយកំណត់ថាមិនចាំបាច់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះសកម្មភាពដែលបានគ្រោងទុកស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួនទេនោះ រដ្ឋភាគីនោះត្រូវផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធស្របតាមមាត្រា៣០ កថាខណ្ឌ១(ក) ជាសាធារណៈ តាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាននៅក្នុងកិច្ចព្រមព្រៀងនេះ។

២- ដោយឈរលើមូលដ្ឋានផ្នែកវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ហើយបើអាចធ្វើបាន ចំណេះដឹងប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន រដ្ឋភាគីមួយអាចកត់ត្រាទស្សនៈរបស់ខ្លួនអំពីហេតុប៉ះពាល់ជាសក្តានុពលនៃសកម្មភាពដែលបានគ្រោងទុក ដែលខ្លួនបានធ្វើសេចក្តីតាំងចិត្ត អនុលោមតាមកថាខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(ក)(១)ខាងលើ ជាមួយរដ្ឋភាគីដែលបានធ្វើសេចក្តីតាំងចិត្តនោះនិងអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ក្នុងរយៈពេល៤០(សែសិប)ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយរួចមក។

៣- ប្រសិនបើរដ្ឋភាគីដែលបានកត់ត្រាទស្សនៈរបស់ខ្លួន មានការព្រួយបារម្ភអំពីហេតុប៉ះពាល់ជាសក្តានុពលនៃសកម្មភាពដែលបានគ្រោងទុក ដែលខ្លួនបានធ្វើសេចក្តីតាំងចិត្តនោះ រដ្ឋភាគីដែលបានធ្វើសេចក្តីតាំងចិត្តនោះត្រូវធ្វើការពិចារណាលើការបារម្ភនោះ ហើយអាចពិនិត្យវាយតម្លៃលើសេចក្តីតាំងចិត្តនោះ។

៤- បន្ទាប់ពីពិចារណាលើការបារម្ភដែលបានកត់ត្រាដោយរដ្ឋភាគីមួយ នៅក្រោមកថាខណ្ឌ(ក)(២)ខាងលើ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ត្រូវពិចារណានិងអាចវាយតម្លៃហេតុប៉ះពាល់ជាសក្តានុពលនៃសកម្មភាពដែលបានគ្រោងទុក ដោយផ្អែកលើវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុតនិងប្រសិនបើអាចធ្វើបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ហើយក្នុងភាពសមស្រប អាចផ្តល់អនុសាសន៍ដល់រដ្ឋភាគីដែលបានធ្វើការតាំងចិត្ត បន្ទាប់ពីបានផ្តល់ឱកាសឱ្យរដ្ឋភាគីនោះឆ្លើយតបទៅនឹងសេចក្តីបារម្ភដែលបានកត់ត្រានិងយកចិត្តទុកដាក់លើការឆ្លើយតបបែបនោះ។

៥- រដ្ឋភាគីដែលបានធ្វើការតាំងចិត្តនោះ ស្របតាមកថាខណ្ឌ(ក)(១)ខាងលើ ត្រូវធ្វើការពិចារណាលើអនុសាសន៍នានារបស់អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស។

៦- ការកត់ត្រាទស្សនៈនិងអនុសាសន៍របស់អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

ខ- *ការកំណត់វិសាលភាព*: រដ្ឋភាគីត្រូវធានាថា ហេតុប៉ះពាល់បរិស្ថានសំខាន់ៗនិងហេតុប៉ះពាល់នានា ដូចជាហេតុប៉ះពាល់សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសុខភាពមនុស្ស និងហេតុប៉ះពាល់ជាសក្តានុពលនៅក្នុងតំបន់នានាក្នុងយុត្តាធិការជាតិ ក៏ដូចជាជម្រើសជំនួសសម្រាប់សកម្មភាពដែលបានគ្រោងទុក ប្រសិនបើមាន ដែលត្រូវបញ្ចូលទៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលត្រូវធ្វើឡើង នៅក្រោមផ្នែកនេះ ត្រូវបានកំណត់អត្តសញ្ញាណ។ វិសាលភាពនេះត្រូវកំណត់ដោយការប្រើប្រាស់វិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ហើយបើអាចរកបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន។

គ- *ការវាយតម្លៃពីឥទ្ធិពលនិងវាយតម្លៃពីការរៀបចំនិងការអនុវត្ត* : រដ្ឋភាគីត្រូវធានាថា ហេតុប៉ះពាល់នៃសកម្មភាពដែលបានគ្រោងទុក ក្នុងនោះរួមទាំងហេតុប៉ះពាល់កើនសរុបនិងហេតុប៉ះពាល់ដទៃទៀត នៅក្នុងតំបន់នានាក្នុងដែនសមត្ថកិច្ចជាតិ ត្រូវបានវាយតម្លៃពីឥទ្ធិពលនិងវាយតម្លៃពីការរៀបចំនិងអនុវត្ត ដោយប្រើវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ហើយបើអាចរកបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន។

ឃ- *ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានជាសក្តានុពល*: រដ្ឋភាគីត្រូវធានាថា៖

១- វិធានការដើម្បីការពារ កាត់បន្ថយ និងគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានជាសក្តានុពលនៃសកម្មភាពដែលបានគ្រោងទុកនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ត្រូវបានកំណត់អត្តសញ្ញាណនិងវិភាគ ដើម្បីបញ្ចៀសហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ។ វិធានការបែបនេះអាចមានដូចជាការពិចារណាលើជម្រើសជំនួសសកម្មភាពដែលបានគ្រោងទុកនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន។

២- ប្រសិនបើសមស្រប វិធានការទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

៣- រដ្ឋភាគីត្រូវធានាឱ្យមានការជូនដំណឹងនិងការពិគ្រោះយោបល់ជាសាធារណៈ ស្របតាមមាត្រា៣២។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ច- រដ្ឋភាគីត្រូវធានាឱ្យមានការរៀបចំនិងការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានស្របតាមមាត្រា៣៣។

២- រដ្ឋភាគីអាចធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមគ្នា ជាពិសេសសម្រាប់សកម្មភាពដែលបានគ្រោងទុកស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ។

៣- បញ្ជីឈ្មោះជំនាញការត្រូវបង្កើតដោយស្ថិតនៅក្រោមអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស។ រដ្ឋភាគីដែលមានសមត្ថភាពមានកម្រិត អាចស្នើសុំមតិយោបល់និងជំនួយពីជំនាញការទាំងនោះដើម្បីអនុវត្តនិងវាយតម្លៃការត្រួតពិនិត្យនិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើសកម្មភាពដែលបានគ្រោងទុកដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន។ ជំនាញការមិនអាចត្រូវបានតែងតាំងទៅផ្នែកផ្សេងទៀតនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពដូចគ្នានោះទេ។ រដ្ឋភាគីដែលបានស្នើសុំមតិយោបល់និងជំនួយ ត្រូវធានាថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវបានដាក់ជូនដល់ខ្លួន ដើម្បីពិនិត្យវាយតម្លៃនិងធ្វើការសម្រេច។

## មាត្រា៣២

## ការជូនដំណឹងនិងការពិគ្រោះយោបល់ជាសាធារណៈ

១- រដ្ឋភាគីត្រូវធានាដល់ការជូនដំណឹងជាសាធារណៈឱ្យបានទាន់ពេលវេលានូវសកម្មភាព ដែលបានគ្រោងទុក ក្នុងនោះរួមទាំងការផ្សព្វផ្សាយតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាននិងតាមរយៈលេខាធិការដ្ឋាននិងឱកាសដែលបានគ្រោងទុកនិងក្នុងពេលវេលាជាក់លាក់ តាមលទ្ធភាពដែលអាចអនុវត្តបាន សម្រាប់ការចូលរួមពីគ្រប់រដ្ឋទាំងអស់ ជាពិសេសរដ្ឋជាប់នឹងឆ្នេរសមុទ្រនិងរដ្ឋផ្សេងទៀតដែលនៅជាប់នឹងសកម្មភាព នៅពេលដែលរដ្ឋទាំងនោះអាចទទួលរងផលប៉ះពាល់ខ្លាំងបំផុតនិងរដ្ឋភាគីពាក់ព័ន្ធក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ។ ការជូនដំណឹងនិងឱកាសសម្រាប់ការចូលរួម ក្នុងនោះរួមទាំងតាមរយៈការផ្តល់មតិយោបល់ ត្រូវធ្វើឡើងពេញលេញនូវដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រសិនបើសមស្រប ក្នុងនោះរួមទាំងនៅដំណាក់កាលនៃការកំណត់វិសាលភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្ថិតក្រោមមាត្រា៣១ កថាខណ្ឌ១(ខ)និងនៅដំណាក់កាលនៃការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានស្របតាមខ្លឹមសារមាត្រា៣៣ មុនពេលធ្វើសេចក្តីសម្រេចថាតើត្រូវឬមិនត្រូវអនុញ្ញាតសកម្មភាពនោះ។

២- រដ្ឋដែលរងផលប៉ះពាល់ខ្លាំងបំផុតជាសក្តានុពលត្រូវបានកំណត់តាមរយៈការយកចិត្តទុកដាក់លើលក្ខណៈនិងផលប៉ះពាល់ជាសក្តានុពលលើបរិស្ថានសមុទ្រនៃសកម្មភាពដែលបានគ្រោងទុក ហើយត្រូវមាន៖

ក- រដ្ឋជាប់ឆ្នេរសមុទ្រដែលអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួនក្នុងគោលដៅរុករក ដកហូត អភិរក្ស ឬគ្រប់គ្រងធនធានធម្មជាតិ អាចត្រូវបានជឿជាក់ដោយសមហេតុផលថានឹងទទួលរងផលប៉ះពាល់ដោយសកម្មភាពនោះ

ខ- រដ្ឋដែលអនុវត្តសកម្មភាពដោយមនុស្សនៅក្នុងតំបន់នៃសកម្មភាពដែលបានគ្រោងទុក ក្នុងនោះរួមទាំងសកម្មភាពសេដ្ឋកិច្ច ដែលអាចជឿជាក់ដោយសមហេតុផលថានឹងទទួលរងផលប៉ះពាល់។

៣- រដ្ឋភាគីពាក់ព័ន្ធក្នុងដំណើរការនេះមានដូចជាជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលមានចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ អង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធនៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ សង្គមស៊ីវិល សហគមន៍វិទ្យាសាស្ត្រ និងសាធារណជន។

៤- ការជូនដំណឹងនិងការពិគ្រោះយោបល់ជាសាធារណៈ អនុលោមតាមមាត្រា៤៨ កថាខណ្ឌ៣ ត្រូវមានលក្ខណៈជាប់ប្រយោជន៍និងតម្លាភាព ត្រូវធ្វើឡើងឱ្យទាន់ពេលវេលានិងចំចំណុចដៅនិងបុរេសកម្ម នៅពេលដែលមានពាក់ព័ន្ធនឹងរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ។

៥- មតិយោបល់សំខាន់ៗដែលទទួលបានក្នុងអំឡុងពេលនៃដំណើរការពិគ្រោះយោបល់ ក្នុងនោះរួមទាំងពីរដ្ឋជាប់មាត់សមុទ្រនិងរដ្ឋផ្សេងទៀតដែលនៅជាប់នឹងសកម្មភាពដែលបានគ្រោងទុក នៅពេលដែលខ្លួនជារដ្ឋរងផលប៉ះពាល់ខ្លាំងបំផុត ត្រូវបានពិចារណានិងឆ្លើយតបឬដោះស្រាយដោយរដ្ឋភាគី។ រដ្ឋភាគីត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះមតិយោបល់ទាក់ទងនឹងហេតុប៉ះពាល់ជាសក្ដានុពលនៅក្នុងតំបន់ក្នុងយុត្តាធិការជាតិនិងផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរតាមការសមស្រប ជាពិសេសការឆ្លើយតបទៅនឹងមតិយោបល់ទាំងនោះ ក្នុងនោះទាក់ទងនឹងវិធានការបន្ថែមដែលសំដៅដោះស្រាយផលប៉ះពាល់ជាសក្ដានុពលទាំងនោះ។ រដ្ឋភាគីត្រូវផ្សព្វផ្សាយជាសាធារណៈនូវមតិយោបល់ដែលទទួលបាននិងការឆ្លើយតបឬការពិពណ៌នាអំពីវិធីដែលខ្លួនត្រូវបានដោះស្រាយ។

៦- នៅពេលដែលមានសកម្មភាពបានគ្រោងទុក ដោយប៉ះពាល់ដល់តំបន់សមុទ្រទឹកជ្រៅដែលព័ទ្ធជុំវិញទាំងស្រុងដោយតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋ រដ្ឋភាគីត្រូវ៖

ក- រៀបចំឱ្យមានការពិគ្រោះយោបល់ជាមួយក្រុមគោលដៅនិងលក្ខណៈបុរេសកម្ម ក្នុងនោះរួមទាំងការជូនដំណឹងជាមុនដល់រដ្ឋជុំវិញនោះ

ខ- ពិចារណាលើទស្សនៈនិងមតិយោបល់របស់រដ្ឋជុំវិញអំពីសកម្មភាពដែលបានគ្រោងទុក ហើយផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ដោយសំដៅជាពិសេសចំពោះទស្សនៈនិងមតិយោបល់ទាំងនោះ ហើយបើអាចធ្វើបានត្រូវពិនិត្យកែប្រែសកម្មភាពដែលបានគ្រោងទុកនោះ។

៧- រដ្ឋភាគីត្រូវធានាលើការទទួលបាននូវព័ត៌មានទាក់ទងនឹងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្រោមកិច្ចព្រមព្រៀងនេះ។ ទោះជាយ៉ាងនេះក្តី រដ្ឋភាគីមិនតម្រូវឱ្យបង្ហាញព័ត៌មានសម្ងាត់ឬព័ត៌មានទាក់ទងនឹងកម្មសិទ្ធិឯកជនទេ។ ប្រការដែលព័ត៌មានសម្ងាត់ឬព័ត៌មានទាក់ទងនឹងកម្មសិទ្ធិឯកជនត្រូវបានកែប្រែ ត្រូវបញ្ជាក់នៅក្នុងឯកសារសាធារណៈ។

## មាត្រា៣៣

## របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- រដ្ឋភាគីត្រូវធានាការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការវាយតម្លៃដែលធ្វើឡើងដោយស្របតាមផ្នែកនេះ។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានព័ត៌មានយ៉ាងតិចណាស់ ដូចជា ការពិពណ៌នាអំពីសកម្មភាពដែលបានគ្រោងទុក ក្នុងនោះរួមទាំងទីតាំងសកម្មភាព ការពិពណ៌នាអំពីលទ្ធផលនៃកំណត់វិសាលភាព ការវាយតម្លៃទិន្នន័យមូលដ្ឋាននៃបរិស្ថានសមុទ្រដែលអាចរងផលប៉ះពាល់ ការពិពណ៌នាអំពីផលប៉ះពាល់ជាសក្ដានុពល រួមទាំងហេតុប៉ះពាល់កើនសរុបជាសក្ដានុពល និងហេតុប៉ះពាល់ផ្សេងៗទៀតនៅក្នុងតំបន់ក្នុងយុត្តាធិការជាតិ។ ការពិពណ៌នាអំពីវិធានការបង្ការ កាត់បន្ថយ និងការគ្រប់គ្រងជាសក្ដានុពល។ ការពិពណ៌នាអំពីភាពមិនច្បាស់លាស់និងកង្វះចំណេះដឹង ព័ត៌មានអំពីដំណើរការពិគ្រោះយោបល់សាធារណៈ ការពិពណ៌នាអំពីការពិចារណានៃជម្រើសសមហេតុផលជំនួសសកម្មភាពដែលបានគ្រោងទុក ការពិពណ៌នាអំពីសកម្មភាពត្រួតពិនិត្យបន្ទាប់ ក្នុងនោះរួមទាំងផែនការគ្រប់គ្រងបរិស្ថាននិងសេចក្តីសង្ខេបមិនមែនជាបច្ចេកទេស។

៣- រដ្ឋភាគីត្រូវផ្សព្វផ្សាយសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ក្នុងអំឡុងពេលដំណើរការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីផ្តល់ឱកាសឱ្យអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសពិចារណានិងវាយតម្លៃរបាយការណ៍។

៤- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស តាមភាពសមស្របនិងទាន់ពេលវេលា អាចផ្តល់យោបល់ទៅរដ្ឋភាគីលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ រដ្ឋភាគីត្រូវពិចារណាលើមតិយោបល់ណាមួយដែលផ្តល់ដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស។

៥- រដ្ឋភាគីត្រូវផ្សព្វផ្សាយរបាយការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងនោះរួមទាំងតាមរយៈយន្តការសម្រួលសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។ លេខាធិការដ្ឋានត្រូវធានាថា រដ្ឋភាគីទាំងអស់ត្រូវទទួលបានការជូនដំណឹងឱ្យទាន់ពេលវេលា នៅពេលរបាយការណ៍ត្រូវបានបោះពុម្ពផ្សាយតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

៦- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយត្រូវយកមកពិចារណា ដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដោយផ្អែកលើការអនុវត្ត នីតិវិធីនិងចំណេះដឹងពាក់ព័ន្ធស្ថិតក្នុងកិច្ចព្រមព្រៀងនេះ ក្នុងគោលដៅបង្កើតគោលការណ៍ណែនាំរួមទាំងការកំណត់អត្តសញ្ញាណនៃការអនុវត្តល្អបំផុត។

៧- កម្រងព័ត៌មានដែលបានបោះពុម្ពផ្សាយដែលប្រើក្នុងដំណើរការត្រួតពិនិត្យ ដើម្បីធ្វើការសម្រេចចិត្តថាតើត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយអនុលោមតាមមាត្រា៣០និងមាត្រា៣១ នឹងត្រូវពិចារណានិងពិនិត្យវាយតម្លៃដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដោយផ្អែកលើការអនុវត្ត នីតិវិធីនិងចំណេះដឹងពាក់ព័ន្ធ នៅក្នុងកិច្ចព្រមព្រៀងនេះ ក្នុងគោលដៅនៃការបង្កើតគោលការណ៍ណែនាំ ក្នុងនោះរួមទាំងការកំណត់អត្តសញ្ញាណនៃការអនុវត្តល្អបំផុត។

## មាត្រា៣៤

## ការធ្វើសេចក្តីសម្រេច

១- រដ្ឋភាគីដែលស្ថិតក្រោមយុត្តាធិការឬគ្រប់គ្រងផែនការសកម្មភាពដែលមិនអាចអនុវត្តបាន ត្រូវទទួលខុសត្រូវដោយកំណត់ថា តើសកម្មភាពដែលបានគ្រោងទុកនោះអាចដំណើរការបានដែរឬទេ។

២- នៅពេលកំណត់ថា តើសកម្មភាពដែលបានគ្រោងទុកអាចដំណើរការបានឬទេនៅក្រោមផ្នែកនេះ ការយកចិត្តទុកដាក់ពេញលេញនឹងត្រូវធ្វើឡើងលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយអនុលោមតាមផ្នែកនេះ។ ការសម្រេចអនុញ្ញាតឱ្យអនុវត្តសកម្មភាពដែលបានគ្រោងទុកនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់រដ្ឋភាគីណាមួយនឹងធ្វើឡើងបាននៅពេលណា ការពិចារណាលើវិធានការកាត់បន្ថយឬគ្រប់គ្រង រដ្ឋភាគីនោះបានកំណត់ថា ខ្លួនបានខិតខំប្រឹងប្រែងសមហេតុផលទាំងអស់ ដើម្បីធានាថា សកម្មភាពនោះអាចប្រព្រឹត្តទៅបានក្នុងលក្ខណៈស្របគ្នាជាមួយនឹងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបរិស្ថានសមុទ្រ។

៣- ឯកសារសេចក្តីសម្រេច ត្រូវបង្ហាញយ៉ាងច្បាស់នូវលក្ខខណ្ឌក្នុងការឯកភាពដែលទាក់ទងនឹងវិធានការកាត់បន្ថយនិងតម្រូវការពិនិត្យតាមដានបន្តបន្ទាប់។ ឯកសារសេចក្តីសម្រេចនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

៤- តាមសំណើសុំរបស់រដ្ឋភាគីមួយ សន្និសីទកំពូលបណ្តាភាគីអាចផ្តល់មតិយោបល់និងជំនួយដល់រដ្ឋភាគីនោះដោយកំណត់ថា តើអាចអនុវត្តបានឬមិនបាននូវសកម្មភាពដែលបានគ្រោងទុកនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន។

## មាត្រា៣៥

## ការត្រួតពិនិត្យហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាត

រដ្ឋភាគីត្រូវប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រល្អបំផុត ហើយបើអាចរកបាននូវចំណេះដឹងជាប្រពៃណី [illegible]របស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ត្រូវរក្សាទុកក្រោមការឃ្លាំមើលនូវហេតុប៉ះពាល់នៃ[illegible]ក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិដែលខ្លួនអនុញ្ញាតឬដែលខ្លួនចូលរួម ដើម្បីកំណត់ថា តើសកម្មភាពទាំងនេះ[illegible]ឬមានហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថានសមុទ្រឬទេ ជាពិសេស រដ្ឋភាគីនីមួយៗត្រូវត្រួតពិនិត្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់ពាក់ព័ន្ធ ដូចជាហេតុប៉ះពាល់សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសុខភាពមនុស្ស នៃសកម្មភាពដែលបានអនុញ្ញាតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួន ដោយអនុលោមតាមលក្ខខណ្ឌដែលមានចែងនៅក្នុងការឯកភាពនឹងសកម្មភាព។

## មាត្រា៣៦

## ការធ្វើរបាយការណ៍អំពីផលប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាត

១- រដ្ឋភាគីមិនថាធ្វើសកម្មភាពជាបុគ្គលឬជាសមូហភាពឡើយ ត្រូវរាយការណ៍ជាទៀងទាត់អំពីហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាតនិងលទ្ធផលនៃការត្រួតពិនិត្យដែលបានកំណត់ក្នុងមាត្រា៣៥។

២- របាយការណ៍ត្រួតពិនិត្យត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ហើយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសអាចពិចារណានិងវាយតម្លៃរបាយការណ៍ត្រួតពិនិត្យ។

៣- របាយការណ៍ត្រួតពិនិត្យត្រូវពិចារណាដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ដោយផ្អែកលើការអនុវត្តនីតិវិធីនិងចំណេះដឹងពាក់ព័ន្ធក្រោមកិច្ចព្រមព្រៀងនេះ ក្នុងគោលដៅបង្កើតគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាត ក្នុងនោះរួមទាំងការកំណត់អត្តសញ្ញាណនៃការអនុវត្តល្អបំផុត។

## មាត្រា៣៧

## ការពិនិត្យសកម្មភាពដែលបានអនុញ្ញាតនិងហេតុប៉ះពាល់នៃសកម្មភាព

១- រដ្ឋភាគីត្រូវធានាថា ហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាតបានត្រួតពិនិត្យស្របតាមមាត្រា៣៥ ត្រូវបានត្រួតពិនិត្យវាយតម្លៃ។

២- ប្រសិនបើរដ្ឋភាគីដែលមានយុត្តាធិការឬការគ្រប់គ្រងលើសកម្មភាព កំណត់អត្តសញ្ញាណហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដែលមិនត្រូវបានមើលឃើញទុកជាមុននៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាទម្រង់នៃលក្ខណៈឬភាពធ្ងន់ធ្ងរឬដែលកើតឡើងពីការបំពានលក្ខខណ្ឌណាមួយដែលមានចែងក្នុងការឯកភាពលើសកម្មភាពនោះ រដ្ឋភាគីនោះត្រូវពិនិត្យសេចក្តីសម្រេចដែលខ្លួនបានអនុញ្ញាតឱ្យធ្វើសកម្មភាព ជូនដំណឹងដល់សន្និសីទបណ្តារដ្ឋភាគី រដ្ឋភាគីផ្សេងៗទៀតនិងសាធារណជន ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាននិង

ក- តម្រូវឱ្យមានការស្នើសុំនិងអនុវត្តវិធានការដើម្បីទប់ស្កាត់ កាត់បន្ថយនិង/ឬគ្រប់គ្រងហេតុប៉ះពាល់ទាំងនោះ ឬចាត់វិធានការចាំបាច់ណាមួយផ្សេងទៀតនិង/ឬបញ្ឈប់សកម្មភាព ក្នុងករណីសមស្របនិង

ខ- វាយតម្លៃឱ្យបានទាន់ពេលវេលា នូវវិធានការណាមួយដែលបានអនុវត្តឬមានចំណាត់ការ ដែលបានធ្វើឡើងនៅក្រោមកថាខណ្ឌ(ក)ខាងលើ។

៣- ដោយផ្អែកលើរបាយការណ៍ដែលទទួលបាននៅក្រោមមាត្រា៣៦ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសអាចជូនដំណឹងដល់រដ្ឋភាគីដែលបានអនុញ្ញាតឱ្យមានសកម្មភាពនោះ ប្រសិនបើខ្លួនយល់ឃើញថា សកម្មភាពនោះអាចមានហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដែលមិនត្រូវបានដឹងជាមុន នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឬដែលកើតឡើងពីការរំលោភលើលក្ខខណ្ឌនៃការអនុម័តលើសកម្មភាពដែលបានអនុញ្ញាត ហើយអាចផ្តល់អនុសាសន៍ដល់រដ្ឋភាគី ក្នុងករណីសមស្រប។

៤- (ត) ដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ហើយប្រសិនបើរកបាន ចំណេះដឹងប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន រដ្ឋភាគីមួយអាចកត់ត្រាការបារម្ភរបស់ខ្លួន

ជាមួយរដ្ឋភាគីដែលបានអនុញ្ញាតឱ្យមានការធ្វើសកម្មភាពនិងជាមួយវិទ្យាសាស្ត្រនិងស្ថាប័នបច្ចេកទេសដែលសកម្មភាពដែលត្រូវបានអនុញ្ញាត អាចមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដែលមិនត្រូវបានដឹងយល់ជាមុននៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទម្រង់លក្ខណៈឬភាពធ្ងន់ធ្ងរឬដែលកើតឡើងពីការបំពានលក្ខខណ្ឌណាមួយនៃការឯកភាពលើសកម្មភាពដែលបានអនុញ្ញាត។

ខ- រដ្ឋភាគីដែលបានអនុញ្ញាតឱ្យធ្វើសកម្មភាពនោះ ត្រូវពិចារណាលើក្ដីបារម្ភទាំងនោះ។

គ- បន្ទាប់ពីបានពិចារណាលើក្ដីបារម្ភដែលបានកត់ត្រាដោយរដ្ឋភាគីមួយនោះ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវពិចារណានិងអាចវាយតម្លៃបញ្ហានេះដោយផ្អែកលើវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យាសាស្ត្រល្អបំផុតហើយប្រសិនបើអាចកែបាន ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ហើយអាចជូនដំណឹងដល់រដ្ឋភាគីដែលបានអនុញ្ញាតឱ្យធ្វើសកម្មភាពនេះ ប្រសិនបើខ្លួនចាត់ទុកថាសកម្មភាពនោះអាចមានហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដែលមិនអាចដឹងជាមុនបាន នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឬដែលកើតឡើងពីការរំលោភលើលក្ខខណ្ឌណាមួយនៃការឯកភាពលើសកម្មភាពដែលបានអនុញ្ញាត ហើយបន្ទាប់ពីផ្ដល់ឱ្យរដ្ឋភាគីនោះនូវឱកាសដើម្បីឆ្លើយតបទៅនឹងក្ដីបារម្ភដែលបានកត់ត្រានិងគិតគូរពីការឆ្លើយតបនោះ ហើយក្នុងករណីសមស្រប អាចនឹងផ្ដល់អនុសាសន៍ដល់រដ្ឋភាគីដែលបានអនុញ្ញាតឱ្យធ្វើសកម្មភាព។

ឃ- ការកត់ត្រាពីក្ដីបារម្ភ ការជូនដំណឹងណាមួយដែលបានធ្វើឡើងនិងអនុសាសន៍ណាមួយដែលបានផ្ដល់ឱ្យដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មាន។

ង- រដ្ឋភាគីដែលបានអនុញ្ញាតឱ្យធ្វើសកម្មភាព ត្រូវពិចារណាលើការជូនដំណឹងនានាដែលបានផ្សព្វផ្សាយនិងអនុសាសន៍ណាមួយដែលបានផ្ដល់ឱ្យដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស។

៥- រដ្ឋទាំងអស់ ជាពិសេសរដ្ឋជាប់ឆ្នេរសមុទ្រនិងរដ្ឋផ្សេងទៀតដែលនៅជិតនឹងសកម្មភាព នៅពេលដែលរដ្ឋមានសក្ដានុពលទាំងនោះរងផលប៉ះពាល់ខ្លាំងបំផុត រដ្ឋនោះត្រូវជូនដំណឹងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មាន ហើយអាចត្រូវពិគ្រោះយោបល់ក្នុងដំណើរការត្រួតពិនិត្យរាយការណ៍និងពិនិត្យវាយតម្លៃទាក់ទងនឹងសកម្មភាពដែលត្រូវបានអនុញ្ញាតនៅក្រោមកិច្ចព្រមព្រៀងនេះ។

៦- រដ្ឋភាគីត្រូវផ្សព្វផ្សាយ ក្នុងនោះរួមទាំងតាមរយៈយន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មាន៖

ក- របាយការណ៍ស្ដីពីការពិនិត្យវាយតម្លៃនៃហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាត។

ខ- ឯកសារស្ដីពីសេចក្ដីសម្រេច ក្នុងនោះរួមទាំងកំណត់ត្រាអំពីហេតុផលនាំដល់ការធ្វើសេចក្ដីសម្រេចដោយរដ្ឋភាគី នៅពេលរដ្ឋភាគីមួយបានផ្លាស់ប្ដូរសេចក្ដីសម្រេចរបស់ខ្លួនក្នុងការអនុញ្ញាតឱ្យធ្វើសកម្មភាព។

## មាត្រា៣៨

## ស្តង់ដានិង/ឬសេចក្ដីណែនាំដែលត្រូវបានបង្កើតឡើងដោយអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវរៀបចំបង្កើតស្ដង់ដាឬគោលការណ៍ណែនាំសម្រាប់ការពិចារណានិងអនុម័តឱ្យអនុវត្តដោយសន្និសីទកំពូលបណ្ដាភាគីស្ដីពី៖

ក- ការកំណត់ថា តើត្រូវកម្រិតលក្ខខណ្ឌនៃការពិនិត្យជ្រើសរើសឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានស្ថិតនៅក្រោមមាត្រា៣០ ត្រូវបានបំពេញឬលើសពីការកំណត់ សម្រាប់សកម្មភាពដែលបានគ្រោងទុក ក្នុងនោះរួមទាំងផ្អែកលើ[illegible]ជ្រាយដូចមានចែងក្នុងកថាខណ្ឌ២នៃមាត្រានេះ។

ខ- ការវាយតម្លៃហេតុប៉ះពាល់កើនសរុបនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិនិងវិធីក្នុងការគិតពិចារណាលើផលប៉ះពាល់ទាំងនោះ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

គ- ការវាយតម្លៃហេតុប៉ះពាល់នៅក្នុងតំបន់ដែលស្ថិតក្នុងដែនសមត្ថកិច្ចជាតិ នៃសកម្មភាពដែលបានគ្រោងទុកក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិនិងវិធីក្នុងការគិតពិចារណាលើផលប៉ះពាល់ទាំងនោះ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ឃ- ដំណើរការជូនដំណឹងនិងពិគ្រោះយោបល់ជាសាធារណៈ ស្របតាមមាត្រា៣២ ក្នុងនោះរួមទាំងការកំណត់នូវអ្វីដែលជាព័ត៌មានសម្ងាត់ឬជាព័ត៌មានទាក់ទងនឹងកម្មសិទ្ធិឯកជន។

ង- ខ្លឹមសារចាំបាច់នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងព័ត៌មានដែលបានបោះពុម្ពផ្សាយត្រូវបានប្រើក្នុងដំណើរការនៃការពិនិត្យដោយអនុលោមតាមមាត្រា៣៣ ក្នុងនោះ រួមទាំងការអនុវត្តដ៏ល្អ។

ច- ការត្រួតពិនិត្យនិងការរៀបចំរបាយការណ៍អំពីហេតុប៉ះពាល់នៃសកម្មភាពដែលបានអនុញ្ញាតដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦ ក្នុងនោះរួមទាំងការកំណត់ការអនុវត្តដ៏ល្អ។

ឆ- ការអនុវត្តលើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

២- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសក៏អាចរៀបចំបង្កើតស្តង់ដានិងគោលការណ៍ណែនាំសម្រាប់ការពិចារណានិងការអនុម័តដោយសន្និសីទកំពូលបណ្តាភាគី ក្នុងនោះរួមទាំង៖

ក- បញ្ជីនៃសកម្មភាពមិនពេញលេញ ដែលទាមទារឬមិនទាមទារឱ្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាលក្ខណវិនិច្ឆ័យដែលទាក់ទងនឹងសកម្មភាពទាំងនោះ ដែលត្រូវធ្វើបច្ចុប្បន្នកម្មតាមកាលកំណត់។

ខ- ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ នៅក្នុងតំបន់ដែលត្រូវបានកំណត់ថាត្រូវការការពារឬការយកចិត្តទុកដាក់ពិសេស។

៣- ស្តង់ដាណាមួយត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមមាត្រា៧៤។

## មាត្រា៣៩

## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

១- រដ្ឋភាគីជាលក្ខណៈបុគ្គលឬដោយសហការជាមួយនឹងរដ្ឋភាគីផ្សេងទៀត ត្រូវពិចារណាលើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើផែនការនិងកម្មវិធីដែលទាក់ទងនឹងសកម្មភាពដែលស្ថិតនៅក្រោមយុត្តាធិការឬការគ្រប់គ្រងរបស់ខ្លួនដែលត្រូវធ្វើឡើងនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដើម្បីធ្វើការវាយតម្លៃពីឥទ្ធិពលជាសក្តានុពលនៃផែនការឬកម្មវិធីទាំងនេះ ក៏ដូចជាជម្រើសផ្សេងៗលើបរិស្ថានសមុទ្រ។

២- សន្និសីទកំពូលបណ្តាភាគីអាចធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើទីតាំងឬតំបន់មួយ ដើម្បីប្រមូលផ្តុំនិងសំយោគព័ត៌មានល្អបំផុតអំពីទីតាំងឬតំបន់ទាំងនោះ វាយតម្លៃហេតុប៉ះពាល់បច្ចុប្បន្ននិងសក្តានុពលនាពេលអនាគតនិងកំណត់ពីបញ្ហាកង្វះខាតទិន្នន័យនិងអាទិភាពលើការស្រាវជ្រាវ។

៣- នៅពេលធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានកំណត់នៅក្នុងផ្នែកនេះ រដ្ឋភាគីត្រូវយកចិត្តទុកដាក់ពីលទ្ធផលនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រពាក់ព័ន្ធដូចបានធ្វើឡើងក្នុងកថាខណ្ឌ១និង២ខាងលើ ប្រសិនបើអាចធ្វើបាន។

៤- សន្និសីទកំពូលបណ្តាភាគីត្រូវបង្កើតការណែនាំស្តីពីការប្រព្រឹត្តនៃប្រភេទនីមួយៗលើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដូចបានពិពណ៌នានៅក្នុងមាត្រានេះ។

## ផ្នែកទី៥

## ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ

### មាត្រា៤០

### គោលដៅយថាវត្ថុ

ផ្នែកនេះមានគោលដៅដើម្បី៖

ក- ជួយដល់រដ្ឋភាគី ជាពិសេសរដ្ឋភាគីកំពុងអភិវឌ្ឍ ក្នុងការអនុវត្តនូវបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដើម្បីឱ្យសម្រេចបាននូវគោលដៅរបស់ខ្លួន។

ខ- អនុញ្ញាតឱ្យមានកិច្ចសហប្រតិបត្តិការនិងការចូលរួមប្រកបដោយបរិយាបន្ន សមធម៌និងប្រសិទ្ធភាពក្នុងសកម្មភាពដែលបានអនុវត្តនៅក្នុងកិច្ចព្រមព្រៀងនេះ។

គ- អភិវឌ្ឍសមត្ថភាពផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសមុទ្រ រួមទាំងការទាក់ទងដល់ការស្រាវជ្រាវនៃរដ្ឋភាគីនានា ជាពិសេសរដ្ឋភាគីកំពុងអភិវឌ្ឍដែលទាក់ទងនឹងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងតាមរយៈការទទួលបានបច្ចេកវិទ្យាសមុទ្រដោយរដ្ឋភាគីកំពុងអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យាសមុទ្រទៅកាន់រដ្ឋទាំងនេះ។

ឃ- បង្កើន ផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងស្តីពីការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ង- លើសពីនេះទៅទៀត គឺគាំទ្រដល់រដ្ឋភាគីកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសកំពុងអភិវឌ្ឍមិនជាប់ឆ្នេរសមុទ្រ រដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ រដ្ឋជាប់ឆ្នេរសមុទ្រនៅទ្វីបអាហ្វ្រិក រដ្ឋប្រជុំកោះនិងប្រទេសកំពុងអភិវឌ្ឍមានចំណូលមធ្យម តាមរយៈការកសាងសមត្ថភាពការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ នៅក្រោមកិច្ចព្រមព្រៀងនេះ ដើម្បីធ្វើឱ្យសម្រេចគោលដៅទាក់ទងនឹង៖

១- ធនធានពន្ធុសមុទ្រ រួមទាំងការបែងចែកផលប្រយោជន៍ ដូចបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៩។

២- វិធានការជាឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ ដូចដែលមានកំណត់នៅក្នុងមាត្រា១៧។

៣- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានកំណត់ក្នុងមាត្រា២៧។

### មាត្រា៤១

### កិច្ចសហប្រតិបត្តិការក្នុងការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ

១- រដ្ឋភាគីត្រូវសហការដោយផ្ទាល់ឬតាមរយៈអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់និងតាមវិស័យ ដើម្បីជួយដល់រដ្ឋភាគី ជាពិសេសរដ្ឋភាគីកំពុងអភិវឌ្ឍ ក្នុងការសម្រេចបាននូវគោលដៅនៃកិច្ចព្រមព្រៀងនេះ តាមរយៈការកសាងសមត្ថភាព ការអភិវឌ្ឍ ការផ្ទេរវិទ្យាសាស្ត្រសមុទ្រនិងបច្ចេកវិទ្យាសមុទ្រ។

២- ក្នុងការផ្តល់នូវការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រនៅក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋភាគីត្រូវសហការគ្រប់កម្រិតនិងគ្រប់ទម្រង់ទាំងអស់ រួមទាំងតាមរយៈភាពជាដៃគូនិងមានការចូលរួមពីរដ្ឋភាគីពាក់ព័ន្ធទាំងអស់ តាមការសមស្រប វិស័យឯកជន សង្គមស៊ីវិល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលជាអ្នកថែរក្សាចំណេះដឹងប្រពៃណី ក៏ដូចជាតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ។

៣- ក្នុងការផ្តល់នូវអានុភាពដល់ផ្នែកនេះ រដ្ឋភាគីត្រូវទទួលស្គាល់ពេញលេញលើលក្ខខណ្ឌពិសេសរបស់រដ្ឋភាគីកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសកំពុងអភិវឌ្ឍមិនជាប់ឆ្នេរសមុទ្រ រដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ រដ្ឋជាប់ឆ្នេរសមុទ្រនៅទ្វីបអាហ្វ្រិក រដ្ឋប្រជុំកោះនិងប្រទេសកំពុងអភិវឌ្ឍមានចំណូលមធ្យម។ រដ្ឋភាគីត្រូវធានាថា ការផ្តល់ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រមិនមានលក្ខខណ្ឌលើតម្រូវការនៃរបាយការណ៍ដ៏លំបាកនោះទេ។

## មាត្រា៤២

## បែបបទសម្រាប់ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ

១- រដ្ឋភាគីក្នុងសមត្ថភាពរបស់ខ្លួនត្រូវធានាថា ការកសាងសមត្ថភាពសម្រាប់រដ្ឋភាគីកំពុងអភិវឌ្ឍនឹងត្រូវសហការដើម្បីសម្រេចដល់ការផ្ទេរបច្ចេកវិទ្យាសមុទ្រ ជាពិសេសទៅឱ្យរដ្ឋភាគីកំពុងអភិវឌ្ឍដែលមានតម្រូវការនិងស្នើសុំបច្ចេកវិទ្យាសមុទ្រ ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២- រដ្ឋភាគីត្រូវផ្តល់ធនធានទៅតាមសមត្ថភាពរបស់ខ្លួនដើម្បីគាំទ្រដល់ការកសាងសមត្ថភាព ការអភិវឌ្ឍ ការផ្ទេរបច្ចេកវិទ្យាសមុទ្រ និងជួយសម្រួលដល់ការទទួលបានប្រភពជំនួយផ្សេងៗ ដោយយកចិត្តទុកដាក់លើគោលនយោបាយការងារអាទិភាព ផែនការ និងកម្មវិធីជាតិ។

៣- ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ គួរតែជាការរៀបចំដោយផ្អែកលើតម្រូវការប្រទេសប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងអាចអនុវត្តបានម្តងហើយម្តងទៀត ដែលមានលក្ខណៈបរិយាបន្ន អន្តរវិស័យនិងឆ្លើយតបតាមយេនឌ័រ។ ក្នុងករណីសមស្រប កិច្ចការនេះត្រូវបានបង្កើតឡើងនិងមិនត្រួតគ្នានឹងកម្មវិធីដែលនៅជាធរមាន ហើយផ្អែកលើមេរៀនជាបទពិសោធ រួមទាំងសកម្មភាពកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រនៅក្រោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់អនុតំបន់ និងតាមវិស័យ។ ក្នុងករណីអាចធ្វើបាន គឺការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រត្រូវពិចារណាលើសកម្មភាពទាំងនេះ ដើម្បីបង្កើននូវប្រសិទ្ធភាពនិងលទ្ធផលជាអតិបរមា។

៤- ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រត្រូវពឹងផ្អែកនិងឆ្លើយតបទៅនឹងតម្រូវការនិងអាទិភាពរបស់រដ្ឋភាគីកំពុងអភិវឌ្ឍ ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋភាគីជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ដែលកំណត់តាមរយៈការវាយតម្លៃនូវតម្រូវការ ដោយផ្អែកលើករណីជារូបវន្តម្តងមួយៗ នៅថ្នាក់តំបន់ឬអនុតំបន់។ តម្រូវការនិងអាទិភាពបែបនេះអាចត្រូវបានវាយតម្លៃដោយខ្លួនឯងឬមានការសម្របសម្រួលតាមរយៈគណៈកម្មាធិការកសាងសមត្ថភាពនិងការផ្ទេរគណៈកម្មាធិការបច្ចេកវិទ្យាសមុទ្រនិងយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន។

## មាត្រា៤៣

## គោលនយោបាយបន្ថែមសម្រាប់ការផ្ទេរបច្ចេកវិទ្យាសមុទ្រ

១- រដ្ឋភាគីត្រូវមានចក្ខុវិស័យរយៈពេលវែង អំពីសារៈសំខាន់នៃការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យាពេញលេញសម្រាប់កិច្ចសហប្រតិបត្តិនិងការចូលរួមប្រកបដោយបរិយាបន្ន សមធម៌និងប្រសិទ្ធភាពនៅក្នុងសកម្មភាពដែលបានអនុវត្តស្របតាមកិច្ចព្រមព្រៀងនេះនិងដើម្បីសម្រេចគោលដៅរបស់ខ្លួនយ៉ាងពេញលេញ។

២- ការផ្ទេរបច្ចេកវិទ្យាសមុទ្រដែលធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងដោយយុត្តិធម៌និងក្រោមលក្ខខណ្ឌអំណោយផលបំផុត រួមទាំងលក្ខខណ្ឌសម្បទាន អនុគ្រោះ ស្របតាមការព្រមព្រៀងនិងលក្ខខណ្ឌយោគយល់គ្នាទៅវិញទៅមក ព្រមទាំងស្របនឹងគោលដៅនៃកិច្ចព្រមព្រៀងនេះ។

៣- រដ្ឋភាគីត្រូវលើកកម្ពស់និងលើកទឹកចិត្តឱ្យគោរពតាមលក្ខខណ្ឌសេដ្ឋកិច្ចនិងច្បាប់សម្រាប់ការផ្ទេរបច្ចេកវិទ្យាសមុទ្រទៅឱ្យរដ្ឋភាគីកំពុងអភិវឌ្ឍ ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ដែលអាចរាប់បញ្ចូលទាំងការផ្តល់នូវការលើកទឹកចិត្តដល់សហគ្រាសនិងស្ថាប័ននានា។

៤- ការផ្ទេរបច្ចេកវិទ្យាសមុទ្រត្រូវគិតគូរពីភាពត្រឹមត្រូវទាំងអស់លើបច្ចេកវិទ្យាទាំងនោះ ហើយត្រូវបានអនុវត្តដោយគិតគូរដល់ផលប្រយោជន៍ធម្មានុរូបទាំងអស់ រួមទាំងសិទ្ធិនិងកាតព្វកិច្ចរបស់ម្ចាស់បច្ចេកវិទ្យា អ្នកផ្គត់ផ្គង់ និងអ្នកទទួលបច្ចេកវិទ្យាសមុទ្រ និងធ្វើការដោយការយកចិត្តទុកដាក់ជាពិសេសលើផលប្រយោជន៍និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍ ដើម្បីឈានទៅសម្រេចគោលដៅនៃកិច្ចព្រមព្រៀងនេះ។

៥- បច្ចេកវិទ្យាសមុទ្រដែលត្រូវបានផ្ទេរ ដោយអនុលោមតាមផ្នែកនេះត្រូវមានភាពសមស្រប មានភាពចាំបាច់ និងក្នុងវិសាលភាពដែលអាចធ្វើបាន បច្ចេកវិទ្យានោះគួរឱ្យទុកចិត្ត តម្លៃសមរម្យ ទាន់សម័យ មិនប៉ះពាល់បរិស្ថាន និងអាចកែមកប្រើប្រាស់បានដោយរដ្ឋភាគីកំពុងអភិវឌ្ឍ ដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសរបស់រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច។

## មាត្រា៤៤

## ប្រភេទនៃការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ

១- ដើម្បីគាំទ្រដល់គោលដៅដូចមានចែងក្នុងមាត្រា៤០ អាចរួមបញ្ចូលនូវប្រភេទនៃការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ប៉ុន្តែមិនបានកំណត់គាំទ្រដល់ការបង្កើតឬលើកកម្ពស់សមត្ថភាពលើការគ្រប់គ្រងធនធានមនុស្ស សមត្ថភាពអនុវត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា ស្ថាប័ន និងសមត្ថភាពធនធានផ្សេងទៀតរបស់រដ្ឋភាគី ដូចជា៖

ក- ការចែករំលែកនិងការប្រើប្រាស់ទិន្នន័យ ព័ត៌មាន ចំណេះដឹង និងលទ្ធផលស្រាវជ្រាវពាក់ព័ន្ធ។

ខ- ការផ្សព្វផ្សាយព័ត៌មាននិងការលើកកម្ពស់ការយល់ដឹង រួមទាំងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ស្របតាមការការព្រមព្រៀងដោយទទួលបានគ្រប់គ្រាន់ជាមុននិងដោយមិនគិតថ្លៃពីជនជាតិដើមភាគតិច សហគមន៍មូលដ្ឋានទាំងនេះ ក្នុងករណីសមស្រប។

គ- ការអភិវឌ្ឍនិងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ រួមទាំងឧបករណ៍និងសមត្ថភាពបុគ្គលិកសម្រាប់ការប្រើប្រាស់និងថែទាំបច្ចេកវិទ្យានោះ។

ឃ- ការអភិវឌ្ឍនិងការពង្រឹងសមត្ថភាពស្ថាប័ននិងក្របខ័ណ្ឌច្បាប់ឬយន្តការជាតិ។

ង- ការអភិវឌ្ឍ ការពង្រឹងសមត្ថភាពធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុនិងជំនាញបច្ចេកទេស តាមរយៈការផ្លាស់ប្តូរ ការសហការស្រាវជ្រាវ ការគាំទ្របច្ចេកទេស ការអប់រំ ការបណ្តុះបណ្តាល និងការផ្ទេរបច្ចេកវិទ្យាសមុទ្រ។

ច- ការអភិវឌ្ឍ ការចែករំលែកឯកសារណែនាំ គោលការណ៍ណែនាំ និងស្តង់ដា។

ឆ- ការអភិវឌ្ឍកម្មវិធីបច្ចេកទេស វិទ្យាសាស្ត្រនិងស្រាវជ្រាវ និងកម្មវិធីអភិវឌ្ឍន៍។

ជ- ការអភិវឌ្ឍ ការពង្រឹងសមត្ថភាពនិងឧបករណ៍បច្ចេកវិទ្យាសម្រាប់ការត្រួតពិនិត្យ ការគ្រប់គ្រងនិងការតាមដានឃ្លាំមើលប្រកបដោយប្រសិទ្ធភាពនៃសកម្មភាពក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ។

២- ព័ត៌មានលម្អិតបន្ថែមអំពីប្រភេទនៃការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រដែលបានកំណត់ក្នុងមាត្រានេះ ត្រូវបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធII។

៣- សន្និសីទកំពូលបណ្តាភាគីផ្តល់ការយកចិត្តទុកដាក់លើអនុសាសន៍ របស់គណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ ត្រូវធ្វើឡើងតាមកាលកំណត់ ក្នុងករណីចាំបាច់ ពិនិត្យ វាយតម្លៃ អភិវឌ្ឍបន្ថែម និងផ្តល់[illegible]ណែនាំដើម្បីធ្វើឱ្យបានត្រឹមត្រូវនិងដែលមិនទាន់ពេញលេញនៃប្រភេទការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធII ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពនិងនវានុវត្តន៍បច្ចេកវិទ្យា ដើម្បីឆ្លើយតបឱ្យស្របទៅនឹងតម្រូវការវិវត្តរបស់រដ្ឋ អនុតំបន់ និងតំបន់។

### មាត្រា៤៥
### ការត្រួតពិនិត្យនិងការពិនិត្យវាយតម្លៃ

១- ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដែលធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកនេះ នឹងត្រូវត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំ។

២- ការត្រួតពិនិត្យនិងការពិនិត្យវាយតម្លៃ ដូចដែលមានកំណត់ក្នុងកថាខណ្ឌ១ខាងលើ ត្រូវធ្វើឡើងដោយគណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ នៅក្រោមការផ្តល់សិទ្ធិអំណាចពីសន្និសីទកំពូលបណ្តាភាគី ហើយត្រូវមានគោលដៅ៖

ក- វាយតម្លៃ ពិនិត្យពីតម្រូវការនិងអាទិភាពនៃការអភិវឌ្ឍរដ្ឋភាគីកំពុងអភិវឌ្ឍ ដែលទាក់ទងនឹងការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការពិសេសនៃរដ្ឋភាគីកំពុងអភិវឌ្ឍនិងកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច អនុលោមតាមមាត្រា៤២ កថាខណ្ឌ៤។

ខ- ពិនិត្យវាយតម្លៃលើការគាំទ្រនូវតម្រូវការ ត្រូវផ្តល់ជូននិងត្រូវកៀរគរ ក៏ដូចជាកង្វះខាតក្នុងការបំពេញតម្រូវការដែលបានវាយតម្លៃនៃរដ្ឋភាគីកំពុងអភិវឌ្ឍទាក់ទងនឹងកិច្ចព្រមព្រៀងនេះ។

គ- ការកំណត់រកនិងកៀរគរមូលនិធិ នៅក្រោមយន្តការហិរញ្ញវត្ថុដែលបានបង្កើតឡើងក្នុងមាត្រា៥២ ដើម្បីអភិវឌ្ឍនិងអនុវត្តការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ រួមទាំងសម្រាប់ការវាយតម្លៃនូវតម្រូវការ។

ឃ- ការវាស់វែងការអនុវត្តដោយផ្អែកលើសូចនាករដែលបានព្រមព្រៀងនិងការពិនិត្យវាយតម្លៃការវិភាគដោយផ្អែកលើលទ្ធផល វឌ្ឍនភាព រួមទាំងលទ្ធផលដែលសម្រេចបាន និងប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ នៅក្រោមកិច្ចព្រមព្រៀងនេះ ព្រមទាំងភាពជោគជ័យនិងបញ្ហាប្រឈមនានា។

ង- ផ្តល់អនុសាសន៍សម្រាប់សកម្មភាពបន្តពិនិត្យតាមដាន រួមទាំងអំពីអភិក្រមដែលអាចពង្រឹងបន្ថែមទៀតក្នុងការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដើម្បីឱ្យរដ្ឋភាគីកំពុងអភិវឌ្ឍយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ពង្រឹងការអនុវត្តកិច្ចព្រមព្រៀង ដើម្បីសម្រេចគោលដៅរបស់ខ្លួន។

៣- ក្នុងការគាំទ្រដល់ការត្រួតពិនិត្យនិងការវាយតម្លៃលើការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ រដ្ឋភាគីត្រូវដាក់របាយការណ៍ទៅគណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ។ របាយការណ៍ទាំងនោះគួរតែស្ថិតក្នុងទម្រង់មួយនិងនៅក្នុងចន្លោះពេលណាមួយ ដែលត្រូវបានកំណត់ដោយសន្និសីទកំពូលបណ្តាភាគី ដោយយកចិត្តទុកដាក់លើអនុសាសន៍របស់គណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ។ ក្នុងការដាក់របាយការណ៍របស់ខ្លួន ដោយករណីអាចអនុវត្តបាន រដ្ឋភាគីត្រូវយកចិត្តទុកដាក់លើធាតុចូលពីអង្គភាពថ្នាក់តំបន់និងអនុតំបន់លើការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ។ របាយការណ៍ដែលដាក់ជូនដោយរដ្ឋភាគី ក៏ដូចជាធាតុចូលពីស្ថាប័នថ្នាក់តំបន់និងអនុតំបន់ស្តីពីការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ សន្និសីទកំពូលបណ្តាភាគីត្រូវធានាថា លក្ខខណ្ឌតម្រូវក្នុងការរាយការណ៍គួរត្រូវបានធ្វើឡើងក្នុងទម្រង់សាមញ្ញនិងមិនពិបាក ជាពិសេសសម្រាប់រដ្ឋភាគីកំពុងអភិវឌ្ឍ រួមទាំងលក្ខខណ្ឌក្នុងការចំណាយនិងធនធានពេលវេលាផងដែរ។

### មាត្រា៤៦

### គណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ

១- គណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រត្រូវបានបង្កើតឡើងដោយស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ។

២- គណៈកម្មាធិការត្រូវមានសមាជិកដែលមានគុណវុឌ្ឍិនិងជំនាញឯកទេសសមស្រប ដើម្បីបម្រើផលប្រយោជន៍ល្អបំផុតតាមការកំណត់ក្នុងកិច្ចព្រមព្រៀង ត្រូវបានតែងតាំងដោយរដ្ឋភាគីនិងជ្រើសរើសដោយសន្និសីទតំណាងបណ្ដាភាគី ដោយយកចិត្តទុកដាក់លើតុល្យភាពយេនឌ័រនិងការបែងចែកប្រកបដោយសមធម៌តាមភូមិសាស្ត្រនិងមានតំណាងក្នុងគណៈកម្មាធិការមកពីប្រទេសអភិវឌ្ឍតិចតួច រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ និងប្រទេសមិនជាប់នឹងសមុទ្រកំពុងអភិវឌ្ឍ។ ការពិពណ៌នាពីលក្ខខណ្ឌការងារនិងបែបបទសម្រាប់ប្រតិបត្តិការរបស់គណៈកម្មាធិការត្រូវសម្រេចដោយសន្និសីទបណ្ដារដ្ឋភាគីនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។

៣- គណៈកម្មាធិការនេះត្រូវដាក់បញ្ជូនរបាយការណ៍និងអនុសាសន៍ដែលសន្និសីទតំណាងបណ្ដាភាគីពិចារណានិងមានចំណាត់ការ ក្នុងករណីសមស្រប។

## ផ្នែកទី៦

## ការរៀបចំស្ថាប័ន

### មាត្រា៤៧

### សន្និសីទតំណាងបណ្ដាភាគី

១- សន្និសីទតំណាងបណ្ដាភាគីត្រូវបានបង្កើតឡើង នៅក្រោមកិច្ចព្រមព្រៀងនេះ។

២- កិច្ចប្រជុំលើកដំបូងនៃសន្និសីទតំណាងបណ្ដាភាគីត្រូវកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិមិនលើសពី១(មួយ)ឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ បន្ទាប់មក កិច្ចប្រជុំសាមញ្ញនៃសន្និសីទតំណាងបណ្ដាភាគីត្រូវធ្វើឡើងនៅចន្លោះពេលទៀងទាត់ ដែលកំណត់ដោយសន្និសីទតំណាងបណ្ដាភាគី។ កិច្ចប្រជុំវិសាមញ្ញនៃសន្និសីទតំណាងបណ្ដាភាគី អាចធ្វើឡើង នៅពេលផ្សេងទៀត ស្របតាមវិធាននៃនីតិវិធី។

៣- សន្និសីទតំណាងបណ្ដាភាគីត្រូវប្រជុំជាសាមញ្ញ នៅទីតាំងនៃលេខាធិការដ្ឋានឬនៅទីស្នាក់ការអង្គការសហប្រជាជាតិ។

៤- សន្និសីទតំណាងបណ្ដាភាគីត្រូវអនុម័តដោយកុងសង់ស៊ុស នៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន វិធាននៃនីតិវិធីសម្រាប់សន្និសីទតំណាងនិងអង្គភាពបុត្រសម្ព័ន្ធរបស់ខ្លួន វិធានហិរញ្ញវត្ថុដែលគ្រប់គ្រងមូលនិធិនិងការផ្តល់មូលនិធិរបស់លេខាធិការដ្ឋាននិងអង្គភាពបុត្រសម្ព័ន្ធណាមួយ ហើយបន្ទាប់ពីនោះ វិធាននៃនីតិវិធីនិងវិធានហិរញ្ញវត្ថុសម្រាប់អង្គភាពបុត្រសម្ព័ន្ធណាមួយដែលខ្លួនអាចបង្កើតបាន។ រហូតមកដល់ពេលអនុម័តវិធាននៃនីតិវិធី វិធាននៃនីតិវិធីនៃសន្និសីទអន្តររដ្ឋាភិបាលស្តីពីលិខិតុបករណ៍ជាប់កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ នៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រអំពីការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រនៃតំបន់ក្រៅដែនយុត្តាធិការជាតិដែលត្រូវអនុវត្ត។

៥- សន្និសីទតំណាងបណ្ដាភាគីត្រូវខិតខំប្រឹងប្រែងដើម្បីអនុម័តសេចក្តីសម្រេចនិងអនុសាសន៍ជាកុងសង់ស៊ុស។ លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ប្រសិនបើកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើអស់ពីលទ្ធភាព ហើយនៅតែមិនអាចទទួលបានសំឡេងកុងសង់ស៊ុសនោះ ការសម្រេចចិត្តនិងអនុសាសន៍នៃសន្និសីទតំណាងបណ្ដា

ភាគីស្តីពីបញ្ហាជាសារវន្ត នឹងត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីដែលមានវត្តមាននិងបោះឆ្នោត និងការសម្រេចចិត្តលើបញ្ហានីតិវិធីត្រូវអនុម័តដោយសំឡេងភាគច្រើននៃរដ្ឋភាគីដែលមានវត្តមាននិងបោះឆ្នោត។

៦- សន្និសីទកំពូលបណ្តាភាគីត្រូវបន្តត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយតាមរយៈគោលដៅនេះត្រូវ៖

ក- អនុម័តសេចក្តីសម្រេចនិងអនុសាសន៍ទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

ខ- ពិនិត្យវាយតម្លៃនិងសម្របសម្រួលការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមរដ្ឋភាគីពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

គ- លើកកម្ពស់ រួមទាំងបង្កើតដំណើរការនៃកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលសមស្របជាមួយនឹងក្នុងចំណោមអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ក្នុងគោលដៅលើកកម្ពស់ភាពស៊ីចង្វាក់គ្នានៃកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ឃ- ក្នុងករណីយល់ឃើញថាចាំបាច់ បង្កើតអង្គភាពបុត្រសម្ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

ង- អនុម័តថវិកាដោយសំឡេងភាគច្រើនបីភាគបួននៃរដ្ឋភាគីដែលមានវត្តមាន ហើយបោះឆ្នោត ប្រសិនបើកិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីទទួលបានសំឡេងកុងសង់ស៊ុសដោយមិនអាចទទួលបានសំឡេងគ្រប់គ្រាន់ ច្រើនផង និងសម្រាប់រយៈពេលហិរញ្ញវត្ថុមួយណានេះ សន្និសីទកំពូលអាចសម្រេចលើថវិកាបាន។

ច- អនុវត្តមុខងារផ្សេងទៀតដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះឬតាមការចាំបាច់សម្រាប់ការអនុវត្តកិច្ចព្រមព្រៀង។

៧- សន្និសីទកំពូលបណ្តាភាគី អាចសម្រេចស្នើសុំតុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រឱ្យផ្តល់យោបល់លើបញ្ហានីត្យានុកូលស្តីពីការអនុលោមភាពតាមកិច្ចព្រមព្រៀងនៃសំណើមួយ នៅចំពោះមុខសន្និសីទកំពូលបណ្តាភាគីអំពីបញ្ហាណាមួយនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។ សំណើសុំមតិយោបល់ មិនត្រូវធ្វើឡើងចំពោះបញ្ហាដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃអង្គភាពផ្សេងៗទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ ឬតាមវិស័យ ឬលើបញ្ហាពាក់ព័ន្ធជាចាំបាច់នឹងការពិចារណាជាមួយគ្នានៃជម្លោះណាមួយដែលទាក់ទងនឹងអធិបតេយ្យភាពឬសិទ្ធិផ្សេងទៀតលើដែនដីនៅតាមទ្វីបឬដែនកោះ ឬលើការទាមទារជម្លោះឬស្ថានភាពផ្លូវច្បាប់នៃតំបន់មួយ ដែលស្ថិតនៅក្នុងដែនយុត្តាធិការជាតិ។ សំណើនោះត្រូវបញ្ជាក់ពីវិសាលភាពនៃបញ្ហានីត្យានុកូល ដែលត្រូវស្នើសុំមតិយោបល់។ សន្និសីទកំពូលបណ្តាភាគីអាចស្នើសុំឱ្យផ្តល់យោបល់បែបនេះជាបញ្ហាបន្ទាន់។

៨- សន្និសីទកំពូលបណ្តាភាគី នៅក្នុងរយៈពេល៥(ប្រាំ)ឆ្នាំនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់ពីនោះគឺនៅចន្លោះពេលនេះត្រូវកំណត់ដោយសន្និសីទកំពូល ត្រូវវាយតម្លៃនិងពិនិត្យវាយតម្លៃពីភាពគ្រប់គ្រាន់និងប្រសិទ្ធភាពនៃបទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះ ហើយក្នុងករណីចាំបាច់ ស្នើសុំមធ្យោបាយដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងនោះដើម្បីឆ្លើយតបឱ្យកាន់តែប្រសើរឡើងចំពោះការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

## មាត្រា៤៨

## តម្លាភាព

១- សន្និសីទកំពូលបណ្តាភាគីត្រូវលើកកម្ពស់ពីតម្លាភាពក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងសកម្មភាពផ្សេងទៀតដែលត្រូវអនុវត្ត នៅក្រោមកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- រាល់កិច្ចប្រជុំនៃសន្និសីទកំពូលបណ្ដាភាគីនិងអង្គភាពបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវបើកទូលាយឱ្យអ្នកសង្កេតការណ៍ចូលរួម ដោយអនុលោមតាមវិធាននៃនីតិវិធី លើកលែងតែមានការសម្រេចផ្សេងពីសន្និសីទកំពូលបណ្ដាភាគី។ សន្និសីទកំពូលបណ្ដាភាគីត្រូវផ្សព្វផ្សាយនិងរក្សានូវកំណត់ត្រាជាសាធារណៈអំពីការសម្រេចរបស់ខ្លួន។

៣- សន្និសីទកំពូលបណ្ដាភាគីត្រូវលើកកម្ពស់ពីតម្លាភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំងតាមរយៈការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មាននិងការសម្របសម្រួលឱ្យមានការចូលរួមនិងមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធ នៅថ្នាក់អនុតំបន់ តំបន់ និងថ្នាក់ពិភពលោក និងតាមវិស័យ ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលមានចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ សហគមន៍វិទ្យាសាស្ត្រ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការសមស្របនិងស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

៤- តំណាងរដ្ឋដែលមិនមែនជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ អង្គភាពពាក់ព័ន្ធតាមវិស័យនិងនៅថ្នាក់អនុតំបន់តំបន់និងថ្នាក់ពិភពលោក ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលមានចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ សហគមន៍វិទ្យាសាស្ត្រ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលមានចំណាប់អារម្មណ៍លើបញ្ហាទាក់ទងនឹងសន្និសីទកំពូលបណ្ដាភាគី អាចស្នើសុំឱ្យចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំនៃសន្និសីទកំពូលបណ្ដាភាគីនិងអង្គភាពបុត្រសម្ព័ន្ធរបស់ខ្លួន។ វិធាននៃនីតិវិធីរបស់សន្និសីទកំពូលបណ្ដាភាគីត្រូវផ្ដល់បែបបទសម្រាប់ការចូលរួមបែបនេះ ហើយមិនត្រូវមានការរឹតត្បិតហួសហេតុពេកនោះទេលើករណីនេះ។ វិធាននៃនីតិវិធីនេះក៏ត្រូវផ្ដល់ឱ្យអ្នកតំណាងទាំងនោះទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ទាន់ពេលវេលា។

## មាត្រា៤៩

## អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស

១- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។

២- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវមានសមាជិក ដែលបំពេញការងារតាមសមត្ថភាពជំនាញរបស់ខ្លួននិងក្នុងផលប្រយោជន៍ល្អបំផុតនៃកិច្ចព្រមព្រៀង ត្រូវបានតែងតាំងដោយរដ្ឋភាគីនិងជ្រើសរើសដោយសន្និសីទកំពូលបណ្ដាភាគីដែលមានគុណវុឌ្ឍិសមស្រប ដោយយកចិត្តទុកដាក់លើតម្រូវការឱ្យមានជំនាញអន្តរវិស័យ រួមទាំងជំនាញវិទ្យាសាស្ត្រនិងបច្ចេកទេសពាក់ព័ន្ធនិងជំនាញ ក្នុងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនៃជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន តុល្យភាពយេនឌ័រ និងតំណាងភូមិសាស្ត្រប្រកបដោយសមធម៌។ ការពិពណ៌នាពីលក្ខខណ្ឌការងារនិងបែបបទសម្រាប់ប្រតិបត្តិការនៃអង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេស រួមទាំងដំណើរការជ្រើសរើសរបស់ខ្លួននិងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់សមាជិក ដែលត្រូវបានកំណត់ដោយសន្និសីទកំពូលបណ្ដាភាគីនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។

៣- អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសអាចទទួលយកមតិយោបល់សមស្របពីអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ព្រមទាំងពីអ្នកវិទ្យាសាស្ត្រនិងអ្នកជំនាញផ្សេងទៀត ប្រសិនមានតម្រូវការចាំបាច់។

៤- នៅក្រោមសិទ្ធិអំណាចនិងគោលការណ៍ណែនាំរបស់សន្និសីទកំពូលបណ្ដាភាគី ដោយយកចិត្តទុកដាក់លើជំនាញពហុវិស័យ ដូចមានចែងក្នុងកថាខណ្ឌ២ខាងលើ អង្គភាពវិទ្យាសាស្ត្រនិងបច្ចេកទេសត្រូវផ្ដល់មតិយោបល់ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសដល់សន្និសីទកំពូលបណ្ដាភាគី បំពេញមុខងារដែលបានប្រគល់ជូនខ្លួននៅក្នុងកិច្ចព្រមព្រៀង តាមកិច្ចព្រមព្រៀងនេះនិងមុខងារផ្សេងទៀតដែលអាចត្រូវបានកំណត់ដោយសន្និសីទកំពូលបណ្ដាភាគី ទៀងទាត់ធ្វើរបាយការណ៍ទៅសន្និសីទកំពូលបណ្ដាភាគីស្ដីពីការងាររបស់ខ្លួន។

### មាត្រា៥០

### លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានមួយត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។ សន្និសីទកំពូលបណ្តាភាគីនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ត្រូវធ្វើការរៀបចំពីការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន រួមទាំងការសម្រេចលើទីស្នាក់ការកណ្តាលរបស់ខ្លួន។

២- រហូតដល់ពេលលេខាធិការដ្ឋានចាប់ផ្តើមបំពេញមុខងាររបស់ខ្លួន អគ្គលេខាធិការអង្គការសហប្រជាជាតិតាមរយៈអង្គភាពកិច្ចការមហាសមុទ្រនិងច្បាប់សមុទ្រនៃការិយាល័យកិច្ចការនីត្យានុកូលរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ ត្រូវបំពេញមុខងារដោយលេខាធិការដ្ឋាន នៅក្នុងកិច្ចព្រមព្រៀងនេះ។

៣- លេខាធិការដ្ឋាននិងរដ្ឋម្ចាស់ផ្ទះអាចបញ្ចប់កិច្ចព្រមព្រៀងស្តីពីទីស្នាក់ការកណ្តាលនេះបាន។ លេខាធិការដ្ឋានត្រូវទទួលបានសមត្ថភាពនីត្យានុកូលនៅលើដែនដីនៃរដ្ឋម្ចាស់ផ្ទះ ហើយត្រូវមានឯកសិទ្ធិនិងអភ័យឯកសិទ្ធិទាំងនោះពីរដ្ឋម្ចាស់ផ្ទះតាមការចាំបាច់សម្រាប់ការអនុវត្តនូវមុខងាររបស់ខ្លួន។

៤- លេខាធិការដ្ឋានត្រូវ៖

ក- ផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងភស្តុភារដល់សន្និសីទកំពូលបណ្តាភាគីនិងអង្គភាពបុត្រសម្ព័ន្ធរបស់ខ្លួនសម្រាប់គោលដៅនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។

ខ- រៀបចំនិងផ្តល់សេវាដល់កិច្ចប្រជុំសន្និសីទកំពូលបណ្តាភាគីនិងអង្គភាពផ្សេងៗទៀត ដែលអាចត្រូវបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងនេះឬដោយសន្និសីទកំពូលបណ្តាភាគី។

គ- ផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យបានទាន់ពេលវេលា រួមទាំងសេចក្តីសម្រេចរបស់សន្និសីទកំពូលបណ្តាភាគី ជាសាធារណៈ និងបញ្ជូនព័ត៌មានទាំងនោះទៅគ្រប់រដ្ឋភាគី ព្រមទាំងអង្គភាពទទួលបន្ទុកលើលិខិតុបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់និងតាមវិស័យ។

ឃ- ក្នុងករណីសមស្រប ត្រូវធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួល ជាមួយលេខាធិការដ្ឋាននៃអង្គភាពអន្តរជាតិពាក់ព័ន្ធផ្សេងទៀត ហើយជាពិសេស ចូលរួមរៀបចំរដ្ឋបាលនិងកិច្ចសន្យា នៅពេលមានតម្រូវការនិងសម្រាប់ការបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដោយមានការយល់ព្រមពីសន្និសីទកំពូលបណ្តាភាគី។

ង- រៀបចំរបាយការណ៍ស្តីពីការអនុវត្តមុខងាររបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ ហើយបញ្ជូនវាទៅសន្និសីទកំពូលបណ្តាភាគី។

ច- ផ្តល់ជំនួយដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះនិងអនុវត្តមុខងារផ្សេងទៀតដូចបានកំណត់ដោយសន្និសីទកំពូលបណ្តាភាគីឬត្រូវបានប្រគល់ឱ្យ នៅក្នុងកិច្ចព្រមព្រៀងនេះ។

### មាត្រា៥១

### យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន

១- យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។

២- យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានត្រូវមានជាចម្បងនៃវេទិកាផ្តល់ព័ត៌មានដោយមិនគិតថ្លៃ។ គំរូមធ្យោបាយជាក់លាក់សម្រាប់ប្រតិបត្តិការនៃយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ត្រូវកំណត់ដោយសន្និសីទកំពូលបណ្តាភាគី។

៣- យន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានត្រូវ៖

ក- ជាវេទិកាកណ្ដាលមួយដើម្បីឱ្យរដ្ឋភាគីអាចទទួល ផ្ដល់និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងសកម្មភាពដែលបានអនុវត្ត ដោយអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រួមទាំងព័ត៌មានទាក់ទងនឹងៈ

១- ធនធានពន្ធុសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដូចដែលមានចែងក្នុងផ្នែកទីII នៃកិច្ចព្រមព្រៀងនេះ។

២- ការបង្កើតនិងការអនុវត្តនូវឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ។

៣- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

៤- សំណើសុំការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យានិងឱកាសសមុទ្រដែលមានចែងក្នុងកិច្ចព្រមព្រៀង រួមទាំងឱកាសសហការស្រាវជ្រាវនិងបណ្ដុះបណ្ដាល ព័ត៌មានស្ដីពីប្រភពនិងភាពអាចរកបាននៃព័ត៌មាននិងទិន្នន័យបច្ចេកវិទ្យាសម្រាប់ផ្ទេរបច្ចេកវិទ្យាសមុទ្រ ឱកាសសម្រាប់ការសម្រួលដល់ការទទួលបាននូវបច្ចេកវិទ្យាសមុទ្រ និងព័ត៌មានអំពីការផ្ដល់មូលនិធិ។

ខ- សម្របសម្រួលផ្គូផ្គងនូវតម្រូវក្នុងការកសាងសមត្ថភាពដោយមានការគាំទ្រ បើអាចរកបាននិងដោយមានអ្នកផ្ដល់ដើម្បីផ្ទេរបច្ចេកវិទ្យាសមុទ្រ រួមទាំងស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬវិស័យឯកជនដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមជាម្ចាស់ជំនួយក្នុងការផ្ទេរបច្ចេកវិទ្យាសមុទ្រនិងជួយសម្រួលឱ្យទទួលបានចំណេះដឹងនិងជំនាញពាក់ព័ន្ធ។

គ- ផ្ដល់តំណភ្ជាប់ព័ត៌មានទៅកាន់យន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មានថ្នាក់សាកល តំបន់ អនុតំបន់ថ្នាក់ជាតិ និងតាមវិស័យ និងធនាគារពន្ធុផ្សេងទៀត កន្លែងផ្ទុកទិន្នន័យនិងមូលដ្ឋានទិន្នន័យ រួមទាំងតំណភ្ជាប់ព័ត៌មាន ទាក់ទងនឹងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនិងជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន ហើយផ្សព្វផ្សាយតាមលទ្ធភាពអាចធ្វើ តំណភ្ជាប់ព័ត៌មាន ជាមួយនឹងវេទិកាឯកជននិងមិនមែនរដ្ឋាភិបាលផ្សព្វផ្សាយជាសាធារណៈសម្រាប់ការផ្លាស់ប្ដូរព័ត៌មាន។

ឃ- បង្កើតឡើងដោយផ្អែកលើស្ថាប័នទទួលបន្ទុកយន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មាននៅថ្នាក់សាកល តំបន់និងអនុតំបន់ ក្នុងករណីអនុវត្តបាន នៅពេលបង្កើតយន្តការថ្នាក់តំបន់និងអនុតំបន់ ស្ថិតនៅក្រោមយន្តការសាកលនេះ។

ង- លើកកម្ពស់តម្លាភាពដែលបានកែលម្អ រួមទាំងតាមរយៈការសម្របសម្រួល ការចែករំលែកទិន្នន័យនិងព័ត៌មានមូលដ្ឋានស្ដីពីបរិស្ថានទាក់ទងនឹងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិរវាងរដ្ឋភាគីនិងរដ្ឋភាគីពាក់ព័ន្ធដទៃទៀត។

ច- សម្របសម្រួលកិច្ចសហប្រតិបត្តិការនិងកិច្ចសហការអន្តរជាតិ រួមទាំងកិច្ចសហប្រតិបត្តិការនិងកិច្ចផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស។

ឆ- អនុវត្តមុខងារផ្សេងទៀតដូចដែលអាចត្រូវបានកំណត់ដោយសន្និសីទកំពូលបណ្ដាភាគីឬប្រគល់ឱ្យខ្លួននៅក្នុងកិច្ចព្រមព្រៀងនេះ។

៤- យន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មានត្រូវគ្រប់គ្រងដោយលេខាធិការដ្ឋាន ដោយគ្មានការរើសអើងចំពោះកិច្ចសហប្រតិបត្តិការដែលអាចធ្វើបាន ជាមួយអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ដែលកំណត់ដោយសន្និសីទកំពូលបណ្ដាភាគី រួមទាំងគណៈកម្មាធិការមហាសមុទ្រអន្តររដ្ឋាភិបាលនៃអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ អាជ្ញាធរបាតសមុទ្រអន្តរជាតិ អង្គការសមុទ្រអន្តរជាតិ និងអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ។

៥- នៅក្នុងការគ្រប់គ្រងយន្តការសម្របសម្រួលនិងផ្លាស់ប្ដូរព័ត៌មាន ត្រូវផ្ដល់ការទទួលស្គាល់ពេញលេញដល់តម្រូវការពិសេសនៃរដ្ឋភាគីកំពុងអភិវឌ្ឍ ក៏ដូចជាកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ ហើយលទ្ធភាពត្រូវប្រើប្រាស់យន្តការសម្របសម្រួលនេះដើម្បីឱ្យរដ្ឋទាំងនោះ អាចប្រើប្រាស់យន្តការដោយគ្មានឧបសគ្គឬគ្មានបន្ទុកធ្ងន់ធ្ងរ។ ព័ត៌មានត្រូវដាក់បញ្ចូលទៅក្នុងសកម្មភាពលើកកម្ពស់ការចែករំលែកព័ត៌មាន ការលើកកម្ពស់ការយល់ដឹងនិងការផ្សព្វផ្សាយនៅក្នុងនិងជាមួយរដ្ឋទាំងនោះ ក៏ដូចជាការផ្ដល់កម្មវិធីជាក់លាក់ដល់រដ្ឋទាំងនោះ។

៦- ការរក្សាការសម្ងាត់នៃព័ត៌មានដែលបានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះនិងសិទ្ធិដែលមានចែងនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវទទួលបានការគោរព។ គ្មានខ្លឹមសារណាមួយនៅក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវបានបកស្រាយថាត្រូវចែករំលែកព័ត៌មានដែលត្រូវបានហាមឃាត់មិនឱ្យផ្សព្វផ្សាយ នៅក្រោមច្បាប់ក្នុងប្រទេសរបស់រដ្ឋភាគីឬច្បាប់ជាធរមានផ្សេងទៀត។

## ផ្នែកទី៧

## ធនធានហិរញ្ញវត្ថុនិងយន្តការហិរញ្ញវត្ថុ

### មាត្រា៥២

### ការផ្តល់មូលនិធិ

១- រដ្ឋភាគីនីមួយៗត្រូវផ្តល់ធនធាន តាមសមត្ថភាពរបស់ខ្លួនដែលទាក់ទងនឹងសកម្មភាពទាំងនោះដោយមានបំណងចង់ឱ្យសម្រេចនូវគោលដៅនៃកិច្ចព្រមព្រៀងនេះ ដោយយកចិត្តទុកដាក់លើគោលនយោបាយ អាទិភាព ផែនការ និងកម្មវិធីជាតិរបស់ខ្លួន។

២- អង្គភាពដែលបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវទទួលបានមូលនិធិតាមរយៈការផ្តល់វិភាគទានដែលបានវាយតម្លៃរបស់រដ្ឋភាគី។

៣- យន្តការសម្រាប់ការផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់អាចចូលរួម ដំណើរការបាន ថ្មីនិងបន្ថែម និងអាចព្យាករបាននៅក្នុងកិច្ចព្រមព្រៀង តាមកិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើង។ យន្តការនេះនឹងជួយដល់រដ្ឋភាគីកំពុងអភិវឌ្ឍក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំងតាមរយៈការផ្តល់មូលនិធិក្នុងការគាំទ្រដល់ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រនិងអនុវត្តមុខងារផ្សេងទៀតដែលមានចែងក្នុងមាត្រានេះសម្រាប់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រ។

៤- យន្តការត្រូវមាន៖

ក- មូលនិធិស្ម័គ្រចិត្តពិសេស ដែលត្រូវបង្កើតឡើងដោយសន្និសីទកំពូលបណ្តាភាគី ដើម្បីជួយដល់ការចូលរួមរបស់តំណាងនៃរដ្ឋភាគីកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសមិនជាប់សមុទ្រកំពុងអភិវឌ្ឍនិងរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ នៅក្នុងកិច្ចប្រជុំនានារបស់អង្គភាពដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។

ខ- មូលនិធិពិសេសមួយដែលត្រូវទទួលបានមូលនិធិ ពីប្រភពដូចខាងក្រោម៖

១- ការរួមវិភាគទានប្រចាំឆ្នាំ ស្របតាមមាត្រា១៤ កថាខណ្ឌ៦។

២- ការបង់សាច់ប្រាក់ ដូចមានកំណត់ក្នុងមាត្រា១៤ កថាខណ្ឌ៧។

៣- ការរួមវិភាគទានបន្ថែមពីរដ្ឋភាគីនិងវិស័យឯកជនដែលមានបំណងផ្តល់ធនធានហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

គ- មូលនិធិពិសេសនៃមូលនិធិបរិស្ថានពិភពលោក។

៥- សន្និសីទកំពូលបណ្តាភាគីអាចពិចារណាលើលទ្ធភាពនៃការបង្កើតមូលនិធិបន្ថែម ដែលជាផ្នែកមួយនៃយន្តការហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការស្តារនូវស្ថានភាពទូទៅនិងប្រព័ន្ធអេកូឡូស៊ីនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៦- មូលនិធិពិសេសពីប្រភពផ្សេងៗទៀតនិងមូលនិធិពិសេសរបស់មូលនិធិបរិស្ថានពិភពលោក ត្រូវបានប្រើប្រាស់ដើម្បី៖

ក- គម្រោងមូលនិធិលើការកសាងសមត្ថភាពក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងគម្រោងប្រកបដោយប្រសិទ្ធភាពលើការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនៃភាពចម្រុះនិងសកម្មភាពជីវៈចម្រុះសមុទ្រ រួមទាំងការបណ្តុះបណ្តាលទាក់ទងនឹងការផ្ទេរបច្ចេកវិទ្យាសមុទ្រ។

ខ- ជួយរដ្ឋភាគីកំពុងអភិវឌ្ឍក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

គ- គាំទ្រកម្មវិធីអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពដោយជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលជាអ្នកថែរក្សាចំណេះដឹងជាប្រពៃណី។

ឃ- គាំទ្រការពិគ្រោះយោបល់ជាសាធារណៈនៅថ្នាក់ជាតិ អនុតំបន់ និងតំបន់។

ង- ផ្តល់មូលនិធិសម្រាប់អនុវត្តសកម្មភាពផ្សេងទៀត តាមការសម្រេចដោយសន្និសីទកំពូលបណ្តាភាគី។

៧- យន្តការហិរញ្ញវត្ថុគួរតែខិតខំធានាថាគ្មានការត្រួតស៊ីគ្នានៃការផ្តល់ហិរញ្ញវត្ថុ លើកកម្ពស់ការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកនិងភាពស៊ីចង្វាក់គ្នា ក្នុងការប្រើប្រាស់មូលនិធិនៅក្នុងយន្តការនេះ។

៨- ធនធានហិរញ្ញវត្ថុដែលកៀរគរបានក្នុងការគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះអាចមានការផ្តល់មូលនិធិពីប្រភពសាធារណៈនិងប្រភពឯកជន ទាំងជាតិនិងអន្តរជាតិ ប៉ុន្តែមិនកំណត់ត្រឹមការចូលរួមវិភាគទានពីរដ្ឋ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ យន្តការផ្តល់មូលនិធិដែលមានស្រាប់ដែលស្ថិតក្រោមអង្គភាពទទួលបន្ទុកនៅកម្រិតសាកលនិងតំបន់ ទីភ្នាក់ងារផ្តល់ជំនួយ អង្គការអន្តររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល តែពីរូបវន្តបុគ្គលនិងនីតិបុគ្គលនិងតាមរយៈភាពជាដៃគូរវាងសាធារណៈនិងឯកជន។

៩- ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃកិច្ចព្រមព្រៀងនេះ យន្តការត្រូវដំណើរការនៅក្រោមសិទ្ធិអំណាច ក្នុងករណីសមស្របនិងតាមការណែនាំរបស់សន្និសីទកំពូលបណ្តាភាគី ត្រូវទទួលខុសត្រូវ ដូចមានលក្ខខណ្ឌកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។ សន្និសីទកំពូលបណ្តាភាគីត្រូវផ្តល់ការណែនាំអំពីយុទ្ធសាស្ត្រ គោលនយោបាយ អាទិភាពកម្មវិធីជារួម និងសិទ្ធិក្នុងការទទួលបាននិងប្រើប្រាស់ធនធានហិរញ្ញវត្ថុ។

១០- សន្និសីទកំពូលបណ្តាភាគីនិងមូលនិធិបរិស្ថានពិភពលោក ត្រូវឯកភាពលើការរៀបចំចាត់ចែងដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចំពោះកថាខណ្ឌខាងលើ នៅក្នុងកិច្ចប្រជុំលើកដំបូងនៃសន្និសីទកំពូលបណ្តាភាគី។

១១- ដោយទទួលស្គាល់ភាពបន្ទាន់ចាំបាច់ក្នុងការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ សន្និសីទកំពូលបណ្តាភាគីត្រូវកំណត់គោលដៅកៀរគរធនធានដំបូងរហូតដល់ឆ្នាំ២០៣០ សម្រាប់មូលនិធិពិសេសពីគ្រប់ប្រភពទាំងអស់ ដោយយកចិត្តទុកដាក់ក្នុងចំណោមកិច្ចការនានានូវគំរូបែបបទតាមស្ថាប័ននៃមូលនិធិពិសេសនិងព័ត៌មានដែលត្រូវផ្តល់ជូន តាមរយៈគណៈកម្មាធិការកសាងសមត្ថភាពនិងផ្ទេរបច្ចេកវិទ្យាសមុទ្រ។

១២- សិទ្ធិទទួលបានមូលនិធិ នៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវបើកទូលាយ ចំពោះរដ្ឋភាគីកំពុងអភិវឌ្ឍ ដោយផ្អែកលើតម្រូវការនៃរដ្ឋភាគីទាំងនោះ។ ការផ្តល់មូលនិធិនៅក្រោមមូលនិធិពិសេស ត្រូវចែកចាយតាមលក្ខណៈវិនិច្ឆ័យនៃការបែងចែកប្រកបដោយសមធម៌ ដោយយកចិត្តទុកដាក់លើតម្រូវការជំនួយរបស់រដ្ឋភាគីដែលមានតម្រូវការពិសេស ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសមិនជាប់នឹងសមុទ្រកំពុងអភិវឌ្ឍ រដ្ឋមានភូមិសាស្ត្រមិនអំណោយផល រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងរដ្ឋមិនជាប់នឹងសមុទ្រនៅអាហ្វ្រិក រដ្ឋនៅតាមប្រជុំកោះនិងបណ្តាប្រទេសមានចំណូលកម្រិតមធ្យមកំពុងអភិវឌ្ឍនិងយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍតិចតួច។ មូលនិធិពិសេសត្រូវកំណត់គោលដៅធានាដល់ការមានលទ្ធភាពទទួលបានមូលនិធិប្រកបដោយ [illegible]តាមរយៈនីតិវិធីនៃការដាក់ពាក្យនិងអនុម័តសាមញ្ញៗនិងការត្រៀមខ្លួនដែលបានរៀបចំឡើង សម្រាប់គាំទ្រ[illegible]ដល់រដ្ឋភាគីកំពុងអភិវឌ្ឍទាំងនោះ។

១៣- ដោយសារតែបញ្ហាកង្វះសមត្ថភាព រដ្ឋភាគីត្រូវលើកទឹកចិត្តឱ្យអង្គការអន្តរជាតិផ្តល់ការអនុគ្រោះនិងពិចារណាលើតម្រូវការជាក់លាក់និងតម្រូវការពិសេសរបស់រដ្ឋភាគីកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច ប្រទេសមិនជាប់នឹងសមុទ្រកំពុងអភិវឌ្ឍនិងរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងដោយយកចិត្តទុកដាក់លើកាលៈទេសៈពិសេសនៃរដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ក្នុងការបែងចែកមូលនិធិឱ្យបានសមស្របនិងជំនួយបច្ចេកទេសនិងការប្រើប្រាស់សេវាឯកទេសរបស់ខ្លួនសម្រាប់គោលដៅអភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រនៅតំបន់ក្រៅដែនយុត្តាធិការជាតិ។

១៤- សន្និសីទកំពូលបណ្តាភាគីត្រូវបង្កើតគណៈកម្មាធិការហិរញ្ញវត្ថុសម្រាប់ធនធានហិរញ្ញវត្ថុ។ គណៈកម្មាធិការនេះត្រូវមានសមាសភាពដោយសមាជិកមានគុណវុឌ្ឍិនិងជំនាញសមស្រប ព្រមទាំងយកចិត្តទុកដាក់លើតុល្យភាពយេនឌ័រនិងបោយភូមិសាស្ត្រប្រកបដោយសមធម៌។ ការពិពណ៌នាពីលក្ខខណ្ឌការងារនិងគំរូបែបបទសម្រាប់ដំណើរការការងាររបស់គណៈកម្មាធិការ ត្រូវសម្រេចដោយសន្និសីទកំពូលនៃបណ្តាភាគី។ គណៈកម្មាធិការនេះត្រូវរាយការណ៍ជាទៀងទាត់និងផ្តល់អនុសាសន៍ អំពីការកំណត់និងការកៀគរមូលនិធិនៅក្រោមយន្តការនេះ។ គណៈកម្មាធិការនេះក៏ត្រូវប្រមូលព័ត៌មាននិងរបាយការណ៍ស្តីពីការផ្តល់មូលនិធិ នៅក្រោមយន្តការនេះនិងលិខិតុបករណ៍ផ្សេងទៀតដែលរួមចំណែកដោយផ្ទាល់ឬដោយប្រយោលដល់ការសម្រេចបានគោលដៅនៃកិច្ចព្រមព្រៀងនេះ។ បន្ថែមពីលើការពិចារណាដែលមាននៅក្នុងមាត្រានេះ គណៈកម្មាធិការត្រូវពិចារណា ក្នុងចំណោមកិច្ចការដទៃទៀតលើ៖

ក- ការវាយតម្លៃតម្រូវការរបស់រដ្ឋភាគី ជាពិសេសរដ្ឋភាគីកំពុងអភិវឌ្ឍ។

ខ- ការមានមូលនិធិនិងការបែងចែកមូលនិធិទាន់ពេលវេលា។

គ- តម្លាភាពលើការធ្វើសេចក្តីសម្រេចចិត្តនិងគ្រប់គ្រងការកៀគរនិងការបែងចែកមូលនិធិ។

ឃ- គណនេយ្យភាពរបស់រដ្ឋភាគីកំពុងអភិវឌ្ឍដែលទទួលបានមូលនិធិត្រូវប្រើប្រាស់មូលនិធិដូចដែលបានព្រមព្រៀងគ្នា។

១៥- សន្និសីទកំពូលបណ្តាភាគីត្រូវពិចារណាលើរបាយការណ៍និងអនុសាសន៍របស់គណៈកម្មាធិការហិរញ្ញវត្ថុនិងចាត់វិធានការសមស្រប។

១៦- លើសពីនេះ សន្និសីទកំពូលបណ្តាភាគីត្រូវធ្វើការពិនិត្យវាយតម្លៃតាមកាលកំណត់នៃយន្តការហិរញ្ញវត្ថុដើម្បីវាយតម្លៃពីភាពគ្រប់គ្រាន់ ប្រសិទ្ធភាពនិងលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ រួមទាំងការផ្តល់ការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ ជាពិសេសដល់រដ្ឋភាគីកំពុងអភិវឌ្ឍ។

## ផ្នែកទី៨

## ការអនុវត្តនិងអនុលោមភាព

### មាត្រា៥៣

### ការអនុវត្ត

រដ្ឋភាគីក្នុងករណីចាំបាច់ត្រូវចាត់វិធានការផ្នែកច្បាប់ រដ្ឋបាល ឬគោលនយោបាយ ដើម្បីធានាដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

### មាត្រា៥៤

### ត្រួតពិនិត្យការអនុវត្ត

រដ្ឋភាគីនីមួយៗត្រូវត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងនេះ ហើយស្ថិតក្នុងទម្រង់និងចន្លោះពេលដែលកំណត់ដោយសន្និសីទកំពូលបណ្តាភាគី ត្រូវរាយការណ៍ទៅសន្និសីទកំពូលនូវវិធានការដែលខ្លួនបានប្រើប្រាស់ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា៥៥

## គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាព

១- គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាព ដើម្បីសម្របសម្រួល ពិចារណាលើការអនុវត្តនិងលើកកម្ពស់អនុលោមភាពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងនេះ។ គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាពត្រូវសម្របសម្រួលតាមលក្ខខណ្ឌនិងមុខងារប្រកបដោយមានតម្លាភាព ដោយមិនប្រឈមនឹងការតវ៉ានិងនិទណ្ឌភាព។

២- គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាពត្រូវមានសមាជិកដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្រប ដែលត្រូវបានតែងតាំងដោយរដ្ឋភាគីនិងត្រូវបានជ្រើសរើសដោយសន្និសីទកំពូលបណ្តាភាគី ដោយយកចិត្តទុកដាក់លើសមតុល្យយេនឌ័រនិងភាពជាតំណាងភូមិសាស្ត្រប្រកបដោយសមធម៌។

៣- គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាពត្រូវប្រតិបត្តិការងារ តាមគំរូបែបបទនិងវិធាននៃនីតិវិធីដែលបានអនុម័តដោយសន្និសីទកំពូលបណ្តាភាគីនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។ គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាព ត្រូវពិចារណាលើបញ្ហានៃការអនុវត្តនិងការអនុលោមតាមកម្រិតជាច់ដោយឡែកនិងជាប្រព័ន្ធនៅក្នុងចំណោមកិច្ចការផ្សេងៗទៀត ដោយត្រូវរាយការណ៍និងផ្តល់អនុសាសន៍តាមកាលកំណត់ ដោយការយកចិត្តទុកដាក់ពីកាលៈទេសៈ យុត្តាធិការជាតិនីមួយៗ ទៅកាន់សន្និសីទកំពូលបណ្តាភាគី។

៤- នៅក្នុងការអនុវត្តការងាររបស់ខ្លួន គណៈកម្មាធិការអនុវត្តន៍និងអនុលោមភាពអាចប្រើប្រាស់ព័ត៌មានសមស្របពីអង្គភាពដែលបានបង្កើតឡើង នៅក្នុងកិច្ចព្រមព្រៀងនេះ ព្រមទាំងអង្គភាពទទួលបន្ទុកលើបើខិត្តបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ និងតាមវិស័យ ក្នុងករណីចាំបាច់។

## ផ្នែកទី៩

## ការដោះស្រាយវិវាទ

## មាត្រា៥៦

## ការទប់ស្កាត់វិវាទ

រដ្ឋភាគីត្រូវសហការគ្នាដើម្បីទប់ស្កាត់ជម្លោះ។

## មាត្រា៥៧

## កាតព្វកិច្ចដោះស្រាយវិវាទដោយសន្តិវិធី

រដ្ឋភាគីមានកាតព្វកិច្ចដោះស្រាយវិវាទរបស់ខ្លួនទាក់ទងនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ តាមរយៈការចរចា ការសាកសួរ ការសម្រុះសម្រួល ការផ្សះផ្សា មជ្ឈត្តកម្ម ការដោះស្រាយតាមប្រព័ន្ធតុលាការ ស្វែងរកជំនួយពីភ្នាក់ងារ ឬការរៀបចំថ្នាក់តំបន់ ឬដោយសន្តិវិធី តាមជម្រើសផ្សេងៗរបស់ខ្លួន។

## មាត្រា៥៨

## ការដោះស្រាយវិវាទដោយសន្តិវិធីតាមការជ្រើសរើសរបស់រដ្ឋភាគី

គ្មានខ្លឹមសារណាមួយក្នុងផ្នែកនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋភាគីណាមួយនៃកិច្ចព្រមព្រៀងនេះឡើយ ក្នុងការព្រមព្រៀងគ្នានៅពេលណាមួយដើម្បីរដ្ឋភាគីយល់ព្រមដោះស្រាយនូវវិវាទរបស់ខ្លួន ដែលទាក់ទងនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះដោយសន្តិវិធីតាមជម្រើសរបស់ខ្លួនផ្ទាល់។

## មាត្រា៥៩

## វិវាទជាលក្ខណៈបច្ចេកទេស

នៅពេលមានវិវាទដែលទាក់ទងនឹងលក្ខណៈបច្ចេកទេស រដ្ឋភាគីពាក់ព័ន្ធអាចបញ្ជូនវិវាទនេះទៅក្រុមជំនាញការចំពោះកិច្ច ដែលបង្កើតឡើងដោយរដ្ឋភាគីផ្ទាល់។ គណៈកម្មាធិការត្រូវប្រជុំជាមួយរដ្ឋភាគីពាក់ព័ន្ធ ហើយត្រូវខិតខំដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ដោយមិនឧបាស្រ័យលើនីតិវិធីផ្លូវច្បាប់សម្រាប់ដោះស្រាយវិវាទ ដូចនៅក្នុងមាត្រា៦០នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា៦០

## នីតិវិធីដោះស្រាយវិវាទ

១- វិវាទទាក់ទងនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយដោយអនុលោមតាមបទប្បញ្ញត្តិសម្រាប់ដោះស្រាយវិវាទដូចមានចែងក្នុងផ្នែកទី១៥ នៃអនុសញ្ញា។

២- បទប្បញ្ញត្តិនៃផ្នែកទី១៥និងឧបសម្ព័ន្ធV VI VII និងVIII នៃអនុសញ្ញា ត្រូវបានជ្រើសរើសមកប្រើប្រាស់សម្រាប់ដោះស្រាយវិវាទពាក់ព័ន្ធនឹងរដ្ឋភាគីណាមួយនៃកិច្ចព្រមព្រៀងនេះ ដែលរដ្ឋភាគីនោះគឺមិនមែនជារដ្ឋភាគីនៃអនុសញ្ញា។

៣- នីតិវិធីណាមួយដែលទទួលយកដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមមាត្រា២៨៧ រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវអនុវត្តដោះស្រាយវិវាទនៅក្នុងផ្នែកនេះ លើកលែងតែរដ្ឋភាគីនោះនៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្វីការ ឬយល់ព្រមចូលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ឬក្រោយមកនៅពេលណាមួយ បានទទួលយកនីតិវិធីមួយផ្សេងទៀត ស្របតាមមាត្រា២៨៧ នៃអនុសញ្ញាសម្រាប់ដោះស្រាយវិវាទនៅក្រោមផ្នែកនេះ។

៤- សេចក្តីប្រកាសណាមួយដែលធ្វើឡើងដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដែលជារដ្ឋភាគីនៃអនុសញ្ញាដោយអនុលោមតាមមាត្រា២៩៨ រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវអនុវត្តដំណោះស្រាយវិវាទនៅក្នុងផ្នែកនេះ លើកលែងតែរដ្ឋភាគីនោះនៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្វីការ ឬយល់ព្រមចូលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ឬក្រោយមកនៅពេលណាមួយ បានធ្វើសេចក្តីប្រកាសផ្សេងទៀត ស្របតាមមាត្រា២៩៨ នៃអនុសញ្ញាសម្រាប់ដោះស្រាយវិវាទនៅក្រោមផ្នែកនេះ។

៥- អនុលោមតាមកថាខណ្ឌ២ខាងលើ រដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញា នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្វីការ ឬយល់ព្រមចូលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ឬក្រោយមកនៅពេលណាមួយ រដ្ឋភាគីនៃកិច្ចព្រមព្រៀងមានសេរីភាពក្នុងការជ្រើសរើស តាមមធ្យោបាយនៃសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដោយបញ្ជូនទៅកន្លែងទទួល ដែលជាមធ្យោបាយមួយឬច្រើនដើម្បីដោះស្រាយវិវាទទាក់ទងនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ ដូចខាងក្រោម៖

ក- តុលាការអន្តរជាតិទទួលបន្ទុកច្បាប់សមុទ្រ។

ខ- តុលាការយុត្តិធម៌អន្តរជាតិ។

គ- សាលាក្តីមជ្ឈត្តកម្មដូចក្នុងឧបសម្ព័ន្ធVII។

ឃ- សាលាក្តីអាជ្ញាកណ្តាលពិសេសដូចក្នុងឧបសម្ព័ន្ធVIII សម្រាប់ប្រភេទវិវាទមួយឬច្រើនដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ។

៦- រដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញា ដែលមិនបានចេញសេចក្តីប្រកាស (គ) ត្រូវចាត់ទុកថាបានទទួលយកជម្រើសក្នុងកថាខណ្ឌ៥(គ)ខាងលើ។ ប្រសិនបើរដ្ឋភាគីមានវិវាទបានទទួលយកនីតិវិធីដូចគ្នា សម្រាប់ការដោះស្រាយវិវាទនោះ រដ្ឋភាគីនោះអាចត្រូវបានដាក់ឱ្យអនុវត្តនីតិវិធីនេះ លុះត្រាតែរដ្ឋភាគីក្នុងវិវាទនោះ

មានការឯកភាពផ្សេង។ ប្រសិនបើរដ្ឋភាគីជម្លោះមិនទទួលយកនីតិវិធីដូចគ្នាក្នុងការដោះស្រាយវិវាទនោះទេរដ្ឋភាគីនោះអាចងាកទៅជ្រើសរើសមជ្ឈត្តកម្មដូចនៅក្រោមឧបសម្ព័ន្ធVII នៃអនុសញ្ញានេះបានលុះត្រាតែរដ្ឋភាគីដែលមានវិវាទយល់ព្រមផ្សេង។ មាត្រា២៨៧ កថាខណ្ឌ៦ដល់៨នៃអនុសញ្ញា ត្រូវអនុវត្តចំពោះសេចក្តីប្រកាសដូចមានក្នុងកថាខណ្ឌ៥ខាងលើ។

៧-រដ្ឋភាគីមួយនៃកិច្ចព្រមព្រៀងដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញានេះ អាចនៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស៊ីការ ឬយល់ព្រមចូលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះឬក្រោយមកនៅពេលណាមួយ ដោយមិនប៉ះពាល់ដល់កាតព្វកិច្ចដែលកំណត់នៅក្នុងផ្នែកនេះ ធ្វើការប្រកាសជាលាយលក្ខណ៍អក្សរថា ខ្លួនមិនទទួលយកនីតិវិធីមួយឬច្រើនដែលមានចែងក្នុងផ្នែកទី១៥ ចំណុចទី២ នៃអនុសញ្ញា ទាក់ទងនឹងប្រភេទវិវាទមួយឬច្រើនដូចមានចែងក្នុងមាត្រា២៩៨ នៃអនុសញ្ញាសម្រាប់ដោះស្រាយវិវាទ នៅក្រោមផ្នែកនេះ។ មាត្រា២៩៨ នៃអនុសញ្ញាត្រូវអនុវត្តចំពោះសេចក្តីប្រកាសបែបនេះ។

៨-បទប្បញ្ញត្តិនៃមាត្រានេះ នឹងមិនបង្កឧបសគ្គដល់នីតិវិធីស្តីពីការដោះស្រាយវិវាទដែលរដ្ឋភាគីបានព្រមព្រៀងក្នុងនាមជាអ្នកចូលរួមក្នុងអង្គភាពទទួលបន្ទុកលើលិខិតូបករណ៍នីត្យានុកូលនិងក្របខ័ណ្ឌការងារពាក់ព័ន្ធ នៅកម្រិតសាកល តំបន់ អនុតំបន់ ឬតាមវិស័យ ទាក់ទងនឹងការបកស្រាយឬការអនុវត្តលិខិតូបករណ៍និងក្របខ័ណ្ឌការងារបែបទាំងនេះ។

៩- គ្មានខ្លឹមសារណាមួយក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានបកស្រាយថាជាការផ្តល់យុត្តាធិការជូនតុលាការឬសាលាក្តីចំពោះវិវាទណាមួយដែលមានការពាក់ព័ន្ធឬចូលរួមជាចាំបាច់ ក្នុងការពិចារណាក្នុងពេលជាមួយគ្នានៃស្ថានភាពផ្លូវច្បាប់នៃតំបន់មួយ ដូចជានៅក្នុងយុត្តាធិការជាតិឬចំពោះវិវាទណាមួយដែលទាក់ទងនឹងអធិបតេយ្យភាពឬសិទ្ធិផ្សេងទៀតលើដែនដីតាមទ្វីបឬដែនកោះឬការទាមទារដូច្នេះរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដោយសារថាគ្មានខ្លឹមសារណាមួយនៅក្នុងកថាខណ្ឌនេះ នឹងត្រូវបានបកស្រាយថាជាការដាក់កំហិតកំណត់លើដែនសមត្ថកិច្ចរបស់តុលាការឬសាលាក្តីនៅក្រោមផ្នែកទី១៥ ចំណុចទី២ នៃអនុសញ្ញា។

១០- ដើម្បីបញ្ចៀសការសង្ស័យ គ្មានខ្លឹមសារណាមួយក្នុងកិច្ចព្រមព្រៀងនេះត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការអះអាងឬបដិសេធការទាមទារណាមួយចំពោះអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការលើដែនដីឬតំបន់សមុទ្រ រួមទាំងវិវាទណាមួយដែលទាក់ទងនឹងបញ្ហានេះ។

## មាត្រា៦១

## ការរៀបចំបណ្តោះអាសន្ន

ក្នុងពេលរង់ចាំការដោះស្រាយវិវាទដោយអនុលោមតាមផ្នែកនេះ រដ្ឋភាគីមានវិវាទនឹងខិតខំប្រឹងប្រែងរៀបចំដំណោះស្រាយវិវាទតាមសភាពជាក់ស្តែង។

## ផ្នែកទី១០

## រដ្ឋដែលមិនមែនជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ

## មាត្រា៦២

## រដ្ឋដែលមិនមែនជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ

រដ្ឋភាគីនៃកិច្ចព្រមព្រៀងត្រូវលើកទឹកចិត្តដល់រដ្ឋដែលមិនមែនជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះឱ្យក្លាយទៅជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដើម្បីមានសិទ្ធិក្នុងការអនុម័តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ឱ្យស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

## ផ្នែកទី១១

## ភាពស្មោះត្រង់និងការរំលោភសិទ្ធិ

### មាត្រា៦៣

### ភាពស្មោះត្រង់និងការរំលោភសិទ្ធិ

រដ្ឋភាគីត្រូវបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះដោយភាពស្មោះត្រង់ ហើយអនុវត្តសិទ្ធិដែលត្រូវបានទទួលស្គាល់ តាមទម្រង់ដែលនឹងមិននាំដល់ការរំលោភសិទ្ធិ។

## ផ្នែកទី១២

## អវសានប្បញ្ញត្តិ

### មាត្រា៦៤

### សិទ្ធិបោះឆ្នោត

១- រដ្ឋភាគីនីមួយៗនៃកិច្ចព្រមព្រៀងនេះ មានសំឡេងបោះឆ្នោតតែមួយសំឡេង លើកលែងតែមានចែងផ្សេងពីនេះ ដូចក្នុងកថាខណ្ឌ២ខាងក្រោម។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ដែលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើសមត្ថកិច្ចរបស់ខ្លួន ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតដោយមានសំឡេងស្មើនឹងចំនួនរដ្ឋជាសមាជិករបស់ខ្លួនដែលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ។ អង្គការនេះនឹងមិនប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតទេ ប្រសិនបើរដ្ឋជាសមាជិកណាមួយអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោត ហើយប្រសិនបើរដ្ឋជាសមាជិកណាមួយអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតហើយផ្ទុយទៅវិញ អង្គការនេះនឹងមិនប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតទេ។

### មាត្រា៦៥

### ហត្ថលេខា

កិច្ចព្រមព្រៀងនេះនឹងត្រូវបើកទូលាយឱ្យមានការចុះហត្ថលេខាដោយរដ្ឋទាំងអស់និងអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ហើយនឹងនៅតែបើកទូលាយឱ្យមានការចុះហត្ថលេខានៅទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ករហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥។

### មាត្រា៦៦

### ការផ្តល់សច្ចាប័ន ការអនុម័ត ស្ទីការ និងការចូលជាសមាជិក

កិច្ចព្រមព្រៀងនេះត្រូវទទួលបានការផ្តល់សច្ចាប័ន អនុម័ត ឬការទទួលយកជាសមាជិក ដោយរដ្ឋនិងអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ កិច្ចព្រមព្រៀងនេះត្រូវបានបើកទូលាយឱ្យរដ្ឋនិងអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ចូលជាសមាជិក ចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆេទបិទការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការអនុម័ត ស្ទីការនិងការចូលជាសមាជិក ត្រូវតែតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា៦៧

### ការបែងចែកសមត្ថកិច្ចនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងរដ្ឋជាសមាជិករបស់ខ្លួន ដែលទាក់ទងនឹងបញ្ហាគ្រប់គ្រងដោយកិច្ចព្រមព្រៀងនេះ

១- អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ណាមួយដែលក្លាយជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះដោយគ្មានរដ្ឋសមាជិកណាមួយជារដ្ឋភាគី នឹងត្រូវចងភ្ជាប់ដោយកាតព្វកិច្ចទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ។ ក្នុងករណីអង្គការ

បែបនេះ មានរដ្ឋសមាជិកមួយឬច្រើនដែលជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ អង្គការនិងរដ្ឋជាសមាជិករបស់ខ្លួនត្រូវសម្រេចលើការទទួលខុសត្រូវជាច់ដោយឡែករៀងៗខ្លួន ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងនេះ។ ក្នុងករណីបែបនេះ អង្គការនិងរដ្ឋជាសមាជិកនឹងពុំមានសិទ្ធិអនុវត្តសិទ្ធិដែលស្ថិតក្នុងកិច្ចព្រមព្រៀងនេះដំណាលៗគ្នាក្នុងពេលតែមួយឡើយ។

២- នៅក្នុងលិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការអនុម័ត ស្វីការ ឬការចូលជាសមាជិក អង្គការសេមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ត្រូវប្រកាសអំពីវិសាលភាពនៃដែនសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចការ គ្រប់គ្រងដោយកិច្ចព្រមព្រៀងនេះ។ អង្គការនេះ ត្រូវជូនដំណឹងទៅអ្នករក្សាទុកលិខិតូបករណ៍ ដែលជាការកិច្ចរបស់ខ្លួន រួចត្រូវជូនដំណឹងដល់រដ្ឋភាគីអំពីការកែប្រែពាក់ព័ន្ធលើវិសាលភាពនៃដែនសមត្ថកិច្ចរបស់ខ្លួន។

## មាត្រា៦៨

## ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានលិខិតូបករណ៍ទី៦០នៃការផ្ដល់សច្ចាប័ន ការអនុម័ត ស្វីការ ឬការចូលជាសមាជិក។

២- សម្រាប់រដ្ឋឬអង្គការសេមាហរណកម្មសេដ្ឋកិច្ច ថ្នាក់តំបន់នីមួយៗដែលផ្ដល់សច្ចាប័ន អនុម័ត ឬស្វីការកិច្ចព្រមព្រៀងនេះ ឬចូលជាសមាជិក បន្ទាប់ពីការទទួលបានលិខិតូបករណ៍ទី៦០ នៃការផ្ដល់សច្ចាប័ន ការអនុម័ត ស្វីការ ឬការចូលជាសមាជិកនោះ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីការទទួលបានលិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការអនុម័ត ស្វីការ ឬការចូលជាសមាជិករបស់ខ្លួន ស្របតាមកថាខណ្ឌ១ខាងលើ។

៣- ក្នុងការបំពេញនូវគោលដៅនៃកថាខណ្ឌ១និង២ខាងលើ រាល់លិខិតូបករណ៍ដែលអង្គការសេមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ដែលទទួលបាន គឺមិនត្រូវរាប់បញ្ចូលបន្ថែមជាមួយនឹងលិខិតូបករណ៍ដែលទទួលបានដោយរដ្ឋសមាជិកនៃអង្គការនោះឡើយ។

## មាត្រា៦៩

## ការអនុវត្តបណ្ដោះអាសន្ន

១- កិច្ចព្រមព្រៀងនេះ អាចត្រូវបានអនុវត្តជាបណ្ដោះអាសន្នដោយរដ្ឋមួយឬអង្គការសេមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលយល់ព្រមលើការអនុវត្តបណ្ដោះអាសន្នរបស់ខ្លួន តាមរយៈការជូនដំណឹងដល់អ្នកតម្កល់ទុកលិខិតូបករណ៍ ដែលមានជាលាយលក្ខណ៍អក្សរនៅពេលចុះហត្ថលេខាឬការទទួលបានលិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ការអនុម័ត ស្វីការ ឬកាចូលជាសមាជិករបស់ខ្លួន។ ការអនុវត្តបណ្ដោះអាសន្នបែបនេះត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹងពីអ្នកតម្កល់ទុកលិខិតូបករណ៍។

២- ការអនុវត្តបណ្ដោះអាសន្នរបស់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ត្រូវបញ្ឈប់នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន សម្រាប់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះ ឬបន្ទាប់ពីការជូនដំណឹងរបស់រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ទៅអ្នកតម្កល់ទុកលិខិតូបករណ៍ដែលមានជាលាយលក្ខណ៍អក្សរអំពីចេតនា ដើម្បីបញ្ឈប់ការអនុវត្តបណ្ដោះអាសន្នរបស់ខ្លួន។

## មាត្រា៧០

## ការរក្សាការពារនិងអញ្ញត្រកម្ម

មិនមានកិច្ចរក្សាការពារឬការលើកលែងណាអាចត្រូវបានធ្វើឡើងចំពោះកិច្ចព្រមព្រៀងនេះបានទេ គឺលុះត្រាតែត្រូវបានអនុញ្ញាតយ៉ាងច្បាស់ដោយមាត្រាផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា៧១

## សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍

មាត្រា៧០ មិនបានហាមឃាត់រដ្ឋឬអង្គការសេមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលនៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន អនុម័ត ស្ទីការ ឬចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ពីការធ្វើសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍ ទោះជាមានឃ្លាឬមានឈ្មោះ ក្នុងចំណោមខ្លឹមសារផ្សេងៗទៀតក៏ដោយ ក៏ក្នុងគោលដៅធ្វើសុខដុមនីយកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាមួយនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ហើយទោះបីជាសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍ទាំងនោះមិនមានចែងពីការដកខ្លួនចេញឬកែប្រែអានុភាពតាមនីត្យានុកូលនៃបទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះដើម្បីរដ្ឋឬអង្គការសេមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះអនុវត្តតាមភារកិច្ចរបស់ខ្លួន។

## មាត្រា៧២

## ការធ្វើវិសោធនកម្ម

១- រដ្ឋភាគីមួយអាចស្នើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះបាន តាមរយៈការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរទៅកាន់លេខាធិការដ្ឋាន។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយការប្រាស្រ័យទាក់ទងបែបនេះទៅកាន់រដ្ឋភាគីទាំងអស់។ ក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សាយការប្រាស្រ័យទាក់ទងនេះចេញទៅ ប្រសិនបើរដ្ឋភាគីមិនតិចជាងពាក់កណ្តាលឆ្លើយតបដោយគាំទ្រនឹងសំណើនោះ នោះវិសោធនកម្មដែលបានស្នើឡើងត្រូវយកមកពិចារណានៅក្នុងកិច្ចប្រជុំខាងមុខនៃសន្និសីទបណ្តាភាគី។

២- វិសោធនកម្មលើកិច្ចព្រមព្រៀងនេះដែលបានអនុម័តដោយអនុលោមតាមមាត្រា៤៧ ត្រូវបានបញ្ជូនដោយអ្នកតម្កល់ទុកលិខិតូបករណ៍ទៅរដ្ឋភាគីទាំងអស់សម្រាប់ការផ្តល់សច្ចាប័ន ការអនុម័ត ឬការចូលជាសមាជិក។

៣- វិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីដែលផ្តល់សច្ចាប័ន ការអនុម័ត ឬស្ទីការវិសោធនកម្មនោះ នៅថ្ងៃទី៣០ បន្ទាប់ពីការទទួលបានលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការអនុម័ត ឬទទួលយកដោយចំនួនពីរភាគបីនៃចំនួនរដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ក្នុងពេលនៃការអនុម័តវិសោធនកម្ម។ សម្រាប់រដ្ឋភាគីនីមួយៗដែលតម្កល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការអនុម័ត ឬស្ទីការវិសោធនកម្ម បន្ទាប់ពីតម្កល់នូវលិខិតូបករណ៍បានតាមចំនួនចាំបាច់ហើយនោះ វិសោធនកម្មនោះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីតម្កល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការអនុម័ត ឬស្ទីការវិសោធនកម្មរួចរាល់។

៤- ក្នុងពេលមានការអនុម័តវិសោធនកម្មមួយ វិសោធនកម្មនោះអាចកំណត់ថា ចាំបាច់ត្រូវមានការផ្តល់សច្ចាប័ន ការអនុម័ត ឬស្ទីការវិសោធនកម្មសម្រាប់ការចូលជាធរមាននោះមានក្នុងចំនួនតិចឬច្រើនជាងតម្រូវការដែលបានកំណត់ក្នុងមាត្រានេះ។

៥- ដើម្បីសម្រេចគោលដៅនៃកថាខណ្ឌ៣និង៤ខាងលើ លិខិតូបករណ៍ណាមួយដែលដាក់តម្កល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ មិនត្រូវបានរាប់បញ្ចូលបន្ថែមទៅនឹងលិខិតូបករណ៍ដែលដាក់តម្កល់ទុកដោយរដ្ឋសមាជិកនៃអង្គការនោះឡើយ។

៦- រដ្ឋមួយឬអង្គការសេមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលក្លាយជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មស្របតាមកថាខណ្ឌ៣ខាងលើ ដែលបានខកខានក្នុងការបង្ហាញនូវចេតនាផ្សេងពីរដ្ឋឬអង្គការសេមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះ៖

ក- ត្រូវបានចាត់ទុកថាជារដ្ឋភាគីនៃកិច្ចព្រមព្រៀងនេះ ដូចដែលបានធ្វើវិសោធនកម្ម។

ខ- ត្រូវបានចាត់ទុកថាជារដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលមិនមានវិសោធនកម្ម ទាក់ទងនឹងរដ្ឋភាគីណាមួយដែលមិនជាប់កាតព្វកិច្ចផ្លូវច្បាប់តាមរយៈវិសោធនកម្មនោះ។

### មាត្រា៧៣

### ការប្រកាសបដិសេធ

១- តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីមួយអាចប្រកាសបដិសេធកិច្ចព្រមព្រៀងនេះ ហើយអាចបញ្ជាក់ពីហេតុផលនៃការប្រកាសបដិសេធរបស់ខ្លួន។ ការខកខានក្នុងការបញ្ជាក់ពីមូលហេតុ ដែលមិនត្រូវឱ្យប៉ះពាល់ដល់សុពលភាពនៃការប្រកាសបដិសេធនោះឡើយ។ ការប្រកាសបដិសេធត្រូវចូលជាធរមានក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង លើកលែងតែការជូនដំណឹងនោះមានបញ្ជាក់ច្បាស់លាស់អំពីកាលបរិច្ឆេទយូរជាងនេះ។

២- ទោះជាយ៉ាងណាក្តី ការប្រកាសបដិសេធនឹងធ្វើមិនឱ្យប៉ះពាល់ដល់ភារកិច្ចរបស់រដ្ឋភាគីណាមួយក្នុងការបំពេញកាតព្វកិច្ចណាមួយ ដូចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលតាមរយៈកាតព្វកិច្ចនោះ រដ្ឋភាគីនោះអាចអនុវត្តភារកិច្ចរបស់ខ្លួន នៅក្រោមច្បាប់អន្តរជាតិ ដោយមិនពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ។

### មាត្រា៧៤

### ឧបសម្ព័ន្ធ

១- ឧបសម្ព័ន្ធទាំងអស់គឺជាផ្នែកដ៏សំខាន់មួយនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការចែងច្បាស់ជាងនេះម្យ៉ាងវិញទៀត សេចក្តីយោងនៃកិច្ចព្រមព្រៀងឬផ្នែកមួយនៃផ្នែកនានានៃកិច្ចព្រមព្រៀងនេះ គឺដូចមានក្នុងសេចក្តីយោងនៃឧបសម្ព័ន្ធទាំងនេះ។

២- បទប្បញ្ញត្តិនៃមាត្រា៧២ ដែលទាក់ទងទៅនឹងវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះក៏ត្រូវអនុវត្តផងដែរលើសំណើ ការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធថ្មីនៃកិច្ចព្រមព្រៀងនេះ។

៣- រដ្ឋភាគីណាមួយអាចស្នើសុំធ្វើវិសោធនកម្មលើឧបសម្ព័ន្ធណាមួយនៃកិច្ចព្រមព្រៀងនេះ សម្រាប់ជាការពិចារណានៅក្នុងកិច្ចប្រជុំលើកក្រោយនៃសន្និសីទកំពូលបណ្តាភាគី។ ឧបសម្ព័ន្ធទាំងនេះអាចត្រូវបានកែប្រែដោយសន្និសីទកំពូលបណ្តាភាគី។ ទោះបីជាមានបទប្បញ្ញត្តិនានានៃមាត្រា៧២ក៏ដោយ ក៏បទប្បញ្ញត្តិខាងក្រោមត្រូវអនុវត្តទាក់ទងនឹងការធ្វើវិសោធនកម្មសម្រាប់ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ៖

ក- អត្ថបទវិសោធនកម្មដែលបានស្នើឡើង ត្រូវបញ្ជូនទៅលេខាធិការដ្ឋាន យ៉ាងតិច១៥០(មួយរយហាសិប) ថ្ងៃមុនកិច្ចប្រជុំ។ នៅពេលទទួលបានអត្ថបទវិសោធនកម្មដែលបានស្នើឡើង លេខាធិការដ្ឋានត្រូវបញ្ជូនអត្ថបទវិសោធនកម្មនេះទៅរដ្ឋភាគីនានា។ លេខាធិការដ្ឋានត្រូវពិគ្រោះយោបល់ជាមួយអង្គភាពបុគ្រសម្ព័ន្ធ តាមការចាំបាច់ ហើយត្រូវបញ្ជូនការឆ្លើយតបទៅរដ្ឋភាគីទាំងអស់មិនលើសពី៣០(សាបសិប)ថ្ងៃ មុនកិច្ចប្រជុំ។

ខ- វិសោធនកម្មដែលបានអនុម័តនៅក្នុងកិច្ចប្រជុំ ត្រូវចូលជាធរមានក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ បន្ទាប់ពីបិទកិច្ចប្រជុំនៃរដ្ឋភាគីទាំងអស់ លើកលែងតែរដ្ឋភាគីមានការជំទាស់ស្របតាមកថាខណ្ឌ៤ខាងក្រោម។

៤- ក្នុងអំឡុងពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ៣(ខ)ខាងលើ រដ្ឋភាគីណាមួយអាចធ្វើការជំទាស់ទាក់ទងនឹងវិសោធនកម្មនេះបាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតម្កល់ទុកលិខិតុបករណ៍។ ការជំទាស់បែបនេះអាចត្រូវបានដកចេញ នៅពេលណាក៏បានដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតម្កល់ទុកលិខិតុបករណ៍ ហើយនៅពេលនោះ វិសោធនកម្មលើឧបសម្ព័ន្ធត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីនោះនៅថ្ងៃទី៣០ បន្ទាប់ពីថ្ងៃដកការជំទាស់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា៧៥

## អ្នកតម្កល់ទុកលិខិតុបករណ៍

អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នកតម្កល់ទុកកិច្ចព្រមព្រៀងនេះនិងវិសោធនកម្មឬការកែប្រែណាមួយដូចបានកំណត់ខាងលើ។

## មាត្រា៧៦

## ឯកសារយថាភូត

កិច្ចព្រមព្រៀងនេះមានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានតម្លៃជាយថាភូតស្មើៗគ្នា។



### ឧបសម្ព័ន្ធ I

### លក្ខណវិនិច្ឆ័យជារួមសម្រាប់ការកំណត់អត្តសញ្ញាណតំបន់

ក- ភាពពិសេសដោយឡែក។

ខ- ភាពកម្រ។

គ- សារៈសំខាន់ពិសេសសម្រាប់ដំណាក់កាលជីវប្រវត្តិនៃប្រភេទសត្វ។

ឃ- សារៈសំខាន់ពិសេសនៃប្រភេទសត្វដែលបានរកឃើញនៅក្នុងតំបន់នោះ។

ង- សារៈសំខាន់សម្រាប់ប្រភេទសត្វឬទីជម្រកដែលកំពុងរងការគំរាមកំហែង ជិតផុតពូជឬកំពុងធ្លាក់ចុះ។

ច- ភាពងាយរងគ្រោះ រួមទាំងការប្រែប្រួលអាកាសធាតុនិងការឡើងកម្រិតអាស៊ីដនៃមហាសមុទ្រ។

ឆ- ភាពផុយស្រួយ។

ជ- ភាពសើប។

ឈ- ជីវៈចម្រុះនិងផលិតភាព។

ញ- ភាពជាតំណាង។

ដ- ភាពពឹងអាស្រ័យ។

ឋ- ភាពជាធម្មជាតិ។

ឌ- តំណភ្ជាប់ប្រព័ន្ធអេកូឡូស៊ី។

ឍ- ដំណើរការសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ីដែលកើតឡើង។

ណ- កត្តាសេដ្ឋកិច្ចនិងសង្គមកិច្ច។

ត- កត្តាវប្បធម៌។

ថ- ហេតុប៉ះពាល់កើនសរុបនិងឆ្លងដែន។

ទ- ការកកើតឡើងវិញនិងភាពធន់យឺត។

ធ- ភាពគ្រប់គ្រាន់និងលទ្ធភាពជោគជ័យ។

ន- ភាពអាចអនុវត្តឡើងវិញបាន។

ប- ចីរភាពនៃការបន្តពូជ។

ផ- អត្ថិភាពនៃវិធានការអភិរក្សនិងការគ្រប់គ្រង។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឧបសម្ព័ន្ធII**

**ប្រភេទនៃការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ**

នៅក្នុងកិច្ចព្រមព្រៀងនេះ គំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាពនិងការផ្ទេរបច្ចេកវិទ្យាសមុទ្រ អាចរួមមាន ប៉ុន្តែមិនបានកំណត់ត្រឹមតែ៖

ក- ការចែករំលែកទិន្នន័យ ព័ត៌មាន ចំណេះដឹង និងលទ្ធផលស្រាវជ្រាវពាក់ព័ន្ធ ក្នុងទម្រង់ដែលងាយស្រួលដល់អ្នកប្រើប្រាស់ រួមមាន៖

១- ការចែករំលែកចំណេះដឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសមុទ្រ។

២- ការផ្លាស់ប្តូរព័ត៌មានស្តីពីការអភិរក្សនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៣- ការចែករំលែកលទ្ធផលស្រាវជ្រាវនិងការអភិវឌ្ឍ។

ខ- ការផ្សព្វផ្សាយព័ត៌មាននិងការលើកកម្ពស់ការយល់ដឹង រួមទាំង៖

១- ការស្រាវជ្រាវបែបវិទ្យាសាស្ត្រសមុទ្រ វិទ្យាសាស្ត្រសមុទ្រ ប្រតិបត្តិការសមុទ្រ និងសេវាកម្មសមុទ្រពាក់ព័ន្ធ។

២- ព័ត៌មានបរិស្ថាននិងជីវៈចម្រុះ ដែលប្រមូលបានតាមរយៈការស្រាវជ្រាវដែលធ្វើឡើងក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ។

៣- ចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ ស្របតាមការឯកភាពជាមុនដោយសេរីនិងមានព័ត៌មានគ្រប់គ្រាន់ពីអ្នកថែរក្សានូវចំណេះដឹងទាំងនោះ។

៤- ភាពតានតឹងនៅលើមហាសមុទ្រដែលប៉ះពាល់ដល់ជីវៈចម្រុះសមុទ្រក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ រួមទាំងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដូចជាការឡើងកម្តៅនិងការបន្សាបអុកស៊ីសែនមហាសមុទ្រ ព្រមទាំងអាស៊ីដកម្មមហាសមុទ្រ។

៥- វិធានការ ក៏ដូចជាឧបករណ៍គ្រប់គ្រងតាមតំបន់ រួមទាំងតំបន់ការពារធម្មជាតិសមុទ្រ។

៦- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

គ- ការអភិវឌ្ឍនិងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ រួមទាំងឧបករណ៍ដូចជា៖

១- ការអភិវឌ្ឍនិងការបង្កើតហេដ្ឋារចនាសម្ព័ន្ធចាំបាច់។

២- ការផ្តល់បច្ចេកវិទ្យា រួមទាំងឧបករណ៍យកសំណាកគំរូនិងអភិក្រម( ឧទា. សម្រាប់សំណាកទឹក ភូមិសាស្ត្រ ជីវសាស្ត្រឬគីមីសាស្ត្រ)។

